01329764




អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi


---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance


ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 21-Sep-2016, 14:29

CMS/CFO: Sann Rada


# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៤៣០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវិន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ជេត វណ្ណលី

លោក ឡោ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ងួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

## ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| សាក្សី 2-TCW-1005 | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-1005

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្ដើមពី............................................................ ទំព័រ ២
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ............................................................ ទំព័រ ១៧
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី............................................................ ទំព័រ ៣២
សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................ ទំព័រ ៤៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ............................................................ ទំព័រ ៤៧
សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............................................................ ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1005។ ហើយលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោកស្រី ម៉ារី ហ្គីរ៉ូឌ័ មេធាវីនាំមុខអន្តរជាតិតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីអវត្តមាន ដោយមូលហេតុផ្ទាល់ខ្លួន។ ហើយ លីវ សុវណ្ណា មេធាវីជាតិការពារក្ដីឱ្យលោក នួន ជា បានជូនដំណឹងមកថា លោកនឹងមកយឺតនៅពេលសវនាការព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-1005។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍

បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះជាប្រចាំ បើអង្គុយយូរឈឺកាន់តែខ្លាំង ហើយនិងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៧:១៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វីណ្ឌៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ម្សិលមិញលោកបានឆ្លើយថា <មនុស្ស១១នាក់>ត្រូវបានគេបញ្ជូន<ពី>តំបន់៥០៥ ពីក្រចេះ <ទៅភ្នំពេញតាមយន្តហោះ> នៅពេលដែលលោកធ្វើការនៅកងពល១១៧<នៅក្រចេះ>។ ហើយលោកក៏បានផ្តល់សក្ខីកម្មផងដែរថា ការបញ្ជូននេះ គឺដោយសារតែតាមសំណើរបស់មន្ទីរ៨៧០។ ក្នុងចំណោមមនុស្សទាំង១១នាក់ដែលគេបញ្ជូនមក លោកបានឆ្លើយនៅចំពោះ

មុខតុលាការ គឺថាលោកនៅចាំឈ្មោះប្រាំនាក់ទេ។ ហើយលោកក៏បានឆ្លើយផងដែរថា មេបញ្ជាការកងពល១១៧ ឈ្មោះ លាង ត្រូវបានគេបញ្ជូនមកភ្នំពេញ<តាមកាណូត>តាំងពីពីរបីថ្ងៃមុន<>មេដឹកនាំដទៃទៀត ដែលបានបញ្ជូនមកតាមយន្តហោះ<>។ ក្រោយពីគេបញ្ជូនអ្នកទាំងនោះមកភ្នំពេញរួចមក តើលោកមានធ្លាប់ដែលបានឮថា អ្នកទាំងនោះណាខ្លះនៅរស់រានមានជីវិតដែរទេ?

[០៩:០៨:៥៧]

**2-TCW-1005៖**

**ឆ៖** បាទ បញ្ហាដែលហ្នឹងខ្ញុំអាន១នៅក្នុងឯកសារសម្ភាសមុនហើយ ព្រោះថាមកហ្នឹងបាត់ខ្លួនទាំងអស់ ដែលក្នុងទាំងកងពល ទាំងតំបន់ និងវរសេនាធំ ទាំងស្រុកអីហ្នឹងគឺអត់មានបានត្រឡប់ទៅវិញទេ ត្រូវប្ដូរកងពលថ្មី វរសេនាធំថ្មីមួយចំនួន គណៈតំបន់ថែមពីរពីលើមកទៀត ដូច្នេះបានន័យថា អ្នកមុនហ្នឹងត្រូវបញ្ជូនមកភ្នំពេញ អត់បានត្រឡប់ទៅវិញទេ។ នោះដូចខ្ញុំបានសម្ភាសខាងដើម ហើយជម្រាបខាងកាលពីទី១ ហ្នឹងហើយទី១មកនុ៎ង ដែលបាននៅក្នុងឯកសារហ្នឹង។ ហ្នឹងដូចពាក្យដែលខ្ញុំនិយាយអ៊ីចឹង ព្រោះថាក្នុងហ្នឹងវាបានទៅប្ដូរកងពលក៏ប្ដូរ វរសេនាធំមួយចំនួនក៏ដំឡើងបន្ថែម ហើយស្រុក មានលេខាស្រុកក្រចេះទៅមួយ ស្នួលព្រោះយួនយកបានទាំងមូលហើយ អត់មានបានស្រុកស្នួលបន្ថែមកម្មា-ភិបាលគណៈស្រុកទៅទៀតទេ។ តំបន់យក បងភាព កងវរសេនាធំហ្នឹងយកទៅលេខាតំបន់ យក ពូផុនហៅ ទី នោះយកមកធ្វើជាអនុលេខាតំបន់៥០៥ ដែលមុនយួនចូលនេះ ហ្នឹងដែលខ្ញុំដឹង ដែលខ្ញុំនៅទីហ្នឹងផ្ទាល់ ដែលពេលហ្នឹង។ ដូច្នេះអត់មានបានត្រឡប់ទៅវិញទេក្នុងចំនួនហ្នឹង ហើយក៏អត់មានបាននៅរស់ទៀតដែរ។ ព្រោះត្រូវបញ្ចប់ ព្រោះដល់ហើយយួនបុកភ្លាមមក ត្រូវបាត់ខ្លួនទាំងអស់តែម្ដង។ នេះខ្ញុំបានបញ្ជាក់ខាងមុននោះរួចហើយ។

[០៩:១០:៥៤]

**ស៖** តើមានអ្នកណាម្នាក់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ឬកម្មាភិបាលខ្មែរក្រហមណាម្នាក់ប្រាប់លោកថា មានអ្វីកើតឡើងទៅដល់អ្នកទាំងនោះដែរ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមក?

**ឆ៖** បញ្ហាហ្នឹងដូចខ្ញុំបានជម្រាបអ៊ីចឹង បើមកដល់ហ្នឹងហើយ គឺមិនបានត្រឡប់ទៅវិញទេ បានដឹងថា ព្រោះនៅក្នុងនុ៎ងវាមានអ្នកទៅជួរថ្មីនេះ ដូចជាមានគណៈតំបន់ថ្មី កងពលថ្មីដែលទៅនេះ បានគាត់បាននិយាយ ថាមេឯងក្បត់អស់ហើយ។ ហ្នឹងដែលបានពួកខ្ញុំឆោឡោ ពេលយួនបុកមកដល់ហ្នឹងគឺច្របូក

01329771



ច្របល់ពេលហ្នឹង លែងទុកចិត្តគ្នាទាំងអស់។ កម្លាំងខ្ញុំដែលជុំវិញកងពលមួយចំនួនដឹកសម្ភារៈទៅស្ទឹងត្រែងត្រូវយួនបុកហើយ ហ្នឹងដូចខ្ញុំបានជម្រាបអ៊ីចឹង។ ហើយកម្លាំងខ្ញុំដែលធំៗត្រូវវៀយួនកើត ត្រូវមកទប់នៅខាងៗៗព្រៃកទេវវិញហើយ។ ដល់អ៊ីចឹងទៅ ត្រូវទទួលគ្រោះថ្នាក់ហ្នឹងវាត្រូវធ្លាក់ទឹកទន្លេខ្លះ រត់ប្រសេចប្រសាចអ៊ីចឹងទៅ ចប់ត្រឹមហ្នឹង។ ហ្នឹងអ្នកដែលប្ដូរថ្មី អ្នកដូចជា បងញ៉ាន់ គាត់ស្លាប់ហើយ ពូផុន ហ្នឹងប្រហែលជាដឹងគាត់រស់ ដឹងគាត់ស្លាប់ ព្រោះគាត់នៅអន្លង់វែងជាមួយ បងញ៉ាន់ នុ៎ង។ នេះដែលខ្ញុំបានបញ្ជាក់ខាងដើមហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមសួរសំណួរជាក់លាក់មួយចំនួន។ ខ្ញុំសូមឲ្យលោកផ្ដោតការយកចិត្តទុកដាក់ បើធ្វើទៅបានគឺ ពាក់ព័ន្ធទៅនឹងម្សិលមិញនេះដែលខ្ញុំបានបង្ហាញនូវឯកសារពីស-២១ទៅឲ្យលោកមើល។ ហើយព្រឹកនេះ ក៏ខ្ញុំចង់បង្ហាញនូវបញ្ជីអ្នកទោសខ្លះដែលត្រូវបានធ្វើឡើងដែលជាឯកសាររបស់ស-២១ គឺអ្នកទោសដែលបានចូលមកស-២១ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោកប្រធានគឺនេះឯកសារ<E393.2> ជាបញ្ជីអ្នកទោសរួម<ចងក្រងដោយការិយាល័យសហថៅក្រមស៊ើបអង្កេត>។ ហើយលោកសាក្សី ខ្ញុំចង់ឲ្យលោក<ផ្ដល់យោបល់ទៅលើ>អត្តសញ្ញាណរបស់អ្នកទោសប្រាំមួយនាក់ <ដែលយើងនឹងមើលនៅក្នុងឯកសារនេះ>។ ទី១ យើងខ្ញុំក៏សូមបញ្ចាំងបញ្ជីអ្នកទោសនេះនៅលើអេក្រង់ផង ហើយពង្រីកឲ្យបានធំបន្តិច ដើម្បីឲ្យសាក្សីអាចនឹងអានឈ្មោះអ្នកទោសទាំងនេះជាភាសាខ្មែរទៅបាន បើអង្គជំនុំជម្រះអនុញ្ញាត។

[០៩:១៣:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ហើយលោក សុន អរុណ អាចជួយប្រាប់គាត់ផង អានបញ្ជាក់ប្រាប់គាត់ឲ្យច្បាស់ពីឈ្មោះដែលពាក់ព័ន្ធទៅនឹងការសហព្រះរាជអាជ្ញារងនឹងសួរ។

**សួរដោយលោក វីណ្ណៀម ស្មីត៖**

**ស៖** សូមអរគុណលោកប្រធាន។ ឈ្មោះទី១ ដែលខ្ញុំចង់សួរគឺអ្នកទោសលេខរៀង៧.៨៦២ ខ្ញុំសូមឲ្យសហការីរបស់ខ្ញុំអានឈ្មោះជាភាសាខ្មែរនេះ។

**កញ្ញា សុង ឆវ័ន្ត៖**

ឈ្មោះ រ័ត្ន លាង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី សំណួររបស់ខ្ញុំដូចលោកបានឃើញនៅក្នុងកំណត់ត្រានេះហើយ គឺថាអ្នកទោសនេះគឺ ភេទ<ប្រុស> អាយុ៣០ឆ្នាំ ជាអនុលេខាកងពល១១៧។ <ឯកសារនេះបញ្ជាក់ថា គាត់ត្រូវបានចាប់មកពីកងពល១១៧ ហើយ>គាត់បានចូលមកស-២១ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ៧៨។ តើលោកស្គាល់ឈ្មោះម្នាក់នេះទេ?

[០៩:១៥:១០]

**ឆ៖** បាទ ឈ្មោះហ្នឹងស្គាល់បាទ។

**ស៖** ហើយតើបុគ្គលដែលលោកស្គាល់នេះ គឺជាមនុស្សម្នាក់ដែលគេបញ្ជូនមកភ្នំពេញតាមកាណូត មុននឹងគេបញ្ជូនយន្តហោះទៅដឹកកម្មាភិបាលដទៃទៀត អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ហើយឈ្មោះបន្ទាប់មកទៀតនេះ លេខរៀង១០៣៩៧ ហើយក៏សូមឲ្យសហការីរបស់ខ្ញុំអានឈ្មោះជាភាសាខ្មែរ និងសូមបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រផងដែរ។

**កញ្ញា សុង ឆវ័ន្ត៖**

ឈ្មោះ ឈឹម ខុន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ខ្ញុំនឹងអានព័ត៌មានលម្អិតនៅក្នុងបញ្ជីអ្នកទោស នៅពេលដែលបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រហើយ។ មានការកត់ត្រាថា ឈឹម ខុន នេះគឺភេទប្រុស អាយុ២៤ឆ្នាំ ហើយក៏មានកំណត់ត្រាពីតួនាទីរបស់គាត់ជាអនុលេខាតំបន់៥០៥ផងដែរ។ <គាត់ត្រូវបានចាប់មកពីតំបន់៥០៥>។ ហើយនិយាយថាថ្ងៃដែលគាត់ចូលមកស-២១ហ្នឹង គឺថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៨។ សំណួរដំបូងរបស់ខ្ញុំ តើលោកស្គាល់បុគ្គលម្នាក់នេះទេ?

[០៩:១៦:៥០]

**2-TCW-1005៖**

**ឆ៖** ស្គាល់បាទ អនុប្រធានតំបន់ ប្រពន្ធគាត់ឈ្មោះ វ៉ា។

**ស៖** ហើយតើបុគ្គលម្នាក់នេះ ជាបុគ្គលម្នាក់ដែលលោកកំណត់អត្តសញ្ញាណ លោកស្គាល់ថាត្រូវបានគេបញ្ជូន<>ដឹកតាមយន្តហោះមកភ្នំពេញ ពីក្រចេះមកភ្នំពេញ<តាមបញ្ជារបស់៨៧០> ដែល

លោកលើកឡើងកាលពីម្សិលមិញនោះមែនឬទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! ភាគីឆ្លើយ!

**2-TCW-1005៖**

**ឆ៖** ពិតប្រាកដហើយបាទ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ខ្ញុំក៏សូមសួរអ្នកទោសម្នាក់ទៀតផងដែរ គឺអ្នកទោសលេខរៀង<១៣៣៩៦> ហើយក៏សូមឲ្យសហការីរបស់ខ្ញុំហ្នឹង អានឈ្មោះរបស់បុគ្គលម្នាក់នេះផងដែរ។

**កញ្ញា សុង ឆវ័ន្ត៖**

ឈ្មោះ មាស មឿន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សូមកែតម្រូវ គឺលេខរៀង១៣.៣៩៦ ឈ្មោះ មាស មឿន។ ហើយនៅក្នុងកំណត់ត្រានេះថា មាស មឿន គឺភេទប្រុស មានអាយុ៣២ឆ្នាំ ហើយគាត់ជាលេខាតំបន់៥០៥។ គាត់<ត្រូវបាន>ចាប់ខ្លួននៅតំបន់៥០៥ ហើយបញ្ជូនមកស-២១ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៨។ សំណួរដំបូងរបស់ខ្ញុំ សួរថា តើលោកស្គាល់បុគ្គលម្នាក់នេះទេ?

[០៩:១៨:៣៨]

**2-TCW-1005៖**

**ឆ៖** បាទ បញ្ហាហ្នឹងពិតប្រាកដមែន ដូចដែលលោកព្រះរាជអាជ្ញាបានលើក ព្រោះគាត់ជាលេខាតំបន់។

**ស៖** តើ មាស មឿន នេះជាបុគ្គលម្នាក់ដែលលោកបានលើកឡើងពីម្សិលមិញ ថាត្រូវបានគេដឹកតាមយន្តហោះមកភ្នំពេញ តាមរយៈបញ្ជារបស់មន្ទីរ៨៧០នោះមែនទេ?

**ឆ៖** បញ្ហាទាំងអស់ ខ្ញុំវាអត់បានចាំថ្ងៃទីទេ។ តែដោយឡែក ចង់និយាយថា គាត់ដែលឈ្មោះដែលមកហ្នឹង ចំនួនដែលខ្ញុំរាប់ហ្នឹង វា១ឃើញពិតចូលក្នុងនុ៎ងហើយ តែគ្រាន់ថាក្នុងហ្នឹង ព្រោះបញ្ជើជូនមក បញ្ជូនមកតែកងពលទេ ឈ្មោះកងពល បានខ្ញុំជូនទៅកងពលទៅ តែដល់ពេលក្នុងហ្នឹង ត្រូវ១ខ្ញុំវាបានមេចេញទៅផុតហើយ ខ្ញុំដើរលេងទៅ វាអត់បានចាប់អារម្មណ៍បញ្ហាលម្អិតទៀត ព្រះរាជអាជ្ញា។

បញ្ហាហ្នឹង តែឈ្មោះក្នុងហ្នឹង ចូលក្នុងបញ្ជីអ្នកដែលខ្ញុំបានជម្រាបហ្នឹងហើយ។

**ស៖** តើលោកស្គាល់ មាស មឿន នេះច្បាស់ប៉ុនណាដែរ? តើលោកធ្លាប់និយាយប្រាស្រ័យទាក់ទងជាមួយនឹងគាត់នេះញឹកញាប់ទេ<នៅតំបន់៥០៥>?

[០៩:២០:០០]

**ឆ៖** ព្រោះខ្ញុំ ធម្មតាគាត់ហ្នឹងជាលេខាតំបន់ ខ្ញុំមិនអាចទាក់ទងគាត់ញឹកញាប់ តែគ្រាន់មន្ទីរគាត់ខ្ញុំធ្លាប់ចេញចូល ត្រង់ថាឥឡូវមានភ្ញៀវ ឬក៏មានបញ្ហាអីដែលក្នុងអង្គភាពខ្ញុំត្រូវទាក់ទងគាត់ អាចទំនាក់ទំនង ព្រោះនៅកន្លែងជិតគ្នា ខ្ញុំនៅខាងជើងគាត់ប្រហែលជា២០០ម៉ែត្រទេ ៣០០ម៉ែត្រចុះ នៅឯស្ពានក្រគរហ្នឹង ហើយនិងកន្លែងមន្ទីរគាត់នៅកណ្ដាលក្រុងក្រចេះហ្នឹង កាលជំនាន់នោះ។ ហើយការប្រាស្រ័យទាក់ទងគ្នា អាចវាជិតដែរ ព្រោះគាត់អ្នកស្រុកកំណើតនៅកំពត។ ហើយពីដើមចេញពីមុនគាត់ទៅក្រចេះនេះ គឺគាត់ជាប្រធានវរសេនាធំនៅខាងអង្គរបុរី។ ដល់អ៊ីចឹងកាលពីជំនាន់នោះ ក៏ខ្ញុំអាចស្គាល់ដែរ ព្រោះអ្នកកំពត តាកែវជំនាន់នោះ ខ្ញុំអាចជិតដិតច្រើនដែរ ព្រោះបាទ អាហ្នឹងដែលខ្ញុំធ្លាប់ស្គាល់គាត់ណា។ ដល់ទៅហ្នឹងនោះ គ្រាន់តែស្គាល់ជារាប់អាន ជាពូខ្ញុំអីអ៊ីចឹង គាត់ធ្លាប់នៅទទួលបងរុធ ជាមួយគ្នាតាំងពី១នេះទៅ ពីស្រុកកំណើតទៅណា។ រឿងហ្នឹងវាអាច បញ្ហាហ្នឹងវាលម្អិតច្រើនដែរ។ តែគ្រាន់ដល់ពេលគាត់ទៅនោះទៅគាត់ ខ្ញុំវាមិនបានទំនាក់ទំនងអីជិតដិតទេ ព្រោះការងារគាត់ផ្សេង ខ្ញុំវាផ្សេងអ៊ីចឹងទៅ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់។ តើលោកមានបានឃើញឈ្មោះរបស់គាត់នៅក្នុងបញ្ជីមនុស្សទាំង១១នាក់នេះដែរទេ? បើលោកចាំថា លោកឃើញឈ្មោះគាត់នៅក្នុងបញ្ជីទាំង១១នាក់នេះ ក៏ឆ្លើយថាចាំ បើមិនឃើញទេ ក៏ឆ្លើយថាមិនបានឃើញឈ្មោះគាត់ទេ។

**ឆ៖** បាទ ឈ្មោះបានឃើញហើយបាទ ត្រឹមត្រូវ។

**ស៖** តើលោកនៅចាំទេថា លោកនេះបានជូនដំណើរគាត់ឲ្យទៅជិះយន្តហោះហ្នឹង ឬក៏អត់ទេ?

[០៩:២១:៥៧]

**ឆ៖** បើដំណើរខ្ញុំទៅមានតែ ពូរុំអី, បងយ៉េងអី, បងភ័នអី អាហ្នឹងគាត់ជិះទៅជាមួយគ្នាអាហ្នឹង កាលហ្នឹងខ្ញុំគ្រាន់តែជូនដំណើរ អត់បានចូលដល់ព្រលានទៀត ខ្ញុំនៅត្រឹមកុងត្រូលខាងក្រៅ ហើយខ្ញុំត្រឡប់មកវិញ។ ដល់អ៊ីចឹងវាទៅ ដូចថាទៅ វាដំណើរខាងតំបន់គាត់ទៅផ្សេង មិនផ្សេងអីអាហ្នឹងជាក់ស្ដែង ខ្ញុំបញ្ហាហ្នឹងដូចថាបានមេទៅប្រជុំអ៊ីចឹង សប្បាយណាស់ ខាងខ្ញុំៗនិយាយជំនាន់កាលខ្ញុំនៅក្មេង។

01329775



ដល់បានមេទៅផុតអ៊ីចឹង នឹងអាល ទោះបីសភាពការណ៍ឃ្លួនបុកយ៉ាងណាក៏ដោយ ចង់តែដើរលេង។ អាងបានមេចេញផុតបន្តិចទៅ អាងចេញដើរលេង ដល់អ៊ីចឹងទៅ វាបញ្ហាចាប់អារម្មណ៍ បញ្ហាហ្នឹងអត់ទេ ប៉ុនដល់មកពេលបាត់ ហើយដល់ពេលគេមកដូរក្រោយនេះ បានភ្ញាក់ខ្លួន។ អាហ្នឹងចង់និយាយជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់អ៊ីចឹងចុះ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបង្ហាញកំណត់ត្រាមួយទៀតគឺ អ្នកទោសលេខរៀង ៤០៣២ គឺលេខរៀង៤០៣២ ហើយក៏សូមឲ្យសហការីរបស់ខ្ញុំអានឈ្មោះរបស់បុគ្គលម្នាក់នេះ ខ្ញុំនឹងរៀបរាប់ព័ត៌មានលម្អិតបន្ថែមតាមក្រោយ។

**កញ្ញា សុង ឆវ័ន្តៈ**

ឈ្មោះ ឃុន រុំ។

**សួរដោយលោក វីល្លៀម ស្មីតៈ**

**ស៖** បុគ្គលម្នាក់នេះគឺមានភេទប្រុស អាយុ២៤ឆ្នាំ ហើយជាលេខាកងពល១១៧ ហើយបានចូលមកស-២១នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៨ដែរ។ តើបុគ្គលម្នាក់នេះដែលជាពូរបស់លោកហ្នឹងឬ ដែលលោកថាជាពូរបស់លោកហ្នឹង មែន ឬអត់ទេ?

[០៩:២៣:៣៦]

2-TCW-1005

**ឆ៖** ឈ្មោះហ្នឹងបែបអាច។ បាទ ឈ្មោះហ្នឹងឈ្មោះពិតប្រាកដហើយបាទ។

**ស៖** ហើយលោកបានជូនដំណើរគាត់មកជិះយន្តហោះនៅថ្ងៃនោះ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** អ្នកទោសបន្ទាប់នោះ គឺលេខរៀង១២៩០៣ ហើយក៏សូមឲ្យសហការីរបស់ខ្ញុំអានឈ្មោះផងដែរ។

**កញ្ញា សុង ឆវ័ន្តៈ**

ឈ្មោះ ហួន យ៉េង។

**សួរដោយលោក វីល្លៀម ស្មីតៈ**

**ស៖** បុគ្គលម្នាក់នេះ គឺថាមានភេទប្រុស អាយុ២៩ឆ្នាំ ជាលេខាស្រុកក្រចេះ តំបន់៥០៥ ភូមិភាគ<ព្លិសាន> បានចូលមកស-២១នៅថ្ងៃទី<១២ ខែធ្នូ ឆ្នាំ១៩៧៨> និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨

<>ត្រូវបានសម្លាប់នៅស-២១។ តើបុគ្គលម្នាក់នេះ ជាមនុស្សដែលលោកលើកឈ្មោះឡើងពីម្សិលមិញក៏ដូចជាថ្ងៃនេះ ដែលថាត្រូវបានគេដឹកតាមយន្តហោះមកភ្នំពេញនោះមែនទេ?

**2-TCW-1005៖**

**ឆ៖** បាទ ឈ្មោះហ្នឹងឈ្មោះពិតប្រាកដហើយ។ តែដោយឡែកខ្ញុំចង់បញ្ជាក់ព្រះរាជអាជ្ញាអ៊ីចេះ ចង់និយាយថា មកក្នុងចំណោមទាំងអស់ ហើយដែលក្នុងចំណោមនេះ ជូនចូលស-២១មុន ជូនមកកំពង់ឆ្នាំងមុន ក៏មានដែរ ព្រោះឈ្មោះតាមខ្ញុំដឹងដែលចំនួនមកនោះណ៎ា ដែលចំនួនមកក្នុង១១នាក់ហ្នឹង មុនក្រោយមែនក៏ពិតមែន តែជូនឈ្មោះនុ៎ង មិនមែនចូលស-២១ទាំងអស់ទេ។ តែដល់មកថាឈ្មោះក្នុងនេះ ព្រោះខ្ញុំថាមានខ្លះបញ្ជូនមកកំពង់ឆ្នាំង ព្រលានកំពង់ឆ្នាំង។ នេះដែលខ្ញុំដឹងតាមដែលអ្នកធ្លាប់ ធម្មតាសារទូរលេខ អាចនិយាយទាក់ទងគ្នាតាមដៃហ្នឹងខ្លះដែរ សួរគ្នាថា អ៎! ឥឡូវម៉េចហើយ គាត់ទៅយ៉ាងណាសុខទុក្ខយ៉ាងណា។ ទាក់ទងអ៊ីចឹងទៅ សួរទៅ អ៎! ខាង៥០២ គេបញ្ជូនមកថា អ៎! ជាប់គុកអស់ហើយ អ៊ីចេះៗ ហ្នឹងគ្រាន់បាននិយាយទាក់ទងគ្នា បាននឹងដៃទេ កាលជំនាន់នោះ មិនមានអីឥឡូវ ដូចឥឡូវទេ។ ហ្នឹងឈ្មោះពិតប្រាកដហើយ តែមិនមែនគាត់មកពីបូព៌ាទេ យ៉េង គឺទៅពី១១៧ទៅដូចគ្នា ចេញពីលង្វែកទៅដូចគ្នាទេ។ នេះដែលខ្ញុំជម្រាបព្រះរាជអាជ្ញា ហ្នឹងដែលឈ្មោះដូចខ្ញុំបានឃើញអម្បាញ់មិញនេះ គឺឈ្មោះពិត។ អ៊ីចឹងបានថា ចូលមុន ចូលក្រោយ អាហ្នឹងវា ព្រោះតាមខ្ញុំដឹង សភាពការណ៍ថ្ងៃទី០១ខែធ្នូនេះ ថ្ងៃទីមុន ថ្ងៃទី១នោះ សភាពការណ៍វាតឹងតែង ដល់អ៊ីចឹងទៅ អាពេលហ្នឹង មុនក្រោយគ្នាហើយ ព្រោះមក មុនក្រោយគ្នា ត្រង់អ្នកក្រោយ គឺត្រូវតាមយន្តហោះ អ្នកមុនហ្នឹង អាចចូលត្រង់ណាត្រង់ណីព្រោះសភាពការណ៍វាបុកខ្លាំង មិនដឹងអ្នកណាទប់ណា លែងទុកចិត្តគ្នាហើយហ្នឹង ដូចថា ដូចវាធ្ងន់ធ្ងរ។ កុំតែបានផ្ដាច់ព្រែកទេរទាន់ រថក្រោះមកដល់ក្រចេះតាំងមុន តាំងពីខែ១១ម្ល៉េះ មកដល់ព្រែកទេររថក្រោះឆ្លងមកអត់កើត។ អ៊ីចឹងជម្រាបព្រះរាជអាជ្ញាត្រង់ អាហ្នឹងបញ្ហាហ្នឹងរឿងពិត ដែលមានឈ្មោះប៉ុន្មានអំមិញ រាប់អំមិញទើបតែបានប្រាំ។ សូមអរគុណ។

[០៩:២៧:០៨]

**ស៖** សូមអរគុណ។ ខ្ញុំនៅសល់តែឈ្មោះម្នាក់ទៀតទេ ចុងក្រោយគឺលេខរៀង១២.៩០៤ ហើយក៏សូមឲ្យសហការីរបស់ខ្ញុំអានឈ្មោះបុគ្គលនេះផងដែរ។

**កញ្ញា សុង ឆវ័ន្ត៖**

ឈ្មោះ ឈុំ ចិន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** អ្នកទោសម្នាក់នេះគឺ ឈុំ ចិន នេះ ត្រូវបានគេកត់ត្រាថា មានភេទប្រុស អាយុ២៦ឆ្នាំ ជាលេខាស្រុកស្នួល តំបន់៥០៥ ភូមិភាគឦសាន ហើយត្រូវបានចូលមកស-២១ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ៧៨ ហើយក៏បានកត់ត្រាថា បានសម្លាប់ចោលនៅថ្ងៃទី<៣១> ខែធ្នូ ឆ្នាំ១៩៧៨នេះ។ តើលោកស្គាល់បុគ្គលម្នាក់នេះទេ? ហើយបើស្គាល់ តើបុគ្គលម្នាក់នេះគឺជាមនុស្សម្នាក់ដែលលោកថាត្រូវបានគេដឹកតាមយន្តហោះពីក្រចេះមកភ្នំពេញ កាលពីម្សិលមិញនោះមែនទេ?

**2-TCW-1005៖**

**ឆ៖** បាទ ឈ្មោះនេះ គឺជាឈ្មោះពិតរបស់ពូខ្ញុំហើយ ព្រោះ ឈុំ ចិន ហៅ ភ័ន ដែលនៅស្រុកស្នួលនុ៎ង ពូខ្ញុំបង្កើតដែលត្រូវពួកម៉ាក ពូរុំ – ឃឹម រុំ, រុំនេះ។ គាត់នៅជាមួយគ្នា តាំងពីឆ្នាំ៧១, ៧២មកម្ល៉េះ។ ដល់អ៊ីចឹងគាត់មកហ្នឹង បានជាគាត់អូសសណ្ដោងខ្ញុំមកតាមនេះ បានខ្ញុំមកនៅនេះ ពូខ្ញុំបង្កើតហើយណ៎ា ប្អូនឪខ្ញុំ ឪខ្ញុំឈ្មោះ ឈុំ ជី ពូខ្ញុំនេះឈ្មោះ ឈុំ ចិន។ ហ្នឹងពូខ្ញុំបង្កើត។ មកជាមួយគ្នា ជាមួយពូរុំ ហ្នឹងហើយ តែគ្រាន់ដល់មកដល់នេះហើយ មកដល់ភ្នំពេញនេះអាចចូលមុន ចូលក្រោយ។ អាហ្នឹងជាក់ស្ដែងអាហ្នឹង ប៉ុន្តែមកពីនោះគឺមកចំនួនហ្នឹងហើយ។ បាទ រឿងហ្នឹង បាទរឿងពិត។ អរគុណព្រះរាជអាជ្ញា។

[០៩:២៩:១០]

**ស៖** បាទ មិនថ្វីទេលោក មិនបាច់ចាំថា ពួកគាត់ចូលមកស-២១ ថ្ងៃណា ខែណានោះទេ។ តាមរយៈកំណត់ត្រាឈ្មោះអ្នកទោសទាំងនេះ គឺវាបង្ហាញឱ្យឃើញថា អ្នកទាំងអស់នេះ ពិតជាបានចូលមកស-២១ តាមកាលបរិច្ឆេទដែលកត់ត្រា។ ដូចជាឈ្មោះ លាង ចូលមកថ្ងៃទី០១ ខែធ្នូ ៧៨។ ខុន ចូលមកថ្ងៃទី០២ ខែធ្នូ ៧៨។ មឿន ហើយ <រុំ> ចូលនៅថ្ងៃទី០៨ ខែធ្នូ។ ហើយ យ៉េង ហើយនិង <ភ័ន គឺ> ឈុំ ចិន ហ្នឹងគឺចូលមកស-២១ នៅថ្ងៃទី១២ ខែធ្នូ។ គឺអ្នកទាំងអស់នេះ ចូលមកនូវកាលបរិច្ឆេទខុសៗគ្នា។ សំណួររបស់ខ្ញុំចង់សួរលោក ថាតើអាចទេដែលថា អ្នកទាំងអស់នេះ ត្រូវបានគេដឹកពីក្រចេះមកភ្នំពេញ ក៏មិនដឹកមកជើងជាមួយគ្នាដែរ អាចដឹកមកនៅថ្ងៃខុសគ្នា អាចអ៊ីចឹងដែរទេ?

**ឆ៖** បាទ បើតាមខ្ញុំដឹង ពូចិន ហ្នឹងហើយនិង ពូរុំ ហ្នឹងគាត់មកជាមួយគ្នាហើយ។ តែដោយឡែកចូលមុន ចូលក្រោយ បើតាមដែលដឹងផ្អើលខាងពួកខ្ញុំ មន្ទីរហ្នឹងផ្អើលហ្នឹង ដែលផ្អើលហ្នឹងដល់ពេលចុងកន្ទុយហើយនេះ ដែលថាក្បត់នេះ ខាងខ្ញុំថាក្បត់នេះ បាននាំគ្នាមកពីស្ទឹងត្រែងវិញ បានថា ខ្ញុំ

មកពីមណ្ឌលគិរីវិញ ដល់ខាង អ៊ំញ៉ាន់ នេះគាត់ទៅដូរហ្នឹង វាមិនបានចាប់អារម្មណ៍ថាមកដូរទេ។ ដំបូងទៅដល់ ថារួមគ្នាវ៉ៃសិន ដល់តែពេលខ្ញុំទៅពីរយប់ មកវិញ បានថាមេខ្ញុំទាំងអស់ក្បត់នេះ បាននាំគ្នាឆោឡោហ្នឹង។ ការពិតយកទៅអាចមុនអាចក្រោយហ្នឹងឯង សភាពការណ៍វាកៀកមែនទែនហើយ ដល់អ៊ីចឹងទើបដឹងក្រោយដែរហើយទេ។ គ្រាន់តែអាចមុន អាចក្រោយ បើ បងលាង ដឹងមកមុនហើយព្រោះ បងលាង មកមុនគេ បានក្រោយមកហ្នឹង បើខ្ញុំដឹង ដឹងតែ ពូរុំ ហើយ ពូផន, ពូចិន ហ្នឹងមកជាមួយគ្នា ព្រោះជិះឡានមកជាមួយគ្នា។ បាទ មានប៉ុណ្ណឹង។

[០៩:៣១:៣២]

**ស៖** យើងមានចម្លើយពីសាក្សីមួយរូបផ្សេងទៀតនៅក្នុងសំណុំរឿងនេះ គឺខ្ញុំមិននិយាយឲ្យចំឈ្មោះសាក្សីទេ។ ខ្ញុំយោងទៅលើឯកសារ E3/10628 ERNអង់គ្លេស 01142606, ខ្មែរ01127710។ លោកប្រធាន យើងខ្ញុំក៏សូមការអនុញ្ញាតបង្ហាញចម្លើយរបស់សាក្សីនេះ ទៅឲ្យសាក្សីរូបនេះមើល។ ដើម្បីឲ្យសាក្សីរូបនេះមើលឃើញបានច្បាស់នោះ គឺថាខ្ញុំក៏មានដាក់*ហាយឡាយ* នៅក្នុងឯកសារនេះផងដែរ។ <ហើយឈ្មោះរបស់សាក្សីដែលបានផ្ដល់ចម្លើយនេះ ក៏ឃើញមាននៅក្នុងឯកសារនេះដែរ ដូច្នេះសាក្សីនេះដឹងថា នរណាជាអ្នកផ្ដល់ចម្លើយនេះ។ តើអាចបង្ហាញសាក្សីបានទេ ហើយបន្ទាប់មកខ្ញុំនឹងសួរគាត់។>

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគ្រាន់តែជាការកត់សម្គាល់ទេ។ ខ្ញុំយល់ឃើញថា <>សាក្សីរូបនេះ<ស្គាល់>ឈ្មោះសាក្សីដែលលើកមកសួរ<នោះ ជា>ឈ្មោះក្រៅ។ <ដូច្នេះ ខ្ញុំមិនគិតថានឹងមានហានិភ័យណាមួយបញ្ជាក់នៅក្នុងតុលាការពីការហៅឈ្មោះក្រៅរបស់សាក្សីនោះទេ។ ហើយខ្ញុំគិតថា សាក្សីនេះមិនស្គាល់>ឈ្មោះពិតប្រាកដរបស់<សាក្សីដែលលើក>មក<សួរនោះ>ទេ គឺ<ស្គាល់>តែរហស្សនាម<> ឬ<>ឈ្មោះបដិវត្តន៍<របស់គាត់តែប៉ុណ្ណោះ>។

**លោក វីល្លៀម ស្មីត៖**

ទោះយ៉ាងណាក៏ដោយ ខ្ញុំថា មិនចង់ឲ្យបង្ហាញតែឈ្មោះបដិវត្តន៍អីដូចស្នើសុំនោះទេ សុំបង្ហាញឈ្មោះចំរបស់គាត់ឲ្យសាក្សីមើលតែម្ដង។

[០៩:៣៣:១៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំថា ស្នើសុំឲ្យសាក្សីរូបនេះ សួរឈ្មោះបដិវត្តន៍របស់គាត់ ឬក៏ឈ្មោះហៅក្រៅ ដូចជាមិនថ្វីទេ។

**លោក វីណ្ឌៀម ស្មីត៖**

អ៊ីចឹងលោកចង់និយាយពីឈ្មោះ ឧល ហ្នឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រូវហើយ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** បុគ្គលម្នាក់ដែលមានឈ្មោះ ឧល បានបញ្ជាក់ថា <> មឿន ហើយនិង រុំ បាន<ជិះយន្តហោះ>ចេញ<មក>ជាមួយ<គ្នា ហើយ យ៉េង និង ភ័ន បាន>ចាកចេញតាមយន្តហោះផ្សេង គឺឃ្លាតគ្នាពីរបីថ្ងៃ។ តើលោកអាចបញ្ជាក់បានទេថា តើលោកអាចបញ្ជាក់បានទេ ទៅលើអ្វីដែល ឧល និយាយនេះ?

**2-TCW-1005៖**

**ឆ៖** បាទ បញ្ហាបើបាន បងឧល គាត់និយាយអ៊ីចឹងមក កាន់តែច្បាស់ទៀត បាទ លោកព្រះរាជអាជ្ញា ព្រោះបង បងគាត់ ចង់និយាយ បងឧល គាត់ជាប្រធានមន្ទីរតំបន់នោះហើយ។ កិច្ចការអីទាំងអស់នៅក្នុងតំបន់នោះ គឺគាត់ទទួលខុសត្រូវរួមកាលពីជំនាន់នោះ។ បើបាន បងឧល គាត់និយាយមកច្បាស់លម្អិតជាងខ្ញុំទៅទៀត ព្រោះខ្ញុំវា កាលនោះវាជំនាន់នោះ ខ្ញុំវាត្រូវ ដូចថាវាត្រូវ ដូចថាមិនបានលម្អិតនៅក្នុងមន្ទីរដូចគាត់ទេ។ ជួនឡានត្រូវការដឹកគ្រាប់អី ដឹកអីៗអ៊ីចឹងទៅ ឬក៏នៅសារទូរលេខទៅ ខ្ញុំអត់បានចាំ និយាយរួមអត់បានចាប់អារម្មណ៍ដែរហ្នឹង បើបាន បងឧល ទៀត បងឧល អាចលម្អិតជាងខ្ញុំទៅទៀត ព្រោះ បងឧល គាត់បានទៅភ្នំពេញដែរតើ បានហើយគាត់ត្រឡប់មកវិញនេះ បានរឿងហ្នឹងបានផ្ទុះបញ្ហានេះ។ បានលោកព្រះរាជអាជ្ញានិយាយអ៊ីចឹងមកបានច្បាស់។ បាទ អរគុណហើយអ៊ីចឹង។ ខ្ញុំអរគុណលោកព្រះរាជអាជ្ញា។ ឈ្មោះពិតហើយគាត់។

[០៩:៣៥:២៥]

**ស៖** សូមអរគុណសាក្សី។ ប្រហែលជាខ្ញុំចង់សួរលោកអ៊ីចេះ។ តើលោកប្រាកដទេថាឈ្មោះទាំងប្រាំមួយនាក់ ដែលយើងបានពិភាក្សាកន្លងមកហ្នឹង គឺថាជាឈ្មោះមនុស្សប្រាំមួយនាក់ ដែលយើងពិភាក្សា ត្រូវបានបញ្ជូនមកភ្នំពេញ ដោយសារតែវាជាបញ្ហារបស់មន្ទីរ៨៧០ តើលោកច្បាស់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ក្នុងៗចំនួននេះ ខ្ញុំចង់និយាយថា ឈ្មោះបញ្ជូនទៅតែ ពូរុំ មួយទេ។ ឈ្មោះកាលហ្នឹងដែលខ្ញុំបានទទួលដែលនៅលើតុហ្នឹង គឺបានទទួលដឹងតែឈ្មោះ ពូរុំ ហ្នឹងមកដល់ហើយ ពូរុំ ហើយនិង ពូផននេះ, ពូចិន នេះមកជាមួយគ្នា។ អាហ្នឹងខ្ញុំដឹងណា។ ដូច្នេះបញ្ហាហ្នឹង ខ្ញុំដឹង ពូរុំ តែដល់វាបាត់ ត្រូវបាត់ខាងគណៈតំបន់នោះក៏បាត់ មានវរសេនាធំប៉ុន្មាននាក់ទៀតក៏បាត់។ មក អាចមកហ្នឹងជើងមុន ជើងក្រោយមែន តែដោយឡែកខ្ញុំបញ្ហាហ្នឹង ខ្ញុំវាមិនអាចលម្អិតទេ។ តែបើខាងតំបន់ សួរទៅខាង បងឌលគាត់អាចច្បាស់ជាងខ្ញុំ។ គ្រាន់ឈ្មោះៗពិតមែនហើយ។

**ស៖** សូមអរគុណ។ ក្រោយពីពួកគាត់ទាំងអស់ហ្នឹងត្រូវបានគេបញ្ជូនពីក្រចេះមកភ្នំពេញនោះទោះបីថាជិះយន្តហោះជាមួយគ្នា ឬក៏យន្តហោះផ្សេងគ្នាក៏ដោយ <ក្រោយពីរឿងនោះបានកើតឡើង> តើលោកធ្លាប់មានចូលរួមប្រជុំជាមួយ មាស មុត ទេ?

[០៩:៣៧:០៦]

**ឆ៖** បាទ បញ្ហានុ៎ងខ្ញុំបានបកស្រាយនៅសេចក្ដីសម្ភាសមុនហើយ។ ខ្ញុំបានប្រជុំជាមួយគាត់តែ១ថ្ងៃហ្នឹង គឺចង់និយាយថាគាត់ឲ្យកម្លាំងតូចៗនេះឲ្យដឹកសម្ភារៈទៅស្ទឹងត្រែង ព្រោះយួន សភាពការណ៍យួន វាបុកហើយ។ ដល់អ៊ីចឹងខ្ញុំត្រូវយកកម្លាំងដែលធំៗនៅជុំវិញមន្ទីរខ្ញុំ ដែលនីរសារទាំងអស់ និងពួកស្អីទាំងអស់នៅៗក្នុងមន្ទីរហ្នឹង ត្រូវបាន៧០នាក់ហ្នឹងមកទប់ខាងកើតព្រលានយន្តហោះ នៅម្តុំអូរដាកន្ទួតនេះ មកត្បូងដើម្បីទប់។ ដល់ទប់ទល់មុខ ពួកខ្ញុំក៏បាក់ រួមជាមួយកងទ័ពទាំងអស់ហ្នឹង ដែលខ្ញុំចេញពីមន្ទីរហ្នឹង។ គាត់បានប្រជុំហ្នឹង គាត់ថា ឥឡូវមេឯងក្បត់ហើយ អាធំៗទៅយួន អាតូចៗដឹកសម្ភារៈស្ទឹងត្រែង។ អាហ្នឹងបាន ប្រជុំមិនបានប្រហែលជាមិនដល់មួយម៉ោងផងទេ ព្រោះគាត់ប្រញាប់ប្រញាប់។ មកៗ ខ្ញុំហ្នឹងក៏ទៅប្រមូលគ្នាទៅវ៉ៃយួនទៅ។ ដល់អ៊ីចឹងបញ្ហាហ្នឹងបានៗដឹងៗបញ្ហាហ្នឹងពិត។ ខ្ញុំមានប៉ុណ្ណឹង។

**ស៖** តើ មាស មុត គាត់ចំណាយពេលប្រហែលប៉ុន្មានដែរ ក្នុងការថ្លែងនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** បញ្ហាហ្នឹង គាត់នៅប្រហែលជាមិនដល់មួយម៉ោងទេ ប៉ុន្តែខ្ញុំគិតថាមួយម៉ោងទៅចុះ ព្រោះនៅហៅប្រជុំជួរក្នុងមន្ទីរហ្នឹង ហៅទាំងពួក និយាយរួមនៅក្នុងមន្ទីរហ្នឹងទាំងអស់ គាត់ហៅប្រជុំហ្នឹងដើម្បីប្រកាសថា ឥឡូវគាត់ត្រូវដូរមេកងពល។ ហ្នឹងគាត់ហៅតែពួកក្រុមនីរសារ ពួកតែកុងឡាន ពួកហ្គារ៉ាសឡាន ពួកអីៗសម្រាប់នេះហ្នឹង ពេទ្យអីហ្នឹងមួយចំនួនហ្នឹង គាត់ហៅមកប្រជុំទាំងអស់។ និយាយរួមអ្នកនៅក្នុងមន្ទីរហ្នឹង។ ដល់អ៊ីចឹងគាត់ហៅប្រមូលគ្នាមក ថាឥឡូវមេត្រូវដូរហើយ មេអ្នែង

01329781



ក្បត់អស់ហើយ មេអ្នែងក្បត់អស់ហើយ ឥឡូវត្រូវដូរមក ឥឡូវ ញ៉ាន់ ឡើងមេបញ្ជាការប្រធានកងពល នេះ។ អ្ហ្ន! ឥឡូវរៀប។ ដល់អ៊ីចឹងទៅ ដឹងតែប៉ុណ្ណឹងទៅ ឮតែមេក្បត់ហើយ ខ្ញុំប្រមូលទ័ពទៅមុខទៅ។ ហើយកម្លាំងដែលនៅពួកតែកុងឡានអីមួយចំនួនត្រូវដឹកសម្ភារៈចេញពីហ្នឹងទៅស្ទឹងត្រែង ក៏ត្រូវទៅឆ្លង ស្ទឹងត្រែងទៅ។ អ៊ីចឹងមានប៉ុណ្ណឹង។ នៅរយៈពេលថាមិនដល់មួយម៉ោងចុះ ប៉ុន្តែគិតមួយម៉ោងទៅ។ គាត់ប្រជុំប្រកាសហើយ ក៏គាត់ប្រញិបប្រញាប់ចេញដំណើរមកទៀត។ បាទ ខ្ញុំមានប៉ុណ្ណឹង។

[០៩:៣៩:៥១]

**ស៖** តើ មាស មុត មានប្រាប់ទេ ហេតុអ្វីបានជាមេទាំងអស់ហ្នឹងក្បត់ទេ? តើ មាស មុត មាន ប្រាប់ថា ពួកគាត់ហ្នឹងធ្វើអ្វីខ្លះ ទើបគេចោទថាក្បត់ទេ? តើលោកចាំចំណុចទាំងអស់នេះទេ?

**ឆ៖** បាទ ខ្ញុំនៅចាំបានត្រង់ថា គាត់ចង់និយាយថា ខាងពួកខ្ញុំហ្នឹងអត់វៃយួនតែប៉ុណ្ណឹងទេ។ គាត់ អត់មាននិយាយអីសំខាន់ទេ គាត់គ្រាន់តែថា ពួកអ្នែងគ្រប់គ្នាអត់វៃយួនសោះ ឲ្យយួនបុកយកបានទាំង មូល។ គាត់ចង់និយាយថា គាត់ចង់និយាយហ្នឹង និយាយសំដៅថា ស្នួលបុកពីម៉ោងប្រាំមួយព្រឹក ម៉ោង ប្រាំបីយប់យួនយកស្នួលបានទាំងមូល។ ដល់អ៊ីចឹងគាត់ទៅជួយទប់ហ្នឹង បានន័យថា គាត់ថា មកពីពួកខ្ញុំ អត់វៃយួន ក៏ឲ្យយួនយកដីបាន។ ដល់អ៊ីចឹងទៅរឿងហ្នឹង ក៏ពួកខ្ញុំឮតែអ៊ីចឹង រឹតតែខឹងទៀត រឹតតែយកនាំ គ្នាទៅវៃយួនទៀតហើយ។ អាហ្នឹងរឿងហ្នឹង គាត់បាននិយាយតែប៉ុណ្ណឹង គាត់អត់មាននិយាយអីថែម ទៀតទេ និងប្រកាសកងពលថ្មីតែប៉ុណ្ណឹង។ បាទ ប្រជុំមានប៉ុននុ៎ង។

**ស៖** តើលោកយល់ស្របជាមួយនឹងអ្វីដែល មាស មុត និយាយហ្នឹងទេ? ថាក្នុងនាមលោកមក ពីកងពល<១១៧>ហ្នឹង លោកយល់ស្របទេថា កងពលរបស់លោកហ្នឹងមិនបានប្រឹងប្រែងវៃយួននុ៎ង ឬមួយក៏ថា លោកថា កងពលលោកហ្នឹង គឺប្រឹងប្រែងអស់សមត្ថភាពទៅហើយ?

[០៩:៤១:២៩]

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាអ៊ីចេះចុះ ជំនាន់នោះ មិនអាចប៊ានតវ៉ាបាន ត្រង់ ថា ស៊ូបានមិនបាន តែដោយខ្សែកក្នុងចិត្ត គឺដឹងហើយថាកម្លាំងគេធំជាង កាំភ្លើងគេទំនើបជាង កម្លាំង គេច្រើនជាង ដល់អ៊ីចឹងមិនអាចទេ។ គ្រាន់តែឮថា ឮអ៊ីចឹងមកមានកំហឹងមួយថា ត្រូវតែទៅទប់វាឲ្យ ជាប់។ អាហ្នឹងកាលពីជំនាន់នៅក្មេងទេណ៎ា។ ដល់អ៊ីចឹងត្រូវតែទៅ អស់ប៉ុន្មាន ចំណាយប៉ុន្មាន ចំណាយ ទៅឲ្យតែឈ្នះ ឲ្យទប់វិញបាន ប៉ុន្តែទប់វាមិនជាប់ ចុងបំផុត នៅតែធ្លាក់ទឹកទន្លេដដែល។ អាហ្នឹងខ្ញុំចង់ និយាយជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់អ៊ីចឹងចុះ។

**ស៖** អ៊ីចឹងលោកចង់និយាយថា លោកមិនយល់ស្របជាមួយនឹងអ្វីដែល មាស មុត លើកឡើងទេ គឺថាលោក កងពលលោកប្រឹងប្រែងវើអស់លទ្ធភាពហើយ អ៊ីចឹងមែនទេ?

**ឆ៖** និយាយ បាទ និយាយរួមមួយម៉ាត់ទៅ អ៊ីចេះកាលជំនាន់នោះ គឺមិនមែនថាហ៊ានប្រឆាំងអីទេ គ្រាន់ថាកម្លាំងហ្នឹង កម្លាំងខ្ញុំ ពួកខាងកងហ្នឹងវាខំប្រឹងប្រែងហើយ។ តែដោយឡែកមានកំហឹងមួយកំហឹងថា ត្រូវតែចង់វើយកឲ្យឈ្នះវិញបាននោះ តែវារត់វាមិនរួច ទៅវាមិនរួចហ្នឹង។ មិនមែនថា អ្អូ!ខឹងគាត់បញ្ជាឲ្យអ៊ីចេះអ៊ីចុះទេ កាលនុ៎ងវាមិនបានគិតអីដល់ដំណាក់កាលអ៊ីចឹងទេ។ ជំនាន់នោះឲ្យតែឮថាដូចថា យើងបង្រៀនជំនាន់នោះ បង្រៀនឲ្យដាច់ខាត ស្មោះត្រង់អីអ៊ីចឹងទៅណ៎។ ដល់ពេលឮថា យួនលេបទឹកដី ម្នាក់ៗដាច់ខាតហើយត្រូវតែពុះពារទៅហើយ អាហ្នឹងចង់និយាយពិតទៅចុះ។ វាមិនដឹងដល់ដំណាក់កាលនេះ ឈានមកដល់សម្បូរសប្បាយអីចេះ អាហ្នឹងនិយាយរួម។ ជំនាន់នោះដឹងតែមួយច្រក។ ហ្នឹងនិយាយត្រង់ទៅ អត់មានគិតអីទេ គិតតែរឿងដល់ តោះ! នៅប៉ុន្មាននាក់ក៏វើដែរ ១០នាក់ ២០នាក់ក៏វើ។ មិនបានគិតដល់ដំណាក់កាល ដូចថា ការជួបប្រទះការអីយ៉ាងម៉េច អាហ្នឹងគឺអត់គិតទេ ជំនាន់នោះធ្វើម៉េចឲ្យតែ ប្រឹងប្រែងឲ្យតែបានទៅ ព្រោះបើសិនណាយើងមិនវើក៏ងាប់ វើក៏ងាប់ សុខចិត្តវើទៅ។ បើមកក្រោយវិញ ក៏គេនៅតែចាប់ដដែលហ្នឹង។ អាហ្នឹងចង់និយាយអ៊ីចឹង អាហ្នឹងការពិត អាហ្នឹងការយល់របស់ខ្ញុំ។ ដូចកម្លាំងខ្ញុំ៧០នាក់ដែលទៅហ្នឹង ទីចុងបំផុត នៅធ្លាក់ទឹកដដែលអ៊ីចឹងទៅ មិនមែនតែកម្លាំងខ្ញុំទេ កម្លាំងមួយរួមកងពលទាំងអស់ ទ័ពតំបន់ផង ទ័ពស្រុកផង នៅកម្លាំងពីគាត់យកមកជួយមួយវរសេនាធំទៀត ក៏ទៅនៅទប់មិនជាប់។ បាទ ខ្ញុំមានប៉ុណ្ណឹង។

[០៩:៤៤:១៥]

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរពីរបីតូចៗទៀត មុនពេលដែលសហការីខ្ញុំសួរបន្ត។ អ៊ីចឹងលោកគិតថា នៅពេលដែលមេរបស់លោកត្រូវបានគេចាប់ខ្លួន<នៅតំបន់៥០៥> ហើយកងពលរបស់លោក គឺកងពល១១៧ហ្នឹង បានប្រឹងប្រែងប្រយុទ្ធអស់ហើយ <តើ>លោកខឹង<ទេ>ដែលថា គេចាប់ខ្លួនមេរបស់លោក<>ព្រោះថាលោកប្រឹងប្រែងវើអស់លទ្ធភាពហើយ តែគេនៅតែចាប់មេរបស់លោកលោកខឹងទេ?

**ឆ៖** បញ្ហាសំណួរនេះ បើខ្ញុំនិយាយឲ្យចំទៅមនោសញ្ចេតនាក្នុងមេបញ្ជាការខ្ញុំដែលគាត់ខំពុះពារទាំងអស់ ទៅពីនេះ ទៅពីលង្វែកទៅចំនួននោះ ធម្មតាទេ ធម្មតាដែលខំពុះពារតាំងពីខែ៣ ៧៧ មកទល់នឹង៧៨នេះ ខំចំណាយមើល១.៨០០នាក់ប៉ុន្មានខែ ៧ខែ អស់៨០០។ ចង់និយាយថា ខំពុះពារអស់ប៉ុណ្ណឹង

ហើយ ដល់ពេលគ្រាន់តែគាត់ទៅភ្លាមគាត់ថា "មេអ្នែងក្បត់ អត់វើយួន"។ ធម្មតាកងទ័ពទាំងអស់ វាមានការអន់ចិត្ត តែកាលជំនាន់នោះគឺមិនបានហ៊ានតវ៉ាអីដូចឥឡូវទេ មិនមែនហ៊ាននិយាយអីដូចឲ្យក្បោះក្បាយអ៊ីចេះបានទេ។ សូម្បីតែមើលមុខគ្នាចំមិនហ៊ានមើលមុខផង អាហ្នឹងខ្ញុំនិយាយត្រង់ ចំពោះលោកព្រះរាជអាជ្ញាចុះ។ តែធ្វើម៉េច ដើម្បីដាច់ខាត ដើម្បីឲ្យឈ្នះគេ តែនៅមិនឈ្នះ អាហ្នឹងការអាក់អន់ចិត្ត ស្រពន់ចិត្តចេះតែមានហើយ ព្រោះបើគាត់ខំតាំងពី មើលគាត់ទៅតាំងពីខែ៣ ៧៧ រហូតមកទល់នឹង៧៨នេះ។ គាត់ខំប៉ុណ្ណឹងហើយនៅថា។ ហើយគណៈស្រុក និងគណៈតំបន់សុទ្ធចេញពីកងពលហ្នឹងទាំងអស់។ ទីចុងបំផុតទៅនៅគាត់ខុស។ ហើយខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណឹងសិន។

**ស៖** សូមអរគុណ។ ដើម្បីបញ្ជាក់ឲ្យច្បាស់គឺនៅក្នុងឆ្នាំ៧៧ លោកក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការហើយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ បញ្ហាហ្នឹងខ្ញុំ -- បាទ បញ្ហាហ្នឹងពិតប្រាកដមែន។

[០៩:៤៦:៥០]

**ស៖** លោករស់នៅក្នុងរបបខ្មែរក្រហមអស់រយៈពេលយូរ ក្រោយពេលដួលរលំកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំចង់ដឹងថាលោកចាកចេញពីខ្មែរក្រហមនៅពេលណាដែរ?

**ឆ៖** ខ្ញុំចាក កៅ ចាកចេញពីខ្មែរក្រហម ចេញពីកម្ពុជាប្រជាធិបតេយ្យខែ ប្រហែល៩៨នេះ ៩៧នេះ មុនសមាហរណកម្ម ឬសមាហរណកម្មនេះឯង។ សមាហរណកម្ម៩៨នេះ ហ្នឹងខ្ញុំចាកចេញហើយ។

**ស៖** អ៊ីចឹងលោកចង់និយាយថា លោកចេញពីខ្មែរក្រហមឆ្នាំ៩៨មែន តើលោកចង់និយាយឆ្នាំ ១៩៩៨ ឬក៏ ១៩៧៨?

**ឆ៖** និយាយរួមខ្ញុំនៅរហូតមក រត់យួនមករហូតមកនៅទើបសមាហរណ -- នយោបាយឈ្នះឈ្នះ សមាហរណកម្មនេះ ៩៨, ៩៧នេះឯង ៩៧ ប៉ុន្តែដល់ប្រកាសក្រឹត្យខ្ញុំ៩៨។ ដូច្នេះខ្ញុំនៅព្រំដែនរហូត ខ្ញុំមានដែលបែកចេញពីគាត់ឯណា។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណសាក្សី។ ឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកាជូនសហការីរបស់ខ្ញុំ។ ហើយខ្ញុំសូមជម្រាបអង្គជំនុំជម្រះក៏ដូចលោកប្រធានថា ខាងដើមបណ្តឹងរដ្ឋប្បវេណីបានប្រាប់មកខាងខ្ញុំថា ពួកគាត់មិនត្រូវការពេលវេលាដើម្បីសួរសំណួរនោះឡើយ។ សូមអរគុណលោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៤៩:០២]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រី ចៅក្រម។ សូមជម្រាបសួរភាគី និងអង្គសវនាការទាំងមូល។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាសហព្រះរាជអាជ្ញារងជាតិ ហើយខ្ញុំនៅសល់ប្រធានបទមួយទៀត ដើម្បីពិភាក្សាជាមួយលោកចុងក្រោយ។ ប្រធានបទដែលខ្ញុំចង់ពិភាក្សាជាមួយលោក គឺពាក់ព័ន្ធជាមួយនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មុននឹងចាប់ផ្តើមសំណួរលម្អិតទៅនឹងប្រធានបទនេះ ចង់សួរលោកថា លោករៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំណាដែរ លោកនៅចាំទេ?

2-TCW-1005៖

**ឆ៖** បាទ បើខ្ញុំនិយាយពីការរៀបអាពាហ៍ពិពាហ៍ចំពោះបុគ្គលខ្ញុំ ឬសួរជាទូទៅ? បើសួរពីខ្លួនខ្ញុំ ខ្ញុំចង់ឆ្លើយថាខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយ យាយយុត នេះដែល ប្រាក់ យុត នេះឆ្នាំ៨២ – ១៩៨២ ប៉ុន្តែរៀបអាពាហ៍ពិពាហ៍ខ្ញុំមិនបានរៀបដោយការស្រឡាញ់អីធំដុំ អាហ្នឹងនិយាយដូចការបង្ខិតបង្ខំក៏ថាបានដែរ ព្រោះខ្ញុំវាបាក់បែកមកពីជើងមក ខ្ញុំមកពីៗដងរែកមក អាហ្នឹងខ្ញុំនិយាយប្រវត្តិខ្ញុំទៅចុះ។ បាទ ប្រវត្តិខ្ញុំហ្នឹងពីដើមខ្ញុំនៅដងរែក ដល់ខ្ញុំហ្នឹងទៅសុំឡានដឹកគ្រាប់អី មកសូមអង្គភាពមកសូម បងញ៉ាន់នោះ គាត់នៅ១០០៣ហ្នឹង ក៏អ៊ឹំអ៊្ហា! ខ្ញុំទៅរកម្តាយខ្ញុំនៅ២៥០ មកនៅនេះហើយ មកនៅ៣២ មកតាង៉ុកនេះ។ មកដល់ក៏ម្តាយខ្ញុំស្លាប់ ក៏ខ្ញុំមកនៅហ្នឹងមក ក៏នៅយាយ គាត់ថាខ្ញុំស្រុកភូមិគាត់នោះ ក៏ខ្ញុំរៀបជាមួយគាត់ហ្នឹងបានកូនមួយ។ អាហ្នឹងកាលហ្នឹង បើខ្ញុំរៀបអាពាហ៍ពិពាហ៍ហ្នឹងណ៎ា។

[០៩:៥០:៤៧]

**ស៖** ចាស។ អរគុណលោកសាក្សី។

**ឆ៖** បាទ តែខ្ញុំមានបន្តទៀត មិនមែនប្រពន្ធគាត់តែគាត់មួយឯណា ខ្ញុំនៅមានថែមចុងទង នៅមក ជូនខ្ញុំមកនេះមួយទៀត ហ្នឹងពី៨៨ ខ្ញុំផ្តាច់ខ្លួននេះ ៩៧នេះ។

**ស៖** ចាស អរគុណលោកសាក្សី។ ឥឡូវយើងពិភាក្សាគ្នាលម្អិតទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមបទពិសោធន៍

របស់លោកផ្ទាល់នេះ តើបុរសហើយនិងស្ត្រីគាត់មានសិទ្ធិដោយសេរីក្នុងការរើសគូស្រករ ឬក៏រៀបការដោយសេរីតាមឆន្ទៈរបស់គាត់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយបានហើយលោកសាក្សី!

**2-TCW-1005៖**

**ឆ៖** បាទៗ ខ្ញុំឃើញភ្លើងហើយបាទ កំពុងរាវរកភ្លើង។ បាទ បញ្ហានឹងដែលខ្ញុំធ្លាប់ដឹងមក ដែលខ្ញុំឆ្លងកាត់ពីជំនាន់នោះ តាំងពីខ្ញុំនៅតាកែវមករហូតមកដល់ខ្ញុំទៅក្រចេះ អាហ្នឹងបើតាមខ្ញុំដឹងរាល់ការរៀបអាពាហ៍ពិពាហ៍ដូចដែលខ្ញុំបាននិយាយខាងដើមអ៊ីចឹង មិនបានរៀបអីទូងស្គរទូងអីទេ។ រៀបអាពាហ៍ពិពាហ៍ដោយការ ដូចថាឥឡូវខាងនារីគាត់មិនមានសិទ្ធិជ្រើសរើសទេជំនាន់នោះ មានតែបុរសទេ។ ដល់ការហ្នឹង ក៏ថាចាប់គូជូនកាលច្រឡំទៀត អាហ្នឹងរៀបការបងៗជំនាន់នោះ ខ្ញុំ កាលហ្នឹងខ្ញុំនៅទើបអាយុប្រហែលជា ប្រាំបី ប្រាំពីរប្រាំបីដណ្ដប់ទេ។ ដល់អ៊ីចឹងទៅខ្ញុំនិយាយពីការពេលប្រជុំសន្និបាត ឧទាហរណ៍ ឥឡូវប្រជុំធំ បើខ្ញុំនៅខាងកងទ័ពប្រជុំកងពលប្រជុំ ឬវរសេនាធំប្រជុំអ៊ីចឹងទៅ ត្រូវស្រឡាញ់គ្នាប៉ុន្មានគូ ប្រាំគូ។ ឥឡូវរើស ឲ្យខាងបងៗគាត់រើសគ្នាគាត់ហ្នឹង ជួនកាលអ្នែអញយកនេះយកនោះ តែនារីគ្នាអត់មានសិទ្ធិរើសទេ។ បើនារីថាមិនស្រឡាញ់ក៏ដោយ បើថាតម្រូវថាអង្គភាពហ្នឹងត្រូវឲ្យ ឥឡូវដូចពួកគាត់នៅពេទ្យ អ្នករបួសគាត់ទៅសម្រាកពេទ្យ ជួនកាលគាត់ត្រូវរូវគ្នាខ្លះអ៊ីចឹង មកស្នើមក អាហ្នឹងថាដូចមានលិខិតស្នើនោះ ដូចថាមកស្នើមកមេបញ្ជាការ មកអង្គភាពនេះ។ គោរពជូនបង ខ្ញុំសូមស្នើនេះ ស្រឡាញ់នារីឈ្មោះ “ក” អ៊ីចឹង ស្នើទៅ នារីគ្នាម៉េចហ៊ាន។ ទោះគាត់មិនស្រឡាញ់គាត់ស្រលាញ់ឈ្មោះ ក -- “ខ” គាត់បើឈ្មោះ “ក” ស្នើមុន បានឈ្មោះ “ក” ហើយ, ឈ្មោះ “ខ” អត់បានទេ។ អាហ្នឹងមិនមែនការបង្ខិតបង្ខំទេ ប៉ុន្តែមិនហ៊ានតវ៉ា។ អាហ្នឹងខ្ញុំនិយាយរឿងអាពាហ៍ពិពាហ៍ហ្នឹងតាមខ្ញុំដឹងតៗមក រហូតដល់ខ្ញុំទៅនៅក្រចេះហ្នឹងក៏អ៊ីចឹងដូចគ្នាដែរ។ រៀបពេលដែលយើងដូចថាប្រជុំធំសន្និបាត ពេលចប់មួយអាទិត្យអ៊ីចឹង រៀបមួយពេលអ៊ីចឹងទៅ គាត់រៀបបានទៅ ប៉ុនគាត់អត់មានបានរើសបានអីទេអាហ្នឹង តាមចាប់ដាក់។ ជួនកាលទៅក៏ចាប់ដាក់ តាមមេឲ្យថាឥឡូវយកអ្នកនេះយកអ្នកនោះ ផ្គូផ្គងទៅ អាហ្នឹងមានបញ្ហាហ្នឹងមានមែន។ បាទ សូមអរគុណ។

[០៩:៥៣:៥២]

**ស៖** ចាស អរគុណលោកសាក្សី។ មុននេះលោកនិយាយថា បើមានការស្នើគឺខាងបុរសគាត់

អ្នកស្មើ ហើយស្ត្រីមិនអាចមានសិទ្ធិប្រកែក ឬក៏តវ៉ាអីទេ ឬក៏លក្ខខណ្ឌមួយទៀតហ្នឹងគឺ ប្រសិនបើមានមេគាត់រៀបចំឲ្យត្រូវរៀបការហ្នឹង គឺត្រូវរៀបការ។ នៅក្នុងស្ថានភាពដែលលោកលើកឡើងមុននេះ តើនៅក្នុងតំបន់១៣ ឬក៏នៅកន្លែងផ្សេង ឬក៏នៅទាំងពីរកន្លែង បីកន្លែងដែលលោកបានរៀបរាប់ពិភាក្សាកន្លងមក នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញសហមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ព្រោះសាក្សីគាត់អាចផ្ដល់ភស្តុតាងពីអ្វីដែលគាត់ឃើញ ដែលគាត់<បានសង្កេត>ប៉ុណ្ណោះ។ គាត់មិនអាចនិយាយអំពីតំបន់<ផ្សេងទៀត ក្រៅពីតំបន់ដែលគាត់បានធ្វើការនោះទេ>។

[០៩:៥៥:00]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី <បញ្ហានេះខ្ញុំបានប្រាប់សាក្សីពីម្សិលមិញរួចហើយ ហេតុអ្វី>លោក<ជំទាស់នឹងការតាំងសំណួររាល់ពេលដូច្នេះ? បើគាត់មិនដឹងទេ ខ្ញុំបានប្រាប់គាត់រួចហើយ ឲ្យគាត់ឆ្លើយថា "ខ្ញុំមិនដឹង" ទៅ>។

**លោក វ៉ិចទ័រ កូប៉េ៖**

<ហេតុអ្វីលោកស្រីចៅក្រមមិននិយាយដោយផ្ទាល់ជាមួយព្រះរាជអាជ្ញាទៅ? គាត់ឮការកត់សម្គាល់ដូចគ្នាអ៊ីចឹងដែរ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ព្រះរាជអាជ្ញាសួរសំណួរ ហើយខ្ញុំបាន>ប្រាប់ទៅ<សាក្សី>ថា <គាត់>អាចឆ្លើយ <ឬនិយាយថា "ខ្ញុំមិនអាចឆ្លើយបានទេ"។ លោកតែងតែងធ្វើការសន្និដ្ឋានទូវអ្វីដែលសាក្សីអាចនឹងឆ្លើយ>។ ខ្ញុំប្រាប់រួចទៅហើយ ឥឡូវខ្ញុំប្រាប់ម្ដងទៀត ប្រសិនបើលោកដឹង សាក្សីលោកឆ្លើយថាដឹង បើលោកថាមិនដឹងទេ លោកឆ្លើយថា មិនដឹងទៅ លោកសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោស លោកស្រីចៅក្រម ហ្វេនស៍។ ខ្ញុំមានបញ្ហាពាក់ព័ន្ធទៅនឹងនីតិវិធី។ នៅពេលដែលយើងជំទាស់ គឺយើងជំទាស់ទៅនឹងសំណួររបស់ភាគីបដិបក្ខ។ យើងមិនជំទាស់ជាគោលការណ៍ទៅនឹងចម្លើយរបស់សាក្សីទេ។ យើងយល់ថា ចម្លើយ -- យើងគិតថា សំណួរមិនត្រឹមត្រូវ បានយើងជំទាស់ <ហើយនេះជាអ្វីដែលយើងតែងតែអនុវត្តតាំងពីពេលចាប់ផ្តើមមក>។ ហើយ<ជាការពិត>ការរំឮកសាក្សី<>ថា <គាត់មិនអាចឆ្លើយដោយប៉ាន់ស្មាន គឺជា>អង្គហេតុមួយ។ ក៏ប៉ុន្តែ<បើសំណួរនាំទៅរកការឱ្យឆ្លើយដោយស្មានៗ គឺយើងមានសិទ្ធិ>ជំទាស់។ <នេះជាបញ្ហានីតិវិធី។ យើងតែងតែអនុវត្តបែបនេះតាំងពីពេលចាប់ផ្តើមមក ដូច្នេះខ្ញុំពិតជាពិបាកយល់។ ខ្ញុំមិនយល់ថា> ម៉េចក៏ទៅមកបន្ទោសយើង ថាយើងជំទាស់អ៊ីចឹងទៅវិញ។ យើងជំទាស់ ដោយសារតែយើងយល់ឃើញថា សំណួរវាមិនត្រឹមត្រូវ។

[០៩:៥៦:២៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ព្រោះមូលដ្ឋាននៃការជំទាស់របស់មេធាវី>ក្នុងផ្នែកហ្នឹង គឺថាសាក្សី<>ទាយស្មាន ហើយសាក្សី គាត់ទាយស្មានខ្លួនឯងផ្ទាល់។ ខ្ញុំមានបញ្ហាចំពោះ<>សំណួរ<ដែលបានជំទាស់នេះ> ព្រោះថាអាចថាសាក្សីគាត់មិនដឹង។ នេះវាគ្រាន់តែជាការសន្មតទេ។ ខ្ញុំព្យាយាមនិយាយបែបនេះទេ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធាន ដើម្បីដោះស្រាយបញ្ហានេះ ខ្ញុំនឹងលើកយោងទៅនឹងចម្លើយពីមុនរបស់សាក្សី។ ដោយសារនៅក្នុងចម្លើយនៅត្រង់ឯកសារ E3/10622 នៅត្រង់សំណួរចម្លើយលេខ៨០។ នៅពេលដែលអ្នកស៊ើបអង្កេតសួរទៅសាក្សី លោកសាក្សីបានឆ្លើយថា ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ហ្នឹង គឺអនុវត្តទូទាំងប្រទេស រួមទាំងកងទ័ពផងដែរ។ ហើយនៅចម្លើយទី៨១របស់សាក្សី គាត់បានឆ្លើយថា៖ "ពេលដែលខ្ញុំនៅតាកែវ ក្នុងកងពលលេខ២ ខ្ញុំឃើញគេធ្វើបែបនេះដែរ។ ពេលខ្ញុំទៅលង្វែក កងពលលេខ០១ ភូមិភាគបស្ចិម ដូចគ្នាដែរ។ ពេលខ្ញុំទៅធ្វើកងទ័ពនៅក្រចេះ កងពល១១៧ តំបន់៥០៥ ក៏ខ្ញុំបានឃើញការអនុវត្តដូចគ្នាអ៊ីចឹងដែរ។" ហេតុដូច្នេះហើយ ទើបខ្ញុំសួរសំណួរនេះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ឆ៖** អ៊ីចឹងខ្ញុំសួរលោកបញ្ជាក់ថា នៅក្នុងករណីដែលលោកបានលើកឡើងមុននេះថា ស្ត្រីមិន

អាចបដិសេធ ឬក៏ប្រកែកនៅពេលដែលមានការចាត់តាំង ឬក៏រៀបចំឱ្យរៀបអាពាហ៍ពិពាហ៍ហ្នឹង លោកនិយាយដល់តំបន់១៣នៅតាកែវ លោកនិយាយដល់លង្វែក ហើយលោកនិយាយដល់ក្រចេះ នៅក្នុងកងពល១១៧ តំបន់៥០៥ហ្នឹង មែនដែរឬទេ?

[០៩:៥៨:៣០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើអាចផ្តល់ឯកសារយោងឱ្យបានច្បាស់ ដើម្បីជាកំណត់ត្រាដែរឬទេ លោកស្រីតំណាងសហព្រះរាជអាជ្ញា?

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកស្រីចៅក្រម ខ្ញុំផ្តល់ឯកសារយោងម្តងទៀត គឺឯកសារ E3/1062 (ស៊ីក) នៅត្រង់សំណួរចម្លើយលេខ៨០ និង៨១។

**ប្រធានអង្គជំនុំ៖**

ឆ្លើយសាក្សី!

ស្តាប់បានទេ? ស្តាប់បានសំណួរទេ?

**2-TCW-1005៖**

អាចខ្ញុំឆ្លើយបានអត់ ភ្លើងក្រហម?

**ប្រធានអង្គជំនុំ៖**

ភ្លើងក្រហមចេញហើយ។

**2-TCW-1005៖**

បាទៗ ចេញភ្លើងក្រហម ខ្ញុំឆ្លើយបានអត់?

[០៩:៥៩:១៨]

**ប្រធានអង្គជំនុំ៖**

បាន! បានហើយ!

**2-TCW-1005៖**

**ឆ៖** បាទៗ។ អ៊ីចឹងបញ្ហាដែលគាត់លើកឡើងអម្បាញ់មិញ បញ្ហាហ្នឹងត្រឹមត្រូវទាំងអស់ហើយ ព្រោះខ្ញុំបាននៅទីនោះ មកដល់ទីនេះ ខ្ញុំឃើញអង្គភាពខ្ញុំក្តី តាមកន្លែងផ្សេងៗគឺឃើញរៀបអាពាហ៍-

ពិពាហ៍ជាគូៗអ៊ីចឹងមែនហើយ។ ហើយមិនទៅដឹងថា អ្ហែ!ស្រឡាញ់មិនស្រឡាញ់ដូចសម័យនេះអ្ហែ ស្ទី ទេអានុ៎ង ពីដើមហៅ "គូស្នេ"។ ស្នេហ្នឹង បើថាអង្គភាពសម្រេចឲ្យ បាន បើអង្គភាពមិនសម្រេចឲ្យ ទៀត ក៏អត់ដដែល។ នុ៎ងបញ្ហានុ៎ងបើខ្ញុំនិយាយលម្អិតទៅទៀត រឿងហ្នឹងគ្រប់អង្គភាពជំនាន់នោះ។ ប៉ុន្តែ បើខាងមូលដ្ឋាន ខ្ញុំអត់សូវដឹងទេ។ តែបើជួរទ័ព ការម្តង ជួនកាលលេងប្រាំគូ ប្រាំមួយគូ ប្រាំបីគូអ៊ីចឹង ទៅ។ តែការហ្នឹង បានហូបឆ្ងាញ់ដែរ ជប់លៀងជាសាច់ជ្រូក ជាគុយទាវអីអ៊ីចឹងទៅ ធ្វើដៃហ្នឹង ពេល បិទវគ្គហ្នឹងអ៊ីចឹងទៅ។ ប៉ុន្តែការហ្នឹងមិនអ្នកឆ្ងាយទេ ក្នុងមន្ទីរពេទ្យគ្នាឯងហ្នឹង អ្នករបួសកងទ័ពអី គាត់ ទៅសម្រាកអ៊ីចឹង គាត់ចេះតែស្នេទៅអ៊ីចឹងទៅហ្នឹង។ ប្រាប់ឲ្យថាគាត់ស្រឡាញ់ពេញចិត្តតែម្តង មិនអាច មានទេ អាហ្នឹង គ្រាន់តែដូចថាការមានគូស្នេមានអី អាហ្នឹងៗរឿងពិត អាហ្នឹងខ្ញុំបានបកស្រាយបញ្ហា ហ្នឹងជូនតាមហ្នឹង ខ្ញុំឯកភាពតាមដូចលោកព្រះរាជអាជ្ញាគាត់លើកមកហើយ។

[១០:០០:៣៧]

**កញ្ញា សុង ឆវ័ន្តន៖**

**ស៖** ចាសៗ អរគុណលោកសាក្សី។ ចុះនៅក្នុងតំបន់១៣នៅក្នុងអំឡុងពេលដែលលោកនៅ តាកែវហ្នឹង តើការរៀបអាពាហ៍ពិពាហ៍ហ្នឹង ពេលដែលស្នេហ្នឹងអ្នកណាស្នេទៅអ្នកណាក៏បាន ឬក៏ពេល ដែលរៀបអាពាហ៍ពិពាហ៍ហ្នឹង ចង់ស្នេបានហ្នឹងទាល់តែពួកគាត់មានឋានៈ ឬក៏ស្ថិតនៅក្នុងប្រភេទក្រុម មនុស្សជាមួយគ្នា ឧទាហរណ៍បក្សជាមួយនឹងខាងបក្ខជនអ៊ីចឹងទៅ ខាងយុវករ ឬក៏អាចស្នើខ្វែងគ្នាបាន ដែរ ឬក៏ត្រូវតែជាប្រភេទមនុស្សនៅក្នុងក្រុមតែមួយ?

**ឆ៖** តាមដែលខ្ញុំក្តាប់បាន ឬក៏ខ្ញុំធ្លាប់ឆ្លងកាត់នៅត្រង់នុ៎ង ដូចថាឥឡូវនារីគាត់ជនចម្រើន ឬក៏ ស.ក ដូចសម្ព័ន្ធយុវកក បាទនារីណ៎ា តែនារីនៅក្មេង ខាងខ្ញុំនេះបក្ខជន ខាងបុរសនេះ ខ្ញុំមានសិទ្ធិស្នើ នារីហ្នឹងហើយ។ តែបើសិនណាជាខាងខ្ញុំ -- ខាងនារីនេះ ដែលៗគ្នាសក្តិធំអីជាងអ៊ីចឹង អាហ្នឹងក៏នៅតែ បានដូចគ្នា ដូចថាសិទ្ធិជាបក្ខជនអីអ៊ីចឹង ប៉ុន្តែមិនសូវយកទេ បុរសយើងមិនសូវយកដូចនារីចាស់ទេ ជំនាន់នោះ។ នារីចាស់នៅសល់រហូតទាល់រត់យួនទៀតក៏នៅដែរ។ បើគាត់យកក៏យកតែគ្នាគាត់ក្មេងៗ ទៅ អ៊ីចឹងបាននៅសល់បងៗនារីច្រើនចាស់មួយរត់យួននេះ។ អាហ្នឹងរឿងដែលថា ដូចថាអារឿងប្រវត្តិ រូបវាត្រឹមត្រូវអ៊ីចឹងហើយ រឿងបក្ស និងសម្ព័ន្ធអីអ៊ីចឹងទៅ តែដោយឡែកដល់រៀបការអត់អ៊ីចឹងទេ។ អា ហ្នឹងខ្ញុំចង់បកស្រាយអាហ្នឹងឲ្យបន្តិចទៅ ព្រោះតែបើតាមរៀបចំក្នុងឯក -- ក្នុងប្រជុំអ៊ីចឹងទៅ ដូចថា ឥឡូវនែ! បើអ្នែងត្រូវយកៗឲ្យស្របគ្នា ដូចថាអង្គភាពមេបញ្ហាការគាត់ប្រាប់ថា ដល់ពេលដែលស្នើទៅ

អង្គភាពសម្រេចឲ្យយកបានហើយអាហ្នឹងមានអី សំខាន់គឺក្នុងអង្គភាពយល់ស្រប។ ការហ្នឹងខ្ញុំមានប៉ុណ្ណឹង។

[១០:០២:៣៥]

**ស៖** ចាស អរគុណ។ នៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេត គឺនៅត្រង់ឯកសារដែលខ្ញុំលើកយោងមុនដដែលហ្នឹង គឺឯកសារE3/10622។ នៅត្រង់ចម្លើយរបស់លោក សំណួរចម្លើយលេខ៧៥ លោកបានឆ្លើយថា៖ "ពេលប្រជុំគេបាននិយាយ គឺចំពោះនារីដែលមានអាយុ២៥ឆ្នាំ ហើយបុរសណាដែលមានអាយុ៣០ឆ្នាំអាចរៀបការបាន។ ហើយបើនារី ឬបុរសចង់រៀបការ អាចស្នើមកស្រុក ឬឃុំ បើគេរើសថាអ្នកក្នុងសម្ព័ន្ធយុវកករៀបការជាមួយនឹងសម្ព័ន្ធយុវកក ហើយអ្នកនៅក្នុងបក្ខជនរៀបការជាមួយនឹងបក្ខជនដូចគ្នា គឺមិនអាចរៀបការអ្នកក្រៅក្រុមបានទេ។" ខ្ញុំចង់សួរលោកថាពេលហ្នឹងគេមានពន្យល់ទេថាហេតុអ្វីបានជាគេមិនអនុញ្ញាតឲ្យរៀបការជាមួយនឹងមនុស្សនៅក្រៅក្រុម?

**ឆ៖** បញ្ហាដែលលោកព្រះរាជអាជ្ញាលើកឡើងនេះ បញ្ហាហ្នឹងខ្ញុំលើកពីបញ្ហាហ្នឹងត្រឹមត្រូវហើយ តែដោយឡែកខ្ញុំមិននិយាយមិនបានលម្អិតដល់នុ៎ងទេ តែដោយឡែក ឥឡូវខ្ញុំបកស្រាយឲ្យទៅទៀត ព្រោះចង់ថាជាអង្គភាពប្រជុំធម្មតាមូលដ្ឋាន ដូចថាមូលដ្ឋាននិង១៧មេសានេះ ដែលលើកពីម្សិលមិញសួរខ្ញុំនេះ។ ដល់អីចឹងមិនឲ្យមានប្រវត្តិរូបពាក់ព័ន្ធ អាហ្នឹងខ្ញុំនិយាយមិនបានជាឯកសារអីចេញមកពីណាទេ គេប្រជុំក្នុងអង្គភាព គឺដូចថាឥឡូវគាត់មេបញ្ជាការខ្ញុំអីចឹង ឬក៏ថ្នាក់វរសេនាធំ ឬកងពលអីចឹងអាហ្នឹងមិនមែនចេញជាវាមានឯកសារក្រដាសស្នាមអីទេ គឺអង្គភាពហ្នឹងគឺកំណត់ប្រជុំថា ឥឡូវមូលដ្ឋានហ្នឹងត្រូវយកមូលដ្ឋាន មិនឲ្យជាប់ពាក់ព័ន្ធជាមួយអ្នក១៧មេសា ឲ្យជាប់ពាក់ព័ន្ធអីហ្នឹង ខ្លាចជាប់ប្រវត្តិរូបដែលវាមិនច្បាស់លាស់នេះ អាក្លាប់ប្រវត្តិរូបមិនបាននេះ ដល់អីចឹងវាជាប់ពាក់ព័ន្ធ អ៊្ហែ ទៅយកមក ដល់មើលប្រវត្តិរូបក្រោយ លែងជាប់ស្អីគេ ទៅកា.ហ្សេ.បេ។ ស្រាប់ការហើយមិនទាន់បានពីរបីថ្ងៃចោទទៅ សេ.អ៊ី.អា។ អីចឹងវាអស់កម្មាភិបាលត្រូវធ្លាក់ ឬក៏ជាប់ពាក់ព័ន្ធបញ្ហាហ្នឹង។ បញ្ហាហ្នឹងក្នុងអង្គភាពប្រជុំ គឺសំខាន់ គេលះបង់ច្បាស់ ត្រង់ថាឲ្យដាច់ខាត ត្រង់ថាត្រូវគិតគូរជាមូលដ្ឋានថា ឲ្យរឹងប៉ឹងនេះ ស្លូល ជាស្លូលគឺស្អី? សម្ព័ន្ធយុវកក ជនចម្រើន សម្ព័ន្ធយុវកក បក្ខជន។ អាហ្នឹងក្នុងអង្គប្រជុំ តែមិនមានក្រដាសស្នាមអីទេ គឺជាអង្គភាពប្រជុំ។ អាហ្នឹងជាទូទៅ គឺពង្រឹងបញ្ហាហ្នឹង រឹងមាំប៉ុណ្ណឹង។ អាហ្នឹងចង់និយាយដល់អីចឹង ដូចជាការបង្ខំបង្ខិតហើយ។ ដូចថាឥឡូវ ខ្ញុំត្រូវស្រឡាញ់ឈ្មោះ "ក" នារី១៧ ខ្ញុំមិនអាចទៅយកបាន បើតាមការយល់នោះ ព្រោះយកម៉េច បើគេបង្ខំឲ្យទៅយកឯណោះ ឯណាផ្សេង

អ៊ីចឹងទៅ។ អាហ្នឹងខ្ញុំនិយាយ មិនបកស្រាយឲ្យចំលម្អិតដល់ប៉ុណ្ណឹងទេ តែគ្រាន់កាលនុ៎ង គឺខ្ញុំលើកយកបញ្ហាហ្នឹង ត្រឹមត្រូវហើយ ព្រោះឯកភាពតាមហ្នឹងនោះ។

[១០:០៥:៥៤]

**ស៖** ចាស អរគុណលោកសាក្សី។ នៅក្នុងចម្លើយរបស់លោកនៅជាមួយនឹងអ្នកស៊ើបអង្កេតដដែលនេះ ត្រង់សំណួរចម្លើយលេខ១៦៤។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា៖ "អ៊ីចឹងខាងកងទ័ព គាត់ស្នើទៅខាងនារី តើនារីនោះ អាចប្រកែកបានទេ?" ចម្លើយរបស់លោក លោកឆ្លើយថា៖ "ខាងនារីនោះ អត់ប្រកែកបានទេ។ ចំណែកខាងបុរស ពេលខ្លះស្នើរៀបការជាមួយនារី "ក" តែដល់ពេលរៀបការ ទៅរៀបការជាមួយនារី "ឃ" ក៏មានដែរ។" ហើយលោកបាននិយាយថា នារីមិនអាចប្រកែកបាន។ ហើយលោកបាននិយាយបញ្ជាក់ថា ពួកគាត់មានការភ័យខ្លាច។ ខ្ញុំចង់សួរបញ្ជាក់លោកថា ហេតុអ្វីបានជាគាត់មិនអាចប្រកែកបាន? ហើយនៅពេលដែលលោកនិយាយថា នារីមានការភ័យខ្លាចហ្នឹង តើគាត់ភ័យខ្លាចរឿងអ្វីដែរ?

**ឆ៖** ខ្ញុំសូមបកស្រាយបញ្ហាហ្នឹងជូនលោកព្រះរាជអាជ្ញា។ មិនមែនការភ័យខ្លាចបញ្ហាអីទេ ចង់និយាយ ក្នុងអង្គភាពមួយ។ ឥឡូវខ្ញុំអត់មាននិយាយដល់ទូទៅ ទូទៅប្រទេសទេ ខ្ញុំនិយាយតែចំណុចដែលខ្ញុំធ្លាប់នៅគោល១១ បាទ។ ឥឡូវឧទាហរណ៍នៅក្នុងក្រុមនារីហ្នឹង ប្រធានកងនារីហ្នឹង គាត់មានមេកងមួយ បាទ។ ឥឡូវឧទាហរណ៍ថា មេកងហ្នឹង គេគំរាមឲ្យថា ឥឡូវទាក់ទងជាមួយកងខ្ញុំនេះ គាត់ត្រូវរ៉ូវគ្នា គាត់មិនបញ្ជាថា ឥឡូវនេះ អ្អែងអត់មានទៅយកអ្នកណាបានទេ។ អានេះ អញឲ្យយកអានេះ។ អ្ហ៎! ដល់មេកងខ្ញុំនេះ អ្អែងយកអានេះ។ ការផ្គូផ្គង់គ្នារបស់អង្គភាពមួយៗ ទាក់ទងគ្នា ជាមន្ទីរពេទ្យ គេមានមេមន្ទីរអ៊ីចឹង អ្ហ៎! មេកងនារី មានមេកងនារីអ៊ីចឹងទៅ ទ័ពមានទ័ព។ ដល់អ៊ីចឹង មិនអាចហ៊ានប្រឆាំងបាន គ្នាម៉េចហ៊ានប្រឆាំង។ អ្ហ៎! បើមិនយក បើអ្អែងមិនយក គេដក អត់ឲ្យនៅហ្នឹងទេ ទៅនៅកងចល័តនៅអ៊ីចឹងទៅ។ គ្នាភ័យខ្លាចបញ្ហាហ្នឹង។ បើគ្នានៅស្រួល មានអី បើដកទៅកងចល័ត ចប់។ អាហ្នឹងបញ្ហាហ្នឹង ដែលខ្ញុំលើកឡើងគឺចង់និយាយអ៊ីចឹង។ ព្រោះឥឡូវខំតស៊ូពីណា ពី៧៣, ៧៤មក សម្រាប់តែឲ្យនៅណា អ៎! មន្ទីរពេទ្យតំបន់ មន្ទីរពេទ្យកងពល វរសេនាធំអ៊ីចឹងទៅ ដល់ទៅគេឲ្យទៅនៅកងចល័តនៅភូមិវិញ គេធ្វើទុក្ខធ្វើបាប។ គ្នាមិនសុខចិត្ត មិនតាម។ អាហ្នឹងបញ្ហាដែលអង្គភាពមួយៗដែលខំពង្រឹងពង្រឹងបញ្ហាហ្នឹង។ អាហ្នឹង ខ្ញុំនិយាយលម្អិតឲ្យលោកព្រះរាជអាជ្ញាងាយយល់ ដើម្បីយល់ទេ ហើយក៏--

[១០:០៨:១៩]

**ស៖** ចាសៗ អរគុណ។ អរគុណលោកសាក្សី។ ចុះអ្នកដែលប្រកែកតវ៉ាមិនព្រមរៀបអាពាហ៍-ពិពាហ៍ហ្នឹង ត្រូវគេចាត់ទុកថា ជាអ្នកប្រឆាំង ឬក៏ជាសត្រូវដែរឬទេ?

**ឆ៖** បើនិយាយ ខ្ញុំបកស្រាយឱ្យលម្អិតទៀត ចង់និយាយអ៊ីចេះ តាមដែលច្បាប់ បើយើងរៀនច្បាប់បក្ស បើយើងមិនគោរពតាមការចាត់តាំង បានន័យថាយើងហ្នឹងវាប្រឆាំងហើយ។ អាហ្នឹង បើនិយាយតាមច្បាប់ដែលអង្គប្រជុំដូចយើងថានេះ ដែលប្រជុំលើកពីម្សិលស្អូរ ឥឡូវស្វ័យទិតៀនដាក់ខ្លួនឱ្យគេកសាងនេះ។ ឧទាហរណ៍ថា បើសិនណាជាចាប់ ដូចថា ឥឡូវខ្ញុំអង្គភាព អ៊ំ! ឱ្យយកអ្នកនេះ ឬក៏ចាត់តាំងទៅនេះ បើអត់ទៅ បានន័យថា អ្នកនុ៎ងប្រឆាំងហើយ។ ដល់អ៊ីចឹង រឿងហ្នឹងដែលយកអាច្បាប់ហ្នឹងមកនិយាយនេះ បានម្នាក់ៗខ្លាច ដែលមិនហ៊ានៗនោះ។ អាហ្នឹង ខ្ញុំបកឱ្យលម្អិតអ៊ីចឹងទៅចុះ។

**ស៖** តើអ្នកដែលប្រឆាំងនឹងបក្ស ឬក៏ប្រឆាំងនឹងការសម្រេចរបស់បក្សហ្នឹង ពួកគាត់នឹងទទួលបានលទ្ធផលយ៉ាងណាដែរ?

**ឆ៖** តាមដែលខ្ញុំធ្លាប់ដឹង ហ្នឹងសូមជម្រាបលោកព្រះរាជអាជ្ញាត្រង់ទៅ គឺតាមដែលខ្ញុំធ្លាប់ដឹងមក ច្រើនតែដកភារកិច្ចគាត់ចេញពីអង្គភាព ឱ្យមកនៅនេះ ជាមូលដ្ឋានវិញ ឱ្យមកធ្វើស្រែចម្ការនៅភូមិនៅ ដូចនៅជីកប្រឡាយ ជីកទំនប់អ៊ីចឹង អាហ្នឹងតាមខ្ញុំដឹងដែលធ្លាប់ ដែលខ្ញុំធ្លាប់ឃើញ។ ដល់អ៊ីចឹងបានខ្ញុំលើកបញ្ហានុ៎ង។ ដល់អ៊ីចឹងម្នាក់ៗ អ្នកណាហ៊ាន។ មិនមែនមានសិទ្ធិនិយាយតវ៉ា ដូចឥឡូវបានទេជំនាន់នោះ។ ទេអានេះ ខ្ញុំនិយាយឱ្យត្រង់ៗជាមួយមុខលោកព្រះរាជអាជ្ញាឱ្យចុះ បណ្តោយចុះ។

[១០:១០:១៨]

**ស៖** ចាស អរគុណលោកសាក្សី។ ចុះក្រោយពីមានការចាត់តាំងឱ្យមានការរៀបអាពាហ៍-ពិពាហ៍ដោយអង្គការហើយ ឬក៏ដោយថ្នាក់លើហើយហ្នឹង តើប្ដីប្រពន្ធដែលទើបរៀបការហើយហ្នឹងពួកគាត់ត្រូវតម្រូវឱ្យរស់នៅជាមួយគ្នាដែរឬទេ?

**ឆ៖** បញ្ហានុ៎ង ខ្ញុំសូមបកស្រាយទៀត។ យើ! បើអ៊ីចឹងវែងកាន់តែវែងទៅទៀតហើយ។ ឥឡូវឧទាហរណ៍ថា នៅមន្ទីរពេទ្យអង្គភាពខ្ញុំមួយ ដូចថាមន្ទីរពេទ្យ ឬក៏អង្គភាពខ្ញុំចុះ ឥឡូវពេទ្យ ត្រូវការនៅមន្ទីរពេទ្យ។ ឥឡូវរៀបការហើយ បើតាមខ្ញុំដឹងអង្គភាពបងៗមុន រៀបការហើយ៣ថ្ងៃនៅជុំគ្នា ផុតពី៣ថ្ងៃ អ្នកអង្គភាពនៅមុខទៅមុខ អ្នកអង្គភាពនៅពេទ្យនៅពេទ្យ។ តែក្នុងរយៈ១០ថ្ងៃ ឬ២០ថ្ងៃអ៊ីចឹង អាហ្នឹងខាងលើគាត់កំណត់ឱ្យអង្គភាពហ្នឹងគឺសុំមកលេង៣ថ្ងៃ មកលេងផ្ទះ មកលេង មិនមកលេង មិនមែនផ្ទះកំណើតទេណា មកនៅ ដូចថាគាត់នៅពេទ្យក្ដី គាត់នៅកន្លែងកាត់ដេរក្ដី បាទ ដូចថា នៅអង្គភាព

ណាគាត់មកលេងហ្នឹងមក។ អាហ្នឹងច្បាប់ហ្នឹងមាន គាត់ឲ្យមកអ៊ីចឹងមែនដែរ បងៗជំនាន់ការជំនាន់នោះ--

**ស៖** ចាសៗ។

**ឆ៖** -- មិនមែនថាអត់ ពេទ្យឲ្យនៅជុំគ្នារហូត អត់ទេ។ គ្រាន់ថា ចុះអង្គភាព ដូចថា ផ្ទះផ្សេងគ្នា ដូចថានៅកងទ័ពទៅមុខទៅ នៅក្រោយ នៅមន្ទីរពេទ្យអ៊ីចឹងមក កាត់ដេរបាទ។

**ស៖** ចាសៗអរគុណលោក។ អរគុណលោកសាក្សី។ នៅក្នុងអំឡុងពេលដែលលោកនិយាយថាការហើយ៣ថ្ងៃហ្នឹងត្រូវនៅជាមួយគ្នាហ្នឹង តើនៅក្នុងអំឡុងពេលហ្នឹងមានការតាមដាន ឬឃ្លាំមើលពីអង្គការដែរឬទេ ថាពីរនាក់ប្តីប្រពន្ធហ្នឹងពិតជារួមរស់ រួមមេត្រីជាមួយគ្នាជាប្តីប្រពន្ធមែននោះ?

[១០:១២:១៥]

**ឆ៖** ទេ ដល់សួរខ្ញុំលម្អិតអ៊ីចឹង ខ្ញុំកាលជំនាន់នោះ ខ្ញុំអត់ទាន់បានប្រពន្ធផងដូចអត់ដឹងដែរ។ ព្រោះអត់មានទេ បើថារដ្ឋ -- អង្គការការឲ្យហើយ ដូចអត់មានតាមដានអីទៀតទេ គ្រាន់ដឹងថា ឲ្យគាត់ត្រូវរ៉ូវគ្នា អាហ្នឹងខ្ញុំនិយាយពីអង្គភាពខ្ញុំទេ។ តែអាខាងមូលដ្ឋានអី ខ្ញុំអត់បានដឹងទេ អាហ្នឹងបើសិនណាជានៅអង្គភាពខ្ញុំហ្នឹង អត់អីទេ។ ការរស់នៅនុំងគាត់ ដូចជាខាងពេទ្យក្តី ខាងកាត់ដេរក្តី វា-- បាទ។

**ស៖** ចាសៗ អរគុណលោកសាក្សី។ ចុះជាការអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើគោលនយោបាយ និងផែនការនៃការរៀបអាពាហ៍ពិពាហ៍ដែលមានការស្នើទៅថ្នាក់ឃុំថ្នាក់ស្រុកហ្នឹងមានការប្រជុំណែនាំជាទូទៅ ឬក៏លោកដឹងអំពីផែនការនៃគោលនយោបាយនោះ ដោយរបៀបណាដែរ?

**ឆ៖** កាលដែលដឹងហ្នឹង មកពីខ្ញុំបានចូលរួមប្រជុំក្នុងអង្គភាពអ៊ីចឹងទៅ។ អាហ្នឹងដែលខ្ញុំ កាលជំនាន់នោះ ខ្ញុំដូចថា ក្នុងនាមខ្ញុំអនុសេនាតូចអ៊ីចឹងទៅ ខ្ញុំចូលរួមប្រជុំជាមួយអនុសេនាធំ កងវរៈអ៊ីចឹងទៅណា។ ដល់អ៊ីចឹងទៅ ខ្ញុំអាចដឹងថា ឥឡូវប្រជុំនេះ ឥឡូវបងៗជំនាន់មុន គាត់ដូចថា គាត់ចាស់ជាងខ្ញុំអីមែនអ៊ីចឹង គាត់កងទ័ពធម្មតាអ៊ីចឹងទៅ។ ដល់អ៊ីចឹងបងៗជំនាន់នោះ គាត់និយាយហើយថា ឥឡូវនេះបើចង់ស្នើទៅ ដូចថា ឥឡូវពីដើមនោះ ជំនាន់នោះ ត្រឹមអនុសេនាតូច អនុសេនាធំ អត់ទាន់បានចូលបក្សទេ ដល់កងវរៈបាន បានចូលបក្ស។ អាហ្នឹងខ្ញុំនិយាយពីបក្សនោះ គឺត្រឹមអនុសេនាធំ ត្រឹមសម្ព័ន្ធយុវកកទេ។ ដល់អ៊ីចឹងទៅ ចង់ស្នើទៅស្រុកទៅអី ព្រោះជំនាន់នោះ មូលដ្ឋានខ្ញុំមិនសូវដឹងទេ ប៉ុន្តែបើថានៅនារី--

**ស៖** អ៊ីចឹងទេ--

**ឆ៖** -- មន្ទីរស្រុក នារីអីមន្ទីរអីអ៊ីចឹង អាចគាត់ទំនាក់ទំនង ព្រោះខាងមូលដ្ឋាន ថានារីឃុំអ៊ីចឹង

ឧទាហរណ៍អ៊ីចឹង អាហ្នឹងគាត់ធ្លាប់ទាក់ទងគ្នាអ៊ីចឹង គាត់ប្រាស្រ័យទាក់ទងគ្នាទៅ បាទៗ។

[១០:១៤:២០]

**ស៖** លោកសាក្សី ប្រហែលជាសំណួរខ្ញុំមិនច្បាស់ ខ្ញុំចង់សួរថា នៅពេលដែលលោកនិយាយថា មានការប្រជុំណែនាំហ្នឹង តើអ្នកណាជាប្រជុំណែនាំ ប្រាប់ពីបទបញ្ជា ឬគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដែលត្រូវស្នើទៅថ្នាក់ឃុំ ថ្នាក់ស្រុកហ្នឹង? តើពួកគាត់ហ្នឹងជាអ្នកណា ឋានៈអីដែរ ដែលនិយាយប្រជុំរឿងផែនការរៀបអាពាហ៍ពិពាហ៍ហ្នឹង?

**ឆ៖** ទេ អានេះខ្ញុំរាប់រៀបឲ្យយល់នេះ គឺខ្ញុំរាប់រាប់ពីថ្នាក់វរសេនាធំក្តី កងពលក្តីណា អាហ្នឹងក៏ដូចខ្ញុំជម្រាបថា ឥឡូវដូចអង្គភាពខ្ញុំមុន នៅអង្គភាពខ្ញុំមុន ដូច បងផន វរសេនាធំអ៊ីចឹងទៅ។ អ៊ូដល់ខ្ញុំទៅនៅក្រចេះ ពូរុំ អ៊ីចឹងទៅ។ ដល់អ៊ីចឹងទៅ គាត់ប្រជុំ គាត់ថាឥឡូវអ្វែង នៃពួកយើង ឥឡូវនេះថ្នាក់យើងនេះត្រូវទៅយក ភូមិនេះ ឃុំនេះ ស្រុកនេះ។ អ៊ូ! ត្រូវមើលប្រវត្តិរូប តាមដានប្រវត្តិរូបអី អាហ្នឹងចង់និយាយឲ្យលម្អិតអ៊ីចឹងថា មិនមែនពីថ្នាក់លើណាបញ្ជាថាឲ្យនេះទេ សំខាន់គឺអង្គភាពខ្លួនឯងហ្នឹង គឺនិយាយអ៊ីចឹងតែម្តង តែម្តងហ្នឹង តែដោយឡែក មិនមានក្រដាសស្នាមអីទេ។ អានេះខ្ញុំសូមបកស្រាយជូន។ អារឿងដឹងហ្នឹង ដឹងពីក្នុងអង្គប្រជុំហ្នឹង តៗទេ។

**ស៖** ចាស អង្គប្រជុំដែលលោកនិយាយហ្នឹង មានថ្នាក់ស្រុក ថ្នាក់តំបន់ចូលរួមដែរឬទេ? ហើយពេលហ្នឹង តើបើសិនបើមាន តើអ្នកណា ឈ្មោះអ្វីដែរជាអ្នកនិយាយរឿងរៀបអាពាហ៍ពិពាហ៍ហ្នឹង?

[១០:១៥:៥៩]

**ឆ៖** ឥឡូវខ្ញុំសូមបកស្រាយឲ្យខ្លីទៅចុះ ថាឥឡូវ ដូចថាឥឡូវ ខ្ញុំនៅតាកែវអ៊ីចឹង គឺខ្ញុំនៅជាមួយបងផន អ៊ីចឹង។ អ៊ូ! អាហ្នឹង បងផន វរសេនាធំខ្ញុំហ្នឹង គាត់ប្រជុំអ៊ីចឹងទៅ តំបន់ហ្នឹងខ្ញុំអត់បាននៅញឹកញាប់ ព្រោះកាលហ្នឹងខ្ញុំនៅតូច ហើយកាលហ្នឹងក៏មិនទាន់ឈ្នះ៧៥ដែរ។ ដល់ឥឡូវ ខ្ញុំនិយាយពីកងពលដែល ពូរុំ នេះ ឃឹម រុំ អំមិញអ៊ីចឹង។ ដល់អ៊ីចឹងទៅ ធម្មតាប្រជុំនៅអង្គភាព ខ្ញុំចូលរួម។ ដល់ចូលរួម គឺបាននិយាយបញ្ហានុ៎ង។ តែដោយឡែកមានក្រដាសស្នាមពីលើមកថាម៉េចៗ គឺអត់មានទេ គឺនិយាយតែក្នុងអង្គប្រជុំហ្នឹងហើយ។ ដល់អ៊ីចឹងដឹងឮផ្សព្វផ្សាយទៅខាងក្រោមទៀត អង្គភាពតាមវរសេនាធំមួយៗ អនុសេនាធំមួយៗទៀត។

**ស៖** តាមដែលលោកចាំ តើមានការប្រជុំណែនាំរឿងគោលនយោបាយហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** បើលោកព្រះរាជអាជ្ញាសួរអ៊ីចឹងទៅ ដល់វាញឹកញាប់ច្រើនពេកទៅ វាៗមិនបានចាំអស់

ទេ។ តែដោយឡែកខ្ញុំចង់បកស្រាយថា ឧទាហរណ៍ប្រជុំក្នុង៣ខែសរុបៗម្ដង ឧទាហរណ៍៣ខែ មួយត្រីមាសនេះ សរុបផែនការដែលសម្រាប់ ដូចថាយើងត្រូវ ជាការចំណាយចំណូលគ្រាប់រំសេវ ស្បៀងអីទាំងអស់ដែលគ្រប់គ្រងសម្រាប់អង្គភាព សម្រាប់ទ័ពនេះ ដល់អីចឹងត្រូវការប្រជុំបញ្ហាហ្នឹងម្ដង។ អ្ហ៎! ប្រជុំម្ដង ត្រូវការប៉ុន្មាន ក្នុងមួយត្រីមាស ការយ៉ាងតិចក៏ប្រាំគូដែរ ក្នុង៣ខែ។ ដល់អីចឹងត្រូវលើកតៗគ្នាទៅ ខាងមូលដ្ឋាន បើថាខាងបងៗគាត់ស្រឡាញ់មូលដ្ឋាន គាត់ទៅទាក់ទងខាងស្រុក ឬក៏ឃុំនោះទៅ តែកាលនោះយកមកការ យកមកការកន្លែងខាងប្រុសនេះទេ យកមកការកន្លែងកងពលនេះទេ។ មិនដែលខាងទៅការខាងនារីទេ អាហ្នឹងជំនាន់សម័យនោះ ខ្ញុំចង់បកស្រាយឲ្យចំអីចេះ។ តែរឿងថាឲ្យសួរប្រជុំប៉ុន្មានដងៗ ខ្ញុំវាម៉េចចាំអស់ បើលេងប៉ុន្មានឆ្នាំ។ គិតមើលមើល អាហ្នឹងខ្ញុំនៅចាំបានប៉ុណ្ណឹង ខ្ញុំថាដូចថាខ្ញុំនៅចាំល្អដែរណ៎ា។ តែត្រង់គ្រាន់ថាឲ្យមានជាច្បាប់ចេញមកចែងថា អ្ហ៎! ចេះកំណត់អីចេះៗ អត់ទេ គឺថាប្រជុំតៗក្នុងហ្នឹង ក្នុងអង្គភាពមួយៗនេះ។ បាទ ខ្ញុំសូមបកស្រាយប៉ុណ្ណឹង។

[១០:១៨:២៤]

**កញ្ញា សុង ឆវ័ន្តៈ**

ចាស អរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២០នាទី ដល់ម៉ោង ១០:៣៩ នាទី)*

[១០:៣៩:៥០]

**ប្រធានអង្គជំនុំៈ**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកស្រីចៅក្រម អង់តា ហ្គីសសេ ដែលមានបំណង មានមតិយោបល់អំពី -- លោកមេធាវី អង់តា ហ្គីសសេ ដើម្បីមានបំណង មានមតិយោបល់លើការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងការសួរដេញដោលអ្នកជំនាញនាប៉ុន្មាននៅថ្ងៃស្អែក។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ដែលផ្តល់វេទិកាឲ្យខ្ញុំ។ តាមពិតខ្ញុំចង់ធ្វើ<ប្រតិកម្ម>ទាក់ទងទៅនឹងការ<បង្ហាញ>ឯកសារដោយសហព្រះរាជអាជ្ញានៅក្នុងសំណើឯកសារ F2/4/2/5 ថ្ងៃទី២២ កក្កដាកន្លងផុតទៅនេះ។ សហព្រះរាអាជ្ញាគាត់មានជាប់កាព្វកិច្ចក្នុងការធ្វើការបង្ហាញនេះ បង្ហាញពីឯកសារមួយចំនួនដែលមកពីសំណុំរឿងផ្សេង គឺមានឯកសារចំនួន២៧ឯកសារ ដែលត្រូវ<បាន>ផ្តល់ជូនភាគី។ អ៊ីចឹងខ្ញុំយល់ឃើញថា នៅក្នុងក្របខ័ណ្ឌនេះ គឺ<អាស្រ័យលើ>អង្គជំនុំជម្រះ<ក្នុងការ>ផ្តល់ឯកសារទាំងអស់នេះទៅភាគី តែដល់ថ្ងៃនេះ យើងមិនទាន់ទទួលបាននៅឡើយទេ។ នេះគឺជាការផ្ទេរឯកសារថ្មីៗហ្នឹង ក៏ប៉ុន្តែឯកសារមួយចំនួននោះទាក់ទងនឹងសាក្សីមួយដែលនឹងមកមុនពេលកំណត់ មុនកាលកំណត់ ឧទាហរណ៍ គឺជាសាក្សី 2-TCW-976។ អ៊ីចឹងខ្ញុំសូមសំណូមពរឲ្យអង្គជំនុំជម្រះធ្វើយ៉ាងណាឲ្យយើងអាចពិគ្រោះឯកសារទាំងអស់នេះបានយ៉ាងលឿន អនុលោមទៅតាមវិធាន៨៧(៤)។ ហើយអ៊ីចឹងសូមឲ្យធ្វើយ៉ាងណាឲ្យបានឆាប់រហ័សបំផុត។ <ខ្ញុំមិនដឹងថាតើសហព្រះរាជអាជ្ញាមានបំណងដាក់សំណើសុំបែបនេះ ឬក៏យ៉ាងណានោះទេ ប៉ុន្តែយ៉ាងហោចណាស់បើមានសក្ខីកម្មពីដំបូងមួយរបស់សាក្សីនេះ នោះបញ្ហាគឺត្រូវដោះស្រាយជាបន្ទាន់។ ដូច្នេះ>ខ្ញុំសូមទាក់ទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះលើចំណុចនេះ។ ហើយក្នុងពេលនេះដែរ ខ្ញុំឃើញមានសំណើ<សុំបង្ហាញឯកសារ>មួយ<ទៀត>ពីសំណាក់ព្រះរាជអាជ្ញាដែរ គឺឯកសារ<E319/50> ចុះនៅថ្ងៃទី<០១> កក្កដា។ <ហើយជាថ្មីម្តងទៀត មានឯកសារចំនួន១៤ ដែលគួរឲ្យចាប់អារម្មណ៍ ហើយក៏សូមបញ្ជាក់ថា ឯកសារទាំងអស់នេះមានសក្តានុពលឲ្យរួចទោស>ទាក់ទងនឹងផ្នែកបោសសម្អាតនេះ អ៊ីចឹងយើងសុំអនុញ្ញាតចូលពិគ្រោះឯកសារនេះឲ្យបានឆាប់រហ័សផងដែរ ព្រោះថា ត្រូវឲ្យគោរពអនុលោមតាមវិធាន៨៧(៤)នេះ ធ្វើយ៉ាងណាធ្វើឲ្យបានឆាប់រហ័សបំផុត។

[១០:៤៣:១០]

**លោក វីល្លៀម ស្មីត៖**

នេះជាសំណើសុំឯកសារ<លេខ F2/4/2/5> ដែលជាសេចក្ដីសម្រេចមួយបានបង្ហាញរួចមកហើយ ហើយដែលបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាតុលាការកំពូល ហើយអង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតឲ្យបង្ហាញឯកសារនេះ។ <ប៉ុន្តែ>មិនទាន់មានឯកសារនេះ នៅឡើយទេ។ ដូច្នេះប្រហែលជាយើងអាចត្រូវធ្វើការរៀបចំនៅពេលពិសាបាយថ្ងៃត្រង់ ដើម្បីដាក់បង្ហាញនូវឯកសារនេះ។ <>អង្គជំនុំជម្រះតុលាការកំពូល<បានឆ្លើយតបនឹងសំណើយើង> ប៉ុន្តែយើងមិនទាន់ទទួលបានឯកសារនេះនៅឡើយទេ។ ហើយទាក់ទងទៅនឹងឯកសារ E3/19/50 ជាសំណើសុំឲ្យដាក់បង្ហាញឯកសារផងដែរ គឺមានឯកសារចំនួនពីរទាក់ទងទៅនឹងសាក្សីដែលមេធាវីការពារក្ដីបានលើកឡើងនេះ។ បើសិនណាជាអង្គជំនុំជម្រះអនុញ្ញាតឲ្យបង្ហាញឯកសារនេះ នៅថ្ងៃនេះម្ដងទៀត ខ្ញុំជឿជាក់ថា មន្ត្រីច្បាប់របស់អង្គជំនុំជម្រះអាចធ្វើការបង្ហាញបាន ប៉ុន្តែចំណុចសំខាន់នោះ គឺដាក់បង្ហាញឯកសារ ដែលត្រូវបង្ហាញ ត្រូវសួរសាក្សីបន្ទាប់<ពី>អ្នកជំនាញ ហង់រី ឡូកា។

[១០:៤៤:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបញ្ជាក់ ទាក់ទងទៅនឹងការសុំបញ្ជូនឯកសារ គឺឯកសារ F2/4/2/5 តុលាការកំពូលបានឲ្យយើងពិគ្រោះឯកសារមួយបាន គឺឯកសារលេខរៀងទី១៧ នៃឧបសម្ព័ន្ធនៃសំណើសុំដាក់ឯកសារនេះ គឺអង្គជំនុំជម្រះបានឲ្យយើងចូលមើលបានតែតាមនីតិវិធីទេ។ ក៏ប៉ុន្តែព្រះរាជអាជ្ញាគាត់បានធ្វើសំណើភ្ជាប់ជាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផង និងសាលាកំពូលផង។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេច ហើយនិងធ្វើយ៉ាងណាឲ្យយើងទទួលពិគ្រោះឯកសារបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមការបំភ្លឺអំពីសំណាក់សហព្រះរាជអាជ្ញា។ ខ្ញុំយល់ឃើញថា មានការដាក់សំណើមួយទៅចំពោះមុខតុលាការកំពូល គឺឯកសារ F2/4/2/5 ដែលចុះនៅថ្ងៃ២២ កក្កដា។ ហើយអង្គជំនុំជម្រះចង់សួរ ថាតើសំណើនេះគឺដាក់ជូនមកសាលាដំបូងដែរឬក៏យ៉ាងណា? តើមានដាក់សំណើនេះមកអង្គជំនុំជម្រះសាលាដំបូងដែរឬទេ?

**លោក វីល្លៀម ស្មីត៖**

<គេបានប្រាប់ខ្ញុំថា ឯកសារនោះត្រូវ>បានដាក់ជូនទាំងអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាអង្គ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជំនុំជម្រះតុលាការកំពូលផងដែរ <ហើយបានទទួលការកត់សម្គាល់ទាំងពីរ។ នេះជាអ្វីដែលគេបានប្រាប់យើង>។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំយល់។ ឥឡូវក្នុងករណីទាំងពីរនេះ គឺថាសំណើ F2/4/2/5 ហើយនិងសំណើ E319/50 ហ្នឹង តើមានការអនុញ្ញាតអំពីសហចៅក្រមស៊ើបអង្កេត ដើម្បីបញ្ជូនឯកសារទាំងអស់នេះមកក្នុងសំណុំរឿងនេះយើងហើយឬនៅ? ពីព្រោះថាអ្នកដែលមានសិទ្ធិអំណាចក្នុងការសម្រេចនោះ គឺសហចៅក្រមស៊ើបអង្កេតនោះទេ។ បើសិនជាសហចៅក្រមស៊ើបអង្កេតអនុញ្ញាត បាន។

[១០:៤៧:០៥]

**លោក វីល្លៀម ស្មីត៖**

យើងខ្ញុំនឹងជូនដំណឹងទៅមន្ត្រីច្បាប់នៅពេលពិសាបាយថ្ងៃត្រង់។ ក៏ប៉ុន្តែយើងខ្ញុំបានធ្វើការជូនដំណឹងនេះ ដាក់ជូនសំណើនេះទៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

ជាការពិតណាស់ ខ្ញុំដឹងថាសហព្រះរាជអាជ្ញាគាត់អាចបញ្ជូនឯកសារទាល់តែមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែនៅពេលដែលគាត់ដាក់សំណើមានឧបសម្ព័ន្ធ ហើយភាគីមិនអាចចូលពិគ្រោះបាន។ អ៊ីចឹងខ្ញុំគិតថាអង្គជំនុំជម្រះ បើតាមនីតិវិធីនោះត្រូវតែឲ្យភាគីចូលពិគ្រោះបាន យើងមានតែឧបសម្ព័ន្ធនោះទេ។ អ៊ីចឹងដូចខ្ញុំបានលើកឡើងពីកាលម្សិលមិញអ៊ីចឹង បើថាយើងមិនអាចពិគ្រោះឯកសារទាំងអស់នោះបានទេ យើងមិនអាចធ្វើអ្វីកើតទេ។ អ៊ីចឹងហើយខ្ញុំសូមស្នើជូនទៅអង្គជំនុំជម្រះធ្វើឲ្យអនុញ្ញាតឲ្យយើងពិគ្រោះបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា យើងមិនអាចធ្វើបានទេ។ ការសម្រេចផ្ទេរឯកសារនោះ គឺជាសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេត។ ហើយអ៊ីចឹងធ្វើយ៉ាងណាសូមឲ្យសហព្រះរាជអាជ្ញា គាត់ធ្វើការងារចាំបាច់ដែលត្រូវធ្វើ។ យើងនឹងពិនិត្យមើលថ្ងៃនេះ តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យភាគីអាចពិគ្រោះឯកសារទាំងអស់នោះបាន។

[១០:៤៨:៣៤]

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01329799



បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោកសាក្សី ខ្ញុំជាសហមេធាវីអន្តរជាតិការពារលោក នួន ជា។ ហើយខ្ញុំនឹងសួរសំណួរខ្លះៗទៅលោកនៅព្រឹកនេះ និងរសៀលនេះផងដែរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរសំណួរភ្ជាប់ពីសហព្រះរាជអាជ្ញារងជាតិ ពាក់ព័ន្ធទៅនឹងគោលនយោបាយរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រឹកមិញនេះ លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិថា លោកបានក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជានៅដើមឆ្នាំ ១៩៧៧។ ក្នុងនាមជា ក្នុងឋានៈជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា តើលោកមានទឹកឃើញ ឬក៏ចងចាំនូវអ្វីដែលពេលនោះ គេហៅថាសីលធម៌១២ប្រការដែរឬទេ?

[១០:៥០:១៥]

2-TCW-1005៖

**ឆ៖** បាទ បញ្ហានេះខ្ញុំសូមបកស្រាយជូនដែរ បញ្ហាបក្ស ចូលបក្សកុម្មុយនីស្តកម្ពុជាគឺនិយាយសីលធម៌១២ប្រការគឺល្អណាស់។ អាហ្នឹងខ្ញុំបកស្រាយពីសីលធម៌ណា គឺសីលធម៌១២ប្រការក៏ចាំ។ ក្រោយមកមានសីលធម៌ល្អ គុណធម៌ធាតុពិត តួនាទីអីទាំងអស់គឺ ធាតុពិតបើនិយាយពីច្បាប់បក្សគឺល្អណាស់ បើខ្ញុំនិយាយពីជំនាន់នោះវិញ។ បាទ សូម្បីតែម្ទេសមួយផ្លែ មិនឲ្យបេះ អ្នំសូម្បីតែចេសមួយសរសៃមិនឲ្យប៉ះ។ អាហ្នឹងនិយាយពីសីលធម៌។ អ្នំតួនាទីធាតុពិត គុណធម៌ ដឹកនាំមានគុណធម៌ ពីស្អីៗពាក្យ និយាយរួមពាក្យពេចន៍ក្នុងនុំងដែលពេលប្រជុំ ពេលចូលបក្សហើយនេះ ឲ្យដឹកនាំល្អ តួនាទីល្អ ក៏ប៉ុន្តែក្នុងហ្នឹង បក្សគឺដឹកនាំដោយឡែក។ ដល់អ៊ីចឹងទៅ វាការច្របូកច្របល់ នែ៎អាពេលហ្នឹងដែលខ្ញុំនិយាយ បើសិនណាជាច្បាប់បក្សកុម្មុយនីស្តគឺល្អណាស់។ អាហ្នឹងខ្ញុំនិយាយពីការចូលបក្ស ស្បថសច្ចាប្រណិធានចំពោះមុខបក្ស។ អាហ្នឹងខ្ញុំនិយាយបកស្រាយជូនលោកមេធាវី ខ្ញុំចង់បកស្រាយបញ្ហាហ្នឹង។ ពេលដែលចូលបក្ស ស្បថសច្ចាប្រណិធាន ថាបើខ្ញុំមិនស្មោះត្រង់ចំពោះបក្ស បើខ្ញុំបម្រើបក្សមិនបាន ខ្លួនខ្ញុំគឺប្រគល់ជូនបក្ស អត់មានស្តាយស្រណោះអី សម្រាប់ខ្លួន បុគ្គលខ្លួនទេ។ អាហ្នឹងខ្ញុំនិយាយពីបក្ស

កុម្មុយនីស្តដែលស្បថចូល។ ដល់អ៊ីចឹងទៅ អាចិត្ត អារម្មណ៍មួយគិតថា យើងខំធ្វើល្អ តែអ្នកផ្សេងធ្វើមិនល្អ នែ៎អាហ្នឹងដែលខ្ញុំចង់និយាយត្រង់នុ៎ងហើយ ដែលខ្លួបខ្លាចគ្នា លែងទុកចិត្តគ្នា។ បុគ្គលមួយលែងហ៊ានមាត់រកគ្នា។ ដល់ខាងគេមុន គេលែងហ៊ានមាត់រកក្រោយ អាក្រោយលែងហ៊ានមាត់រកមុន។ អាហ្នឹងដឹកនាំដោយឡែក។ អាហ្នឹងខ្ញុំចង់និយាយពីដល់ពេលចូល "ខ" ហ្នឹង ខ្ញុំឆ្លើយហ្នឹងបំភ្លឺ ដោយយោគយល់ថា បើនិយាយពីច្បាប់ចូលបក្ស សីលធម៌ និងគុណធម៌ ធាតុពិត អាហ្នឹងនិយាយពីកាលពីចូល។ តែដល់ពេលចូលធ្វើហើយ ខ្លាចគ្នាទៅវិញទៅមក លែងទុកចិត្តគ្នា នែ៎មកពីប្រវត្តិរូបនេះ។

[១០:៥២:២៤]

អាហ្នឹងដូចខ្ញុំនិយាយខាងដើម ពីម្សិលខ្ញុំនិយាយបញ្ហាហ្នឹងហើយ ខុសប្រវត្តិរូប។ អ្នប្រវត្តិរូបអ្នកនាំចូលក្បត់ ចាប់បាត់។ អ្នកក្រោយមិនដឹងជានរណា គ្នាភ័យអ៊ីចឹងទៅ ខ្លាចលែងហ៊ាន។ អ្នកពីត្បូងលែងហ៊ានមកជើង អ្នកជើងលែងហ៊ានទៅលិច ខ្លាចគ្នាទៅវិញទៅមក ដល់អ៊ីចឹងដល់ហ្នឹងក្នុងបក្សពីរបក្សបី អាហ្នឹងខ្ញុំអត់យល់ទេ កាលពីជំនាន់ហ្នឹង ខ្ញុំនៅក្មេង។ តែដោយឡែក ដល់និយាយពីរឿងការស្បថចូលបក្សហ្នឹង គឺឲ្យមានសីលធម៌ល្អ ការរស់នៅល្អ។ អាហ្នឹងបញ្ហាពេលដែលប្រជុំ គឺនិយាយអ៊ីចឹងហើយ តែដល់មកចូលអនុវត្ត ៗអត់បានទេ។ ទៅជាមានការប៉ះទង្គិច ចោទប្រកាន់អីហ្នឹង។ ដល់ចុងក្រោយ មកណេះ មកដល់ចុងក្រឡាប់ចាក់ចុង៧៨ហ្នឹង ចាប់ផ្តើមអុកឡុកហើយ។ អាយួនចូលផង អាយើងនេះទាស់គ្នាផង លែងទុកទុកចិត្តគ្នាដូចថា កងពល១១៧លែងទុកចិត្ត៥០២ ៗលែងទុកចិត្ត១៦៤។ អាហ្នឹងខ្ញុំនិយាយពីកងទ័ព។ តែខាងមូលដ្ឋាន បែបលើសនេះទៅទៀត។ ហ្នឹងខ្ញុំនិយាយឲ្យឃើញអាបញ្ហានេះសិន។ ហ្នឹងសួរខ្ញុំមិញប៉ុណ្ណឹង ខ្ញុំសុំឆ្លើយបកស្រាយប៉ុណ្ណឹងចុះ។

**ស៖** តើលោកចាំទេថា ប្រការណាមួយក្នុងចំណោមសីលធម៌ទាំង១២ប្រការនេះ មាននិយាយអំពីការកសាងគ្រួសារដែរទេ? មានគោលការណ៍ណាដែលសម្រេចអំពីការរៀបការ ឬក៏អំពីការកសាងគ្រួសារនោះទេ?

[១០:៥៤:១០]

**ឆ៖** បាទ បញ្ហាហ្នឹងខ្ញុំអាចនៅចាំបានខ្លះ តែវាមិនបានលម្អិត។ តែបើក្នុងឯកសារធ្វើល្អតែបុគ្គល ដូចជាខ្ញុំនិយាយមិញអ៊ីចឹង។ ឥឡូវចង់និយាយថា ក្នុងហ្នឹងមើល ខ្ញុំនៅចាំបានអំពីការត្រួតពិនិត្យជីវិតឲ្យល្អ។ អាហ្នឹងខ្ញុំនិយាយពីចំពោះ -- អាហ្នឹងចង់និយាយ អាហ្នឹងខ្ញុំនិយាយពីគុណធម៌ណា ថាចំពោះអ្នកដឹកនាំ ស្នេហាជាតិកាន់តែចង់ឲ្យជាតិរុងរឿង តែចំពោះអ្នកមានគ្រួសារ ក៏ចង់ឲ្យគ្រួសារនោះ

ល្អ អ្នកៗ!ទី១ បើឪពុកម្ដាយដែលមានកូនស្រី ចង់ឲ្យកូនស្រីមានប្ដីល្អ។ ឪពុកម្ដាយដែលមានកូនប្រុស ចង់ឲ្យកូនប្រុសនោះ មានប្រពន្ធល្អ។ នោះចំពោះនិយាយពីប្រជាជនធម្មតាហ្នឹង ខ្ញុំនៅចាំច្បាប់ហ្នឹងបានមួយចំនួនដែរ។ តែដោយឡែក ចំពោះយើងអ្នកដឹកនាំ ក៏ចង់ឲ្យរឹតតែល្អលើសនេះ។ តែដោយឡែក ដឹកនាំដោយឡែកពីគ្នានេះ ភូមិភាគនិរតី ស្ដេចត្រាញ់មួយ, ភូមិភាគបូព៌ា ស្ដេចត្រាញ់មួយ, ភូមិភាគបស្ចិមស្ដេចត្រាញ់មួយ, ភូមិភាគពាយ័ព្យ ស្ដេចត្រាញ់មួយ, ភូមិភាគឧត្តរ ស្ដេចត្រាញ់មួយ, ភូមិភាគកណ្ដាលស្ដេចត្រាញ់មួយ។ នេះដែលខ្ញុំចង់និយាយថា ប្រវត្តិហ្នឹងដែលខ្ញុំនៅចាំបាន ត្រង់ថា ដល់អ៊ីចឹងទៅ ច្បាប់ដែលៗនិយាយឲ្យល្អនោះ លែងមានហើយ។ ដូចថា ហ្នឹងខ្ញុំៗនិយាយឲ្យហួសៗតួនាទីខ្ញុំបន្តិចចុះ។ តែអាហ្នឹង គ្រាន់តែការយល់ឃើញរបស់ខ្ញុំ ឬក៏ខ្ញុំធ្លាប់ទៅតាមតំបន់ ដូចបូព៌ា ក៏ខ្ញុំធ្លាប់ដឹកគ្រាប់ទៅនុ៎ង។ មកខាងឧត្តរនេះ ក៏ខ្ញុំធ្លាប់ដឹកសម្ភារៈឲ្យមកយកម្ហូបអាហារត្រីងៀតឲ្យទ័ព ក៏ខ្ញុំអាចឆ្លងចូលកាត់ឧត្តរ ទៅតាមស្ទឹងត្រែង យកពីទន្លេសាបទៅអ៊ីចឹងទៅ។ ដល់អ៊ីចឹង ខ្ញុំឃើញវាខុសពីមួយកន្លែងៗ ខុសគ្នាទាំងអស់ជំនាន់នោះ។

[១០:៥៦:00]

ដល់អ៊ីចឹងបាត់គុណធម៌នេះ បាត់គុណធម៌ដែលល្អ ដែលគាត់ខំនិយាយឲ្យល្អថា សីលធម៌ល្អ គោរពស្រឡាញ់គ្នា សមមិត្ត មិត្ត អាហ្នឹងពាក្យហ្នឹង "មិត្ត" ហ្នឹងគឺជាយុទ្ធជនធម្មតា ហៅមិត្ត។ តែសមមិត្ត ថ្នាក់ដឹកនាំ "សមមិត្ត" ហ្នឹងពាក្យល្អ។ តែដល់យើងខាងក្រោមនេះ គ្រាន់តែឈ្លបភូមិ ឈ្លបឃុំ អាឈ្លបអីគេសហករណ៍ស្អីៗនេះ ធ្វើបាបប្រជាជន ចុងក្រោយនេះ ដែលខ្ញុំទើបនឹងដឹង៧៨ យួនចូលហើយនេះទេ។ បើពីមុនមកខ្ញុំបានដឹងអ៊ីចឹងទេ បើអ៊ីចឹងមិនមែនកងទ័ពទៅវាយយួនដល់ផ្លាយប៉ុន្មានខេត្តមុខនោះទេ អាហ្នឹងខ្ញុំនិយាយពីបញ្ហាហ្នឹង បកស្រាយជូនលោកមេធាវីចុះ។ វាច្របូកច្របល់ លែងទុកចិត្តគ្នាត្រង់នុ៎ង។ បាទ សូមអរគុណ។

**ស៖** តើលោកចាំខ្លឹមសារ គោលការណ៍<ទី>៦ នៃទង់បដិវត្តដែលមិនឲ្យមានឥរិយាបថណាបំពារបំពានទៅដល់ស្ត្រី ឬក៏រំលោភបំពានទៅលើស្ត្រីទេឬ គោលការណ៍ទី៦?

**ឆ៖** បញ្ហានុ៎ង ខ្ញុំវាអត់បានចាំអស់ទេ ព្រោះបើនិយាយទៅ វាយូរឆ្នាំហើយ តែវាគ្រាន់ចាំត្រង់ថាបើក្នុងអង្គប្រជុំអី កងទ័ព គឺឲ្យមានសីលធម៌ល្អចំពោះប្រជាជន ចំពោះក្នុងអង្គភាពអី អាហ្នឹងវាៗមានហើយ តែខ្ញុំគ្រាន់តែវារឿងក្នុងៗក្នុងឯកសារ វាមិនបានចាំអស់ក៏ពិតមែន តែគ្រាន់តែការយល់ដឹងខ្ញុំនៅចាំបានអ៊ីចឹងហើយ។ តែដោយឡែក ដល់បុគ្គលដឹកនាំដោយឡែកនេះណ៎ា ការខ្ចបខ្ចាតគ្នានេះណ៎ា អា

ហ្នឹងខ្ញុំចង់និយាយអាគោលការណ៍នុ៎ង ខ្ញុំវាអត់បានចាំទាំងអស់ទេ ក្នុងប្រាំយ៉ាង គុណធម៌ប្រាំយ៉ាង សីលធម៌១២ប្រការអីហ្នឹង ក៏អត់បានចាំទាំងអស់ដែរ តែគ្រាន់នៅចាំថា យកតែពាក្យសីលធម៌មួយមកនិយាយគឺបានន័យថាល្អណាស់ហើយ។ តែដោយឡែក ដល់ខ្លួបខ្លាចគ្នាទៅវិញទៅមក ត្រង់ថា ពេលដែលបានកាន់អំណាច លែងស្គាល់គ្នាបណ្ដោយ ហ្នឹងខ្ញុំនិយាយឲ្យត្រង់ចំពោះមុខច្បាប់ចុះ។ ព្រោះថា ទី១អី? ថ្នាក់នៅភូមិ ថ្នាក់អី ប្រធានសហករណ៍ចុះ ស្រាប់តែដកពីប្រធានសហករណ៍ហ្នឹង ទៅដល់ស្រុកផ្សេង ឡើងគណៈស្រុកបាត់ ឡើងគណៈតំបន់បាត់។ ដល់ឮឡើងធំអ៊ីចឹង អ្នកនៅនេះគ្នាប៉ានតវ៉ាឯណា បាត់អាសីលធម៌ល្អ ដែលរដ្ឋខំ ដែលថាខំអាពេលដែល នោះដូចខ្ញុំកាលពីតូចក្រូចឆ្មារមក ដែលៗដែលខ្ញុំអាយុ១៦, ១៧ឆ្នាំដែលខ្ញុំចូលទ័ពនុ៎ង ដែលប្រជុំមកកសាងគ្នាឲ្យល្អណាស់ សីលធម៌ល្អ បាទ ខ្ញុំ ស្រាប់តែដល់ឡើងមេក្រុម ទៅមេកងតូច អញ អា មឹងបាត់ហើយ ខុសពេលៗប្រជុំនោះបាត់ហើយ។ ហ្នឹងសូមអរគុណ ខ្ញុំបកស្រាយសង្ខេប។

[១០:៥៩:១៩]

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ថារយៈពេលនេះវាយូរហើយ មិនអាចឲ្យចាំពាក្យពេចន៍ចំៗដែលមាននៅក្នុងគោលការណ៍សីលធម៌១២ប្រការនេះទេ។ តើលោកដឹងទេថា នៅក្នុងគោលការណ៍សីលធម៌១២ប្រការនេះ មានគោលការណ៍ពីរពាក់ព័ន្ធទៅនឹងការកសាង ការបង្កើតគ្រួសារដែលភាគីទាំងពីរនេះ គឺទាំងស្ត្រី និងបុរសត្រូវយល់ស្របគ្នា យល់ព្រមគ្នា<ជាមុនសិន>។ ហើយ<ទី២>សមូហភាព<ត្រូវ>យល់ស្របដែរ<> គឺថាពេលហ្នឹង ទើបគេអាចរៀបការទៅបាន។ អ៊ីចឹងមែនទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបខាងដើមហើយ បញ្ហាដែលឯកសារហ្នឹងមានហើយ តែខ្ញុំមិនបានចាំអស់ទេ បញ្ហានុ៎ង។ ពេលដល់ឈ្នះ៧៥ហើយនេះ ឬ៧៦ហើយនេះ មកក្រឡាប់ចាក់ទេ ពី៧៦ឯកសារ ៗហ្នឹងវាមានមុនហើយ មុន៧៥។ អាហ្នឹងមុនដែលខ្ញុំចូលបក្សទៅទៀត។ តែដោយឡែកចង់និយាយថាដល់តែពេលនេះ អាពេលដែលបានអំណាចហើយនេះ ដែលខ្ញុំចង់និយាយត្រង់នុ៎ងទេ ដែលចង់ផ្ដោតថា ខ្ញុំវាអត់បានចាំទេ ព្រោះកាលហ្នឹងខ្ញុំអត់ទាន់ចូលបក្សដែរ តែគ្រាន់តែនៅចាំបានថាអាសីលធម៌រស់នៅត្រូវឲ្យមានល្អអីអ៊ីចឹងទៅ មានមែន។ អាហ្នឹងកាលពីអត់បានអំណាចនោះណា៎ ខ្ញុំចង់និយាយអំណាច ៗដូចថាធ្វើយកបក្សកុម្មុយនីស្តគឺត្រូវការអី ការកសាងប្រទេស គឺត្រូវការឯករាជ្យ ម្ចាស់ការនោះ។ អាហ្នឹងដល់អ៊ីចឹងទៅ វាយកអាឯករាជ្យ ម្ចាស់ការមកវាភ្លេចអស់អាសីលធម៌ហ្នឹងរលីងទៅ។ អារឿងថាគេឲ្យខ្ញុំចាំអារឿងការកសាងគ្រួសារហ្នឹង ការរំលោភបំពានដែលខ្ញុំនិយាយចុងកន្ទុយ អាមុនសម្រាកអំមិញនេះ គឺខ្ញុំ

និយាយអាឃើញជាក់ស្ដែង។ តែអាក្នុងឯកសារនោះ ខ្ញុំដឹងថាមានមួយចំនួនដែលល្អហើយ។ ល្អត្រង់ថា គាត់ប្រជុំមកឱ្យយើងអី កសាងប្រទេសល្អស្អីៗទៅ តែដល់អាពេលទៅអនុវត្ត បុគ្គលអនុវត្តនេះ តាមតំបន់មួយៗ តាមស្រុកមួយៗ វាទៅជាចាក និយាយមួយហ៊ុនហ្នឹង វាឡើងទៅមួយចំអាម មួយចំអាមឡើងទៅមួយតឹក ខុសគ្នាទាំងអស់។ សូម្បីទៅរៀនសាលាជាមួយគ្នា ចេញមកវិញ អនុវត្តផ្សេងគ្នា។ អាហ្នឹងខ្ញុំចង់និយាយបកស្រាយជូនអីចឹងចុះ ព្រោះខ្ញុំវាអត់បានចាំ ប៉ុន្តែខ្ញុំដឹងនៅចាំតែរឿងសីលធម៌ហ្នឹង គឺនៅចាំបាន។ អាហ្នឹងដែលគាត់បានអប់រំរហូត តាំងពីពេលនោះមកដល់ពេលនេះ។

[១១:០២:០៤]

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ ប៉ុន្តែតើលោកយល់ស្របជាមួយខ្ញុំទេ ថាគោលការណ៍បដិវត្តមួយក្នុងចំណោមគោលការណ៍បដិវត្តទាំងពីរក្នុងការរៀបការហ្នឹង គឺថាទាំងភាគីខាងបុរសទាំងស្ត្រីត្រូវតែមានការយល់ព្រមគ្នាចំពោះការរៀបការនេះជាមុនសិន។ អីចឹងមែនទេ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ សាក្សីបានឆ្លើយហើយ ថាគាត់មិនបានដឹងអំពីគោលការណ៍នៃការរៀបការនេះទេ។ <ហើយបើគាត់មិនបានដឹងផង ខ្ញុំគិតថា មិនអាចសួរគាត់ថា "តើលោកយល់ស្របទេ>ថា គោលការណ៍"<>ក <ឬ> ខ។ <សាក្សីបាននិយាយថា គាត់មិនដឹងពីគោលការណ៍ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំនោះទេ។> យ៉ាងដូច្នេះទៅ គួរសួរតាមរបៀបផ្សេងវិញ។ ហើយយើងខ្ញុំក៏ស្នើសុំឱ្យផ្ដល់លេខយោងឯកសារចំពោះគោលការណ៍សីលធម៌ទាំង១២ប្រការនេះផងដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំអាចអានអំពីគោលការណ៍នេះ គឺឯកសារE3/765។ ពេលនេះយើងមានតែអង់គ្លេស ERNគឺ 00539994 គឺឯកសារ E3/765 ដែលគោលការណ៍នេះនិយាយថា "សម្រាប់បញ្ហាបច្ចុប្បន្នសម្រាប់ការបង្កើតការកសាងគ្រួសារ <គឺគ្មានឧបសគ្គអ្វីទេ។> គឺយើងយោងទៅលើតែគោលការណ៍ពីររបស់បក្ស។ ទី១ ភាគីទាំងសងខាងត្រូវតែយល់ព្រមគ្នា។ ទី២ សមូហភាពយល់ព្រម យល់ស្រប

ហើយបន្ទាប់មកគឺថាការរៀបការនឹងអាចរៀបចំទៅបានហើយ។ <ដូចបានអានទូវ>គោលការណ៍ទី៦ គឺមិនត្រូវបំពារបំពានទៅលើស្ត្រី<> លោកនឹកឃើញអំពីគោលការណ៍ទី៦នេះទេ?

[១១:០៤:២៦]

2-TCW-1005៖

**ឆ៖** បញ្ហាលោកបានបកស្រាយហ្នឹងត្រូវហើយ តែដោយឡែកបញ្ហាដែលទី៦ ថាមិនឲ្យនេះ មិនឲ្យបំពារបំពាន ថាឲ្យគោរពសិទ្ធិនារីនេះ អាហ្នឹងក៏ខ្ញុំវាមិនបានចាំ មិនបានគិតដូចឥឡូវទេ។ តែដោយឡែកខ្ញុំចង់និយាយជម្រាបលោកថាអ៊ីចេះ ថាចង់និយាយថា បុគ្គលដឹកនាំដោយឡែក ពិតមែនថាឯកសារមានអ៊ីចឹងមែន តែដោយឡែកនេះ បុគ្គលអង្គភាពមួយៗ ដូចថាវាទៅជាផ្សេងៗគ្នា ចង់និយាយប្រជុំទៅក្នុង ដូចថាក្នុងមួយសាលាហ្នឹងមានបីបួនពាន់នាក់អ៊ីចឹង ចេញទៅវិញខុសគ្នាទាំងអស់។ ឧទាហរណ៍ខ្ញុំចង់និយាយឲ្យចំអ៊ីចេះចុះ។ រឿងហ្នឹងដែលកាឡែឯកសារហ្នឹង ដែលគ្រោះថ្នាក់ដល់ៗសព្វថ្ងៃនេះ។ ហ្នឹងខ្ញុំបកស្រាយចុងក្រោយ គឺសូមជម្រាបជូនលោកមេធាវីឲ្យចំអ៊ីចេះចុះ។ ព្រោះលែងទុកចិត្តគ្នាហើយ អ្ហ៎! ដល់ការបង្ខំគ្នា អ្ហ៎! ដល់អ៊ីចឹងទៅ អាឯកសារដែលថាមានស្រាប់ហ្នឹង គឺវាលែងហើយ វាលែងប្រើការហើយអាហ្នឹងនោះ។ ខ្ញុំចង់និយាយថា វាលែងប្រើការ អាសមូហភាពហ្នឹង គឺឲ្យដាក់របស់រួមទាំងអស់ហើយ ដល់របស់រួមទាំងអស់ វាទៅក្លាយរួមទាំងអស់។ យូរៗទៅ ទៅជាប្រពន្ធក៏រួម ប្ដីក៏រួមទាំងអស់ហើយ មានអីទៀត។ អាសមូហភាពហ្នឹង គឺមានហើយ ឲ្យប្រមូលទាំងអស់ សម្ភារៈអី កម្មសិទ្ធិសមរម្យ កូនស្លាបព្រាមួយតូចហ្នឹង។ អាហ្នឹងខ្ញុំនៅចាំបាន។ បើយកអាហ្នឹងបានល្អទាំងអស់គ្នា មានអី។ តែផ្ទុយទៅវិញម៉េច បើខ្ញុំឃើញទៅ អាហ្នឹងខ្ញុំនិយាយច្បាប់មានហើយ តែដល់បុគ្គលមិនអនុវត្តនេះ ជាក់ស្ដែង ធ្វើបាបធ្វើទុក្ខនេះ អាហ្នឹងខ្ញុំនិយាយជាក់ស្ដែង អត់និយាយក្នុងច្បាប់ទេ។ បាទ សូមបកស្រាយជូនប៉ុណ្ណឹង។

**សៈ** ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត។ ខ្ញុំចង់សួរលោកអំពីពេលវេលាដែលលោកបានផ្ទេរទៅខេត្តក្រចេះ ក្នុងឆ្នាំ នៅដើមឆ្នាំ៧៧។ នៅពេលដែលលោកទៅខេត្តក្រចេះហ្នឹង តើលោកអាចរៀបរាប់ប្រាប់បានទេ អំពីស្ថានភាពនៅទីនោះ ទាក់ទងជាមួយនឹងវៀតណាម? ថាតើមានការប៉ះទង្គិចកើតរួចមកហើយ ឬមួយក៏ថាមានជម្លោះប្រដាប់អាវុធ អាចជាការឈ្លានពានដោយកងទ័ពវៀតណាម ឬក៏យ៉ាងម៉េចដែរ? តើនៅពេលដែលលោកទៅដល់ភ្លាមនោះ តើស្ថានភាពនៅក្រចេះនោះយ៉ាងម៉េចដែរ?

[១១:០៧:០៦]

**ឆ៖** បាទ បញ្ហានេះ ខ្ញុំសូមបកស្រាយជូនបាន។ ពេលដែលទៅហ្នឹង គឺសភាពការណ៍នៅ៧៧ ហ្នឹង គឺយួនបុកគ្រប់ៗតំបន់។ ដល់អ៊ីចឹង នៅក្រចេះហ្នឹងគឺវាយកបានត្រឹមចម្ការស្នួល ចម្ការកៅស៊ូស្នួល ហើយ។ បានជាយកទ័ពទៅជួយទប់ត្រង់នុ៎ង ព្រោះទ័ពត្រង់នុ៎ងមានតិច។ ខាងនុ៎ង គឺមាន បើខាងជួរភាគឦសានហ្នឹង មានមួយកងពល៨០១នៅខាងរតនគិរី, ៩២០នៅមណ្ឌលគិរី ឯក្រចេះមានតែទ័ពតំបន់ តែ៧០៧ហ្នឹងមួយទេ មានទ័ពតំបន់ អត់មានទ័ពភូមិភាគទេ។ ដល់អ៊ីចឹង បានបំបែកអង្គភាព អ៊ំសឿង នេះ គាត់បំបែកចេញឲ្យខាងលើ ឲ្យទៅជួយវ៉ៃ១១៧ហ្នឹង គឺទៅជួយទប់នៅក្រចេះហ្នឹង គឺចម្ការកៅស៊ូស្នួល យួនយកបាត់ហើយ។ ពេលដែលទៅហ្នឹង គឺយួនបុកមកដល់ចម្ការកៅស៊ូហើយ ដែលពួកខ្ញុំទៅនេះ ក្រោយនេះ ដែលទៅ៧៧ អ្នកចូលដើម៧៧។ ការពិតជំនាន់នុ៎ង គឺទាំងបុកទាំងអស់។ នៅត្រង់ខាងបូព៌ា ហ្នឹងក៏បុក ខាងនិរតីហ្នឹងក៏បុក ប៉ុន្តែក្រចេះចូលមុនគេ គឺចូលចម្ការកៅស៊ូស្នួលតាំងពី ខ្ញុំទៅដល់ហ្នឹងគឺ ដល់ចម្ការកៅស៊ូហើយ បានវ៉ៃទៅវិញមួយសា។ ទៅដល់ហ្នឹងបុកទៅវិញ ស្លាប់ទ័ពអស់មួយចំនួន ព្រោះ វាដាក់អង្គប់ មីននៅគល់កៅស៊ូខាងលិច យើងទៅក្រាបលុតជង្គង់ខាងលិច ត្រូវគ្រោះថ្នាក់នៅបាក់ៗភ្លៅ ស្លាប់បីបួនថ្ងៃយក ទម្រាំតែយកបានរោងចក្រអាររឈើយ៉ូមវិញ។ ហើយអ៊ីចឹងបានជាយើងរុញទៅដល់ នោះ យើងវ៉ៃទៅចូលស្រុកវាម្តងហើយ។ ទៅដល់ណោះ ប៉ុន្តែដីស្រែយួន វាវាល កាលជំនាន់នោះ។ បាន ជាដល់ចុង៧៨នេះ បុកមកមួយសាទៀត។ អាហ្នឹងនិយាយសភាពការណ៍វៀតណាមពីជំនាន់នុ៎ង ថាយួន ក៏បាន វៀតណាមក៏បាន និយាយអ៊ីចឹងចុះ។ ហ្នឹងខ្ញុំទៅទាន់ហេតុការណ៍ហ្នឹង គឺបុកចូលមកហើយ បាន យកទ័ពទៅពីនេះទប់។

[១១:០៩:១០]

**ស៖** ចំពោះពេលវេលាដែលវាកើតឡើង តើនៅពេលដែលកងទ័ពវៀតណាមឈ្លានពាន ឬវាយប្រហារមកដល់ខេត្តក្រចេះហ្នឹង តើលោកទៅដល់ហើយ ឬមួយក៏មិនទាន់ទេ?

**ឆ៖** ពេលចូល--។ បញ្ហាខ្ញុំបកស្រាយអំមិញ ចង់និយាយថាពេលដែលពួកខ្ញុំទៅក្រោយហ្នឹង គឺ យួនវាយកបានចម្ការកៅស៊ូស្នួលហើយ។ តែទៅដល់វិញ បានទប់បានជាប់វិញ ទៅនៅត្រឹមខាងកើតផ្លូវ ជាតិវិញ។ នៅត្រឹមអាវាលស្រែមុខកន្លែងផ្លូវជាតិលេខ៧នេះ នៅទប់ត្រង់ហ្នឹងបានជាប់យូរដែរ លុះត្រា តែ ដល់តែពាក់កណ្តាលចុង៧៨នេះ ចូលបុកមកមួយសាទៀត។ លើកនេះវាបុកពីរបីសា រុញគ្នាចេញ រុញគ្នាឡើងហ្នឹង។ អាហ្នឹងចង់និយាយថាសភាពការណ៍ហ្នឹង វាតឹងតែងនៅត្រង់នុ៎ង។

**ស៖** ខ្ញុំសួរលោកអំពីបញ្ហានេះ ព្រោះថា នៅក្នុងចម្លើយមួយដែលលោកបានផ្តល់ភស្តុតាង

ទាក់ទងទៅនឹងពេលវេលាដែលកងកម្លាំងវៀតណាមឈ្លានពាន គឺឯកសារ E3/10622 សំណួរចម្លើយ ៩៦។ លោកបាននិយាយថា វៀតណាមចូលមកក្នុងពេលចូលឆ្នាំខ្មែរ ឆ្នាំ៧៧។ អ៊ីចឹងបានន័យថា នៅក្នុង <ពាក់កណ្ដាល>មេសា ឆ្នាំ៧៧ តើអ៊ីចឹងមែនទេ?

[១១:១០:៥៦]

**ឆ៖** ដូចការបកស្រាយរបស់ខ្ញុំនុ៎ង មិនដឹងជាដូចជាថ្ងៃ ក្នុងចូលឆ្នាំ៧៧នេះ ដូចអត់មានបាននិយាយទេ ព្រោះអាហ្នឹងមិនដឹងឮយ៉ាងម៉េច បកយ៉ាងម៉េចទេ។ គ្រាន់តែខ្ញុំចង់ថា ពេលដែលខ្ញុំទៅខែ៣ ឆ្នាំ៧៧ហ្នឹង យួនវាបុកបានចូលចម្ការកៅស៊ូស្នួលហើយ។ អានេះខ្ញុំនិយាយតែមួយច្រកហ្នឹងទេ។ ដោយរុញទៅវិញបានមួយសា ក៏ពេលហ្នឹងបុកមកមួយសាទៀត តែបុករុញគ្នាចុះ រុញគ្នាឡើង មកនៅទើរត្រឹមចម្ការកៅស៊ូហ្នឹងដដែល។ តែដល់វាញឹកញាប់ពេក ព្រោះរុញគ្នាទៅរុញគ្នាមក អត់មានយូរប៉ុន្មានដែរទេ វារុញបានដី ដីឆ្ងាយដែរ វាចម្ការកៅស៊ូធំណាស់ មួយឃុំឃ្សឹមដែរ មួយឃុំស្នួលហ្នឹង។ ដល់អាបញ្ហាហ្នឹងឲ្យលម្អិត ខ្ញុំចាំបានតែអារឿងថា អាពេលទៅហ្នឹង ហើយដល់ពេលបុកមកទៀត ក៏មិនបានរៀបរាប់អស់ដែរ ព្រោះវារុញទៅ មួយខែពីរខែរុញគ្នាម្ដង មួយខែពីរខែរុញទៅមកម្ដង។ ហ្នឹងលោកព្រះរាជអាជ្ញាពិនិត្យមើលសាដើមទៅ វាអាចនិយាយចន្លោះត្រង់ហ្នឹងមួយដឹង។ ប៉ុន្តែបើពេលចូលឆ្នាំហ្នឹង តាមខ្ញុំដឹង ខ្ញុំយល់ថា ពេលនុ៎ងអាចប្រហែលជាខាងខ្ញុំ បាក់មកមួយសា ហើយបានរុញទៅមួយសាទៀត ព្រោះដល់វាខ្ញុំមិនបានទៅវៃផ្ទាល់ឯណា ខ្ញុំនៅជញ្ជូនសពផង ដឹកស្បៀងឲ្យទ័ព ដឹកគ្រាប់ឲ្យទ័ពផង នៅកន្លែងប្រព័ន្ធតេអូ វិទ្យុទាក់ទងនេះផង។ ដល់អ៊ីចឹង ក្រែងលោអ្នកវៃផ្ទាល់នោះ អាហ្នឹងរុញទៅរុញមក អាហ្នឹងវាឯកសារទូរលេខអីវាមាននៅកន្លែងមន្ទីរហើយ។ តែវាឆេះអស់ហើយ ឆេះខ្ទេចខ្ទីរអស់ហើយ មិនមានបានសំណល់សល់អីទុកភស្តុតាងទេ ឯកសារទូរលេខអីនោះ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹងសិន។

**ស៖** ឥឡូវនេះ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់បន្តិចដើម្បីឲ្យខ្ញុំច្បាស់ថា ខ្ញុំយល់អ្វីដែលលោកនិយាយ។ ខ្ញុំជឿថា កន្លងមកលោកនិយាយថា លោកមកដល់ខេត្តក្រចេះ ក្នុងខែមីនា ឆ្នាំ៧៧។ ហើយនៅពេលដែលលោកមកដល់ហ្នឹង គឺវៀតណាមបានកាន់កាប់ចម្ការកៅស៊ូនៅស្នួលរួចហើយ។ តើអ៊ីចឹងមែនទេ?

[១១:១៣:៣១]

**ឆ៖** បាទ បញ្ហាហ្នឹង ខ្ញុំបានបកស្រាយហ្នឹងហើយ ថាហ្នឹងហើយ ចម្ការកៅស៊ូហើយ។ ខ្ញុំទៅដល់ យួនមកដល់ចម្ការកៅស៊ូហើយតើ។ តែគ្រាន់ថារុញគ្នាទៅ រុញគ្នាមក នៅទើរតែត្រឹមហ្នឹងដដែល បានរុញទៅហួសផ្លូវបន្តិចអ៊ីចឹងមក ប្រហែលជាកន្លះខែមួយខែអ៊ីចឹង រុញមកវិញទៀត។ វាកេលបុក

ខាងជើង ខាងត្បូង ក្រឡឹងចុះក្រឡឹងឡើង កៀងគ្នាចូលយកតែចម្ការកៅស៊ូនោះហើយ។ អាហ្នឹងខ្ញុំចង់និយាយហ្នឹងហើយ។

**ស៖** តើលោកដឹងទេថា ហេតុអ្វីកងទ័ពវៀតណាមមកត្រួតត្រាចម្ការកៅស៊ូនៅស្នួលនេះ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! សាក្សីឆ្លើយ! ឆ្លើយ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្តាប់ខ្ញុំឮទេ?

**2-TCW-1005៖**

**ឆ៖** ឮតើ។ ដាក់អាន៎ុងដដែលតើ! អាឡូ!

**ស៖** ឥឡូវនេះខ្ញុំសួរលោកឡើងវិញ។ តើលោកដឹងទេ ហេតុអ្វីបានជាកងទ័ពវៀតណាមឈ្លានពានទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ហើយមកកាន់កាប់ចម្ការកៅស៊ូស្នួលនោះ?

[១១:១៥:២៣]

**ឆ៖** លោកសួរខ្ញុំអ៊ីចឹង ខ្ញុំថ្នាក់ក្រោមមិនអាចនិយាយត្រង់បានថាអ៊ីចេះ។ ខ្ញុំសូមបកស្រាយទៅចុះ។ ព្រោះមិនមែនបុកតែចម្ការកៅស៊ូស្នួលមួយទេ បុកទូទាំងប្រទេស។ អាហ្នឹងខាងប៉ូប៉ាក៏បុក ខាងស្រុកបារិតនោះក៏បុក ហ្នឹងខាងប៉ូប៉ាហ្នឹង ស្រុកបារិតក៏បុក ខាងចន្ទ្រា ត្រឡោកបែក ខាងចន្ទ្រាដែលជាប់នឹង នៅកំពង់ចាមនេះក៏បុក ខាងមេមត់នេះ ទៅខាងរតនគិរីក៏បុក។ ដូច្នេះមិនមែនតែត្រូវតែក្រចេះមួយទេ តែគ្រាន់តែក្រចេះ ទិសខ្ញុំកាន់កាប់ ដែលខ្ញុំដឹង។ តែបុកៗទូទាំងប្រទេស គឺបុកទាំងអស់ ពី៧៧ ហ្នឹងគឺបុកទាំងអស់។ សូម្បីតែខាងនិរតី តាកែវហ្នឹងក៏បុក។ ដូច្នេះមិនដឹងជាយ៉ាងណាអាន៎ុង សួរខ្ញុំ ដល់សួរខ្ញុំអ៊ីចឹង ខ្ញុំឆ្លើយអត់កើតទេ ត្រង់ថាមិនដឹងជាយ៉ាងម៉េច បើគេបុកមកទាំងអស់ហើយ។ ព្រោះឥឡូវនៅបាក់ដៃខាងអង្គរបុរីក៏បុក នៅកំពតនោះក៏បុក។ អាហ្នឹងខ្ញុំនិយាយពិសោធពី៧៧ទេ រហូត៧៧ បើតាមដឹងយកមកផ្តាយឯណាជិតកោះអណ្តែតនេះ អាហ្នឹងស្រុក ខាងស្រុកម្តាយខ្ញុំនៅគិរីវង់ អាហ្នឹង៧៧ ដែលខ្ញុំទៅក្រចេះហើយនេះ។ ដល់អ៊ីចឹងបុកទូទាំងប្រទេស ៧៧យួនបុកទាំងអស់។ ត្រង់ថាឲ្យចង់បានអីមិនមែនថាចម្ការកៅស៊ូមួយទេ អាហ្នឹងខ្ញុំនិយាយទូទាំងប្រទេសបណ្តោយចុះ ព្រោះអាហ្នឹងសារទូរលេខអាចទាក់ទងគ្នាដឹង អ្នកណាបុកត្រង់ណា ត្រង់ណា បុកត្រង់ណា ព្រោះអាជំនាន់នោះ សារទូរលេខប្រើដៃហ្នឹងលឿនណាស់ លឿនចង់លឿនជាង ប៉ុនមិនលឿនជាងកុំព្យូទ័រទេ អានោះនៅបកនៅអីទៀត។ អា

ហ្នឹងខ្ញុំចង់បកជម្រាបជូនលោកៗព្រះរាជអាជ្ញាអ៊ីចឹងវិញចុះ។

**ស៖** នៅក្នុងការស្ដាប់ចម្លើយ <ឬបទសម្ភាសន៍>របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា E3/9647 អង់គ្លេសមានលេខ <01212283>, ខ្មែរមានលេខ 00975723, បារាំងមានលេខ 00996564។ លោកបាននិយាថា "យួនវាយបុកខ្លាំងនៅឆ្នាំ៧៧"។ តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា វៀតណាមហ្នឹងវាយបុកខ្លាំងហ្នឹង?

[១១:១៧:៥០]

**ឆ៖** បញ្ហាលោកសួរខ្ញុំនេះ ក៏ដូចខ្ញុំសូមឆ្លើយ ថាឆ្លើយដដែលថា បើតាមខ្ញុំដឹង កងទ័ពដែលចេញៗទៅការពារព្រំដែនទាំងអស់នេះ ពី៧៧ ចេញគ្រប់កង ចេញគ្រប់ភូមិភាគ។ ពាយ័ព្យក៏ទៅជួយនៅនិរតី និរតីមកជួយបូព៌ា អ្ហ៎!៧៧ហ្នឹងណ៎ា។ អ្ហ៎! ខាងពលទី១ បំបែកមក១១៧ មកក្រចេះនេះ ក៏មកទប់ព្រំដែន ព្រោះនិយាយរួមបុក៧៧ យួនបុកៗទាំងអស់ហ្នឹង ដែលលោកនិយាយថាបុកអំមិញហ្នឹង គឺបុកហ្នឹងហើយ វាបុក អាហ្នឹងពាក្យថាបុកហើយ តែគេបុកមក រុលមកនោះ។ អាហ្នឹងខ្ញុំនិយាយជាមួយឯកសារកម្ពុជា ខ្ញុំចង់និយាយថា និយាយរួមយួនបុកទូទាំងប្រទេស មិនមែនថាតែច្រកខ្ញុំកាន់កាប់ហ្នឹងមួយទេ ដឹងឮហ្នឹងមួយទេ។ ហើយភូមិភាគព្លិសានហ្នឹង បើគិតទៅ ភូមិភាគព្លិសាន ខ្ញុំនិយាយឲ្យចំទៅ មានតែពីរកងពលទេ មានតែ៨០១រតនគិរី មាន៩២០មណ្ឌលគិរី ដល់ក្រចេះមានតែទ័ពតំបន់ អត់មានទ័ពភូមិភាគ ឬមជ្ឈិមអីនៅចូលទេ។ ដល់អ៊ីចឹងទៅ បានជាយកទៅនេះ ដាក់ក្រចេះហ្នឹង កាត់ចេញពីភូមិភាគព្លិសានទៀត ទៅជាតំបន់មជ្ឈិមគ្រប់គ្រង។ អានេះខ្ញុំនិយាយឲ្យចំថា ខេត្តក្រចេះហ្នឹងមួយ កងពលដែលខ្ញុំទៅថ្មីនេះ។ ហើយខ្ញុំនិយាយជាមួយឯក ខាងឯកសារកម្ពុជា គាត់មកសួរខ្ញុំ គាត់និយាយអង្គុយប្រាជ្ញគ្នានឹងតុអ៊ីចឹង ខ្ញុំក៏មិនដឹងថាគាត់ដាក់ទូរស័ព្ទថតសំឡេងអី ចេះតែព្រោកប្រាជ្ញទៅតាមនឹកឃើញខ្លះអីខ្លះអ៊ីចឹង គាត់សួរនាំពីនេះពីនោះ បន្តិចមួយសន្ទុះទៅ គាត់យក គាត់សួរថាឈ្មោះនេះ ០៧ឈ្មោះអ្នកណា? ខ្ញុំក៏ដំបូង និយាយហួរហែៗ គាត់យកឈ្មោះ បងលាង យកឈ្មោះបងលាង មក ថាស្គាល់ទេ ខ្ញុំថា បងលាងចាប់បាត់ហើយ។ អាហ្នឹងបានរឿងហ្នឹងជាប់វិទ្យាស្ថានស្រាវជ្រាវ ជាប់សួរខ្ញុំទៅ ក៏ខ្ញុំមិនបានដឹងថាគាត់ថតសំឡេង។ ដល់ហើយបានអ្នកមកជិតហ្នឹង គេថា នោះថតសំឡេងឡើងពីរ។ អើ! និយាយហួសអស់ហើយ អាហ្នឹងខ្ញុំត្រង់ជាមួយលោកព្រះរាជអាជ្ញាទៅចុះ។ ខ្ញុំមានយោបល់ប៉ុណ្ណឹង។

[១១:២០:០៣]

**ស៖** ឥឡូវនេះខ្ញុំដឹងហើយថា លោកសាក្សីមិនមែននៅសមរភូមិមុខទេ ប៉ុន្តែខ្ញុំចង់ដឹងថា តើ

លោកអាចប្រាប់បានទេ ថាការវាយប្រហារពីកងទ័ពវៀតណាមហ្នឹង នៅក្នុងខែមីនា-មេសា ៧៧នោះ ថាតើវាជាការវាយប្រហារបែបភ្ញាក់ផ្អើល បែបមិនជូនដំណឹងមុន ឬមួយក៏ថា វាដូចថាកងទ័ពកម្ពុជាប្រជាធិបតេយ្យដឹងមុនថា វៀតណាមនឹងវ៉ៃចូលមក?

**ឆ៖** បញ្ហានេះ ខ្ញុំសូមបកស្រាយជូនលោកព្រះរាជអាជ្ញាឲ្យបានក្បោះក្បាយជាងនេះបន្តិចក៏ថាបាន ប៉ុន្តែវាអាចវែងពេកក៏ថាបានដែរ។ ត្រង់ថា ការងារយោធាខាងលើគាត់ដឹងហើយ ខាងលើគាត់ដឹងមុនហើយ តែដល់សារទូរលេខបញ្ជូនមក ចង់ថា ឥឡូវសភាពការណ៍យួនបុកហើយ ដាក់សារទូរលេខមកតែប៉ុណ្ណឹង។ សភាពការណ៍យួនបុកហើយ ឲ្យយើងត្រៀមកម្លាំងទប់ ត្រង់ទប់ជាប់មិនជាប់ មិនដឹងទេ គ្រប់សមរភូមិ គឺខាងលើណែនាំដឹងហើយ ខាងលើដឹងមុនហើយ ដឹងថាយួនបុក។ ពីអគ្គសេនាធិការគាត់បានបញ្ជូនសារទូរលេខ បញ្ជូនគ្រប់កងពលហើយ។ ដល់អ៊ីចឹងទៅគាត់ដឹងថា សភាពការណ៍យួនបុកហើយ ឲ្យយើងទប់ ដល់អ៊ីចឹងសភាពការណ៍យួនបុកមែន។ ដល់បុកមែន វាមិនមែនមកចេញអាច្រកយើងការពារទៀត វាវាងនាំវ៉ៃយើងពីក្រោយទៀត។ ដល់អ៊ីចឹងវាក្នុងផ្ទៃក្នុងនេះ ដែលចង់និយាយនេះចូលក្នុង “ខ” ផ្ទៃក្នុងនេះ ដល់សួរខ្ញុំអ៊ីចឹង។ ដែលបោសសម្អាតផ្ទៃក្នុង អាផ្ទៃក្នុងគ្នាឯងហ្នឹងអូសចូលជាមួយយួនទៅ អូសកម្លាំងវ៉ៃគ្នាចុះឡើង។ អាហ្នឹងដែល ដល់អ៊ីចឹងចូល “ខ”ហ្នឹងហើយ ដែលរឿងហ្នឹង។ អ៊ីចឹងដល់សួរខ្ញុំអ៊ីចឹង ដល់បកសាក្រោយវិញបន្តិច។ ហើយកងទ័ពដែលទប់មិនជាប់ ដោយសារបញ្ហាអ៊ីចឹង វាមិនទុកចិត្តគ្នានោះ ខ្លាចបាក់ខាងនេះ ខាងនោះ។ បាទ ខ្ញុំមានប៉ុណ្ណឹងសិន។

[១១:២២:១៩]

**ស៖** នៅក្នុងការសម្ភាស E3/9647 អង់គ្លេសមានលេខ<01212318>, ខ្មែរមានលេខ 0097 5746 និងបារាំងមានលេខ 00996586។ លោកបាននិយាយពីរដងថា៖ “យើងមិនបានវ៉ៃយួនទេ យើងមិនបានវ៉ៃយួន យួនវាមកឈ្លានពានយើងមុន”។ តើការដែលលោកនិយាយនេះ មានន័យថា កងទ័ពវៀតណាមដែលជាអ្នកចាប់ផ្ដើមការប៉ះទង្គិច ឬក៏ការជម្លោះប្រដាប់អាវុធមុននៅក្នុងឆ្នាំ៧៧ ខែមេសា នុ៎ងមែនទេ?

**ឆ៖** បាទ ពាក្យហ្នឹងដែលខ្ញុំនិយាយ គឺពាក្យពិត ព្រោះតាមព្រំដែនទាំងអស់ គឺរង្គោះរង្គើទាំងអស់ ដូចខ្ញុំបកស្រាយថាដដែលៗចុះ។ អាហ្នឹង ហ្នឹងហើយ រឿងហ្នឹង ខ្ញុំនិយាយហ្នឹងគឺរឿងពិតបាទ។ ព្រោះខាងយើងទ័ពតិចណាស់ កម្លាំងតិច បើនិយាយកម្លាំងទ័ព បើរាប់ទៅអត់បាន១០០.០០០នាក់ទេទូទាំងប្រទេស ដែលតាមខ្ញុំសរុប ក្នុងមួយកងពលៗនេះ ដែលខ្ញុំដឹង កាលនោះនៅក្មេងមែន តែគ្រាន់តែ

ឆ្លងកាត់។ ដោយឡែកចង់និយាយអ៊ីចឹងទៅ បានថាដល់រង្គោះរង្គើទាំងអស់អ៊ីចឹង។ ហើយសារទូរលេខគ្រប់កងពលមួយៗមានគ្រប់ បញ្ជូនសារទៅវិញទៅមកដឹង តាមសមរភូមិមួយៗ។ នេះខ្ញុំសូមជម្រាបជូនលោកព្រះរាជអាជ្ញា។ ពាក្យហ្នឹងខ្ញុំនិយាយពិត ព្រោះយើងអត់មានបានទៅឈ្លានពានគេទេ។ អាហ្នឹងខ្ញុំនិយាយពីបញ្ហាព្រំដែន ពីជំនាន់៧៧មកទេ។ ប៉ុន្តែរកាំរកូសតាំងពី៧៦ ខ្ញុំនៅអីគិរីវង់នោះ រកាំរកូសគ្នាពី៧៦មក រហូតបាន៧៧ហ្នឹង ចាប់ផ្តើមខ្លាំង ដល់ខ្ញុំ--។ អាហ្នឹងដែលខ្ញុំនិយាយហ្នឹង ខ្ញុំបកស្រាយចំមែនហើយបញ្ហានុ៎ង។ បាទ សូមអរគុណ។

**ស៖** <ប៉ុន្តែ ដើម្បីឲ្យយល់ច្បាស់>--

[១១:២៤:២៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន សូមអរគុណ។ មិនមែនជាការជំទាស់ទេ ប៉ុន្តែជាកំណត់ត្រា គឺថាឃ្លាដែលបានលើកឡើងមកឲ្យសាក្សីស្តាប់ពាក់ព័ន្ធទៅនឹងចលនារបស់វៀតណាមនោះ ឃ្លានុ៎ងគឺត្រូវបានដកចេញពីពេលវេលាមួយដែលសាក្សីគាត់និយាយ នៅចុងឆ្នាំ៧៨ទេ គឺពាក់ព័ន្ធទៅនឹងការចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ក៏ដូចជានៅពេលដែល មាស មុត បាននិយាយជាមួយពួកគេអំពីការឈ្លានពានរបស់វៀតណាម។ ដូច្នេះដើម្បីបញ្ជាក់ឲ្យច្បាស់ក្នុងកំណត់ត្រាប្រតិចារឹក គឺថា គាត់និយាយអំពីចុងឆ្នាំ៧៨ មិនមែនដើមឆ្នាំ៧៧ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងសួរបន្តទៅទៀត ដោយសួរសាក្សីដោយមិនយោងទៅលើអ្វីដែលសួរពីមុនមកទេ។ ខ្ញុំមិនច្បាស់ថាអ្វីដែលព្រះរាជអាជ្ញានិយាយច្បាស់ ត្រឹមត្រូវ មិនត្រឹមត្រូវនោះទេ។ ដូច្នេះអ្វីដែលខ្ញុំចង់សួរគឺថានៅខែមីនា ៧៧ វៀតណាមចាប់ផ្តើមការឈ្លានពាននេះមុន ឬមួយក៏អ្នកណាជាអ្នកចាប់ផ្តើមការឈ្លានពាននេះ?

**លោក វីល្លៀម ស្មីត៖**

លោកប្រធានអ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាសាក្សី គាត់និយាយអំពីការប៉ះទង្គិចនៅតាមព្រំដែន នៅ

តាមព្រំដែនវៀតណាម ហើយវាមានការប៉ះទង្គិចជាច្រើន។ ដូច្នេះគួរតែសួរថាមានការប៉ះទង្គិចកន្លែងណាដែលមេធាវីការពារក្ដីចង់សួរដើម្បីឱ្យការសួរសំណួរនេះច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សាក្សីបាននិយាយរួចមកហើយនូវកន្លែងជាក់លាក់មួយចំនួន គឺការឈ្លានពាន។ ដូច្នេះខ្ញុំកម្រិតកំណត់ត្រឹមតែអ្វីដែលគាត់បានដឹងតែប៉ុណ្ណោះ គឺការឈ្លានពាននៅស្នួល ហើយនិងការចូលកាន់កាប់ចម្ការកៅស៊ូ។ តើកងទ័ពវៀតណាមជាអ្នកចាប់ផ្ដើម គឺជាអ្នកចាប់ផ្ដើមការឈ្លានពានហ្នឹងមុន ឬមួយក៏យ៉ាងម៉េចដែរ នៅពេលដែលគេចូលមកចម្ការកៅស៊ូស្នួលនោះ?

[១១:២៧:២០]

**2-TCW-1005៖**

**ឆ៖** បាទ ដូចខ្ញុំបកស្រាយហើយខាងដើមអ៊ីចឹង គឺខ្ញុំទៅដល់ហ្នឹង គឺយួនមកដល់ហ្នឹងបាត់ហើយ។ ដល់អ៊ីចឹងទៅការវ៉ៃគ្នារុញចុះរុញឡើង ក៏វានៅតែត្រង់នុង វាអត់ៗ កិលទៅមុខក៏មិនទៅ មកក្រោយក៏មិនមក កិលបានទៅមុខបន្តិចមកក្រោយបន្តិច។ ដូច្នេះវានៅនឹងទ្រឹងនៅត្រង់ហ្នឹង គឺការពិតទៅខាងយើងទ័ពយើងតិចទេ យើងមានបានទៅវ៉ៃឯណា។ តែដោយឡែក ដល់ប្រហែលជាដើម៧៨វិញ អាហ្នឹងវ៉ៃចូលបានមួយចំនួនវិញ ព្រោះខឹងថាគេវ៉ៃមកយើងណា។ តែដល់ក្នុងចុង ប្រហែលជាចុង៧៨ហើយ ប្រហែលជាទៅដល់នៅប៉ុន្មានថ្ងៃផង គេបុកមកវិញយកអាហ្នឹងមកដល់វិញដដែល។ ដូច្នេះវាប្រទាញប្រទង់គ្នាតំបន់យោធា។ បើនិយាយ វាមិនបានចាំច្បាស់ឱ្យលម្អិត តែគ្រាន់តែក្នុងហ្នឹងរុញទៅរុញមករហូត។ ដល់៧៨មក អាហ្នឹងដល់និយាយផ្ដោតមក៧៨ បានបុកមកភ្នំពេញបណ្ដោយ អាហ្នឹងខ្ញុំនិយាយ។ ប៉ុន្តែបើថានៅទ្រឹង នៅទ្រឹងតាំងពី៧៧មកម្ល៉េះ។ ការពិតខាងយើងអត់មានបានទៅវ៉ៃគេមុនទេ ខាងគេមកវ៉ៃមុនទេ អាហ្នឹងបើនិយាយការងារយោធា អាហ្នឹងបញ្ជាក់ជូនលោកព្រះរាជអាជ្ញាប៉ុណ្ណឹងចុះ។ ហើយក៏យ៉ាងណា មានអីបន្តទៀត អាហ្នឹងខ្ញុំបកស្រាយបានខ្ញុំបកបានជូន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយ ប៉ុន្តែឥឡូវនឹងគឺថាជិតដល់ម៉ោងដប់មួយ សាមសិបនាទីទៅហើយ លោកប្រធាន តើយើងគួរសម្រាក ឬមួយក៏យ៉ាងម៉េច?

[១១:២៨:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរ ការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់ សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន ត្រឡប់ទៅបន្ទប់រង់ ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ វិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៥នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅ មេធាវីការពារក្តីលោក នួន ជា សួរដេញដោលចំពោះសាក្សី លោកសាក្សី យើងជាប្រធានអង្គជំនុំជម្រះ មានបំណងសួរបញ្ជាក់លោកបន្តិចបន្តួចពាក់ព័ន្ធនឹងសក្ខីកម្មរបស់លោក ដែលលោកបានផ្តល់រយៈពេល ពីម្សិលមិញរហូតដល់ព្រឹកមិញ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សំណួរទី១ ពេលដែលលោកបានផ្លាស់ទៅឈរជើងនៅខេត្តក្រចេះ នៅឯក្រចេះនុំង សំណួរសួរថា តើកន្លែងដែលលោកទៅឈរជើងនៅក្នុងចន្លោះពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨ហ្នឹង វា នៅក្នុងតំបន់អ្វី ឈ្មោះអីកន្លែងនុំង ឬក៏នៅភូមិភាគណាដែរ បើតាមលោកចាំ?

[១៣:៣២:៤៩]

01329813



2-TCW-1005៖

**ឆ៖** បាទ នុំងវានៅក្នុងខេត្តក្រចេះហ្នឹង តែវានៅក្នុងស្រុកស្នួលមួយកន្លែង មន្ទីរខ្ញុំនៅក្នុងស្រុកក្រចេះមួយកន្លែងទៅ បាទ នៅក្រគរ ហៅស្ពានក្រគរ ខាងជើងក្រចេះប្រហែលជាដីពីរបីម៉ែត្រហ្នឹង។ ហ្នឹងដាក់កន្លែងផែ ដូចយកសម្រាប់សម្ភារៈពីភ្នំពេញទៅ។ ហើយនៅខាងព្រែកឆ្លូង ខាងស្រុកស្នួលនោះដាក់ឃ្លាំងសម្រាប់ផ្គត់ផ្គង់ទ័ពពីមុខ និងគ្រួសារយោធាដែលនៅកៀកខាងនោះ។ បាទ ហ្នឹងមន្ទីរពីរកន្លែងក្នុងកងកាលនុំង មានមន្ទីរពីរកន្លែងនុំង។

**ស៖** ប៉ុន្តែលោកដឹកទេ ដឹកថាកន្លែងដែលលោកទៅឈរជើងនៅប្រមាណពីរកន្លែង បីកន្លែងនៅខេត្តក្រចេះដែលលោកឆ្លើយអម្បាញ់មិញនេះ វានៅក្នុងតំបន់អ្វី ឈ្មោះអីដែរ តំបន់នុំង? ឬក៏ឋិតនៅក្នុងភូមិភាគណាដែរ?

**ឆ៖** បាទ កន្លែងហ្នឹងនៅខេត្តក្រចេះ តំបន់៥០៥ហ្នឹង ហើយនិងតំបន់៥០៥ហ្នឹង ក្រោយពីពួកខ្ញុំទៅនេះ គឺកាត់ចូលជាតំបន់ស្វយ័ត បានន័យថា តំបន់ដែលអត់ចំណុះឲ្យភូមិភាគព្រៃសានទៀតទេ។ អាហ្នឹងវានៅក្នុងមជ្ឈិមគ្រប់គ្រង បាទ។ ដូច្នេះនៅក្នុងនុំង គឺកងពលខ្ញុំអត់បញ្ចូលភូមិភាគ៥ -- ភូមិភាគព្រៃសានទេ គឺវានៅក្នុងមជ្ឈិមគ្រប់គ្រងផ្ទាល់។ សម្ភារៈអីឡើងមកយកភ្នំពេញផ្ទាល់ អត់មានពាក់ព័ន្ធអីជាមួយភូមិភាគទេ។

[១៣:៣៤:២៧]

**ស៖** ហើយចុះវាចំណុះមជ្ឈិមផ្ទាល់ កងទ័ពមជ្ឈិមផ្ទាល់ សួរថា ចុះនៅលោកដឹងទេថា តើកងពលរបស់លោក ១៧៧ហ្នឹងមានពេលណាមួយ ឬក៏មានត្រូវរាយការណ៍ទៅគណៈតំបន់៥០៥ ដែរឬទេ?

**ឆ៖** បាទ បញ្ហាកាលជំនាន់ខ្ញុំនៅ អត់មានទេ៥០៥ ព្រោះតំបន់ផ្សេង ព្រោះខាងកងពលនេះរាយការណ៍បញ្ជូនសារទូរលេខអីបញ្ជូនមកអង្គសេនាធិការបណ្ដោយ អត់មានពាក់ព័ន្ធអីជាមួយតំបន់ទេ។ តែបើទំនាក់ទំនងខាងបញ្ហាអី ខាងក្រោមៗដូចជាសេដ្ឋកិច្ច ហូបចុកអី ដូចថាអាចផ្គត់ផ្គង់ឲ្យទ័ពបាន ហ្នឹងខាងតំបន់ជួយ។ តែដោយឡែក សំខាន់សារទូរលេខស៊ីៗ រាយការណ៍សម្រាប់ដឹកសម្ភារៈដូចគ្រាប់ អាវុធយុទ្ធភណ្ឌអីស៊ីផ្សេងៗ គេមកយកទទួលពីរដ្ឋទៅបណ្ដោយ ពីអង្គសេនាធិការទៅបណ្ដោយបាទ។

**ស៖** បាទ អរគុណនូវសេចក្ដីបំភ្លឺ។ ហើយសំណួរមួយទៀត សួរថា លោកបានផ្ដល់សក្ខីកម្មៗកាលពីម្សិលមិញ ហើយអំពីលិខិតមួយដែលលោកបានឃើញដែលមន្ទីរ៨៧០បានហៅកម្មាភិបាលទៅ

ភ្នំពេញ។ ហើយសំណួរសួរថា តើនេះជាលើកទី១ ដែលលោកបានឃើញ ឬក៏បានឃើញបញ្ជាពី៨៧០ ទៅកាន់កងពល១៧៧ ឬក៏មានឱកាសណាផ្សេងទៀតដែលលោកបានឃើញបញ្ជាបែបនេះដែរឬទេ ពីមន្ទីរ៨៧០ ឬក៏ពីមជ្ឈិម ទៅកងពល១១៧ របស់លោក?

[១៣:៣៦:៣១]

**ឆៈ** បាទ ពីម្សិលមិញ ខ្ញុំបានបកស្រាយបញ្ហាសំបុត្រ ដែលម-៨៧០ ជូនហើយ។ តែដោយឡែក ចង់និយាយថា កន្លងទៅ មិនមានសំបុត្រដែលយកតាមរយៈជា១នីរសារយកទៅឲ្យទេ កន្លងទៅច្រើនបញ្ជូនសារតាមទូរលេខ។ ដល់១ដែលសំបុត្រមួយហ្នឹង ខ្ញុំទៅតែឃើញហ្នឹង១មួយហ្នឹង ដោយសារអី ដោយសារសភាពការណ៍ យួនបុកខ្លាំង វាច្របូកច្របល់ អាចយកសំបុត្រហ្នឹងមក១ដោយផ្ទាល់ហ្នឹង គឺចង់និយាយថា បើសារទូរលេខ ច្រើនតែបន្តិកន្លងទៅ សារបកបីបួនជាន់អី នៅតែគេចាប់បាន នៅតែគេ នៅតែហៅគ្រាប់ផ្លោងជាន់ខ្លួនឯង គ្នាឯងហ្នឹង។ ហ្នឹងចង់និយាយជម្រាបលោកព្រះរាជអាជ្ញាឲ្យ១បានដឹងថា រឿងសារទូរលេខនេះ ជួនកាលបកបួនជាន់ ឬបីជាន់ជំនាន់នោះ ប្រើដៃផង នៅតែ១គេចាប់បាន អក្ខរៈដែលយើងធ្វើ វាខុសគ្នាជាងយោធាពីមុនសម្ងាត់ហើយ នៅតែបែកការណ៍ ដោយសារ ដូចថា ដល់តែយកមកផ្ទាល់អ៊ីចេះ បានដឹងថាពិត។ ប៉ុន្តែសារហ្នឹង មិនដឹងជាយកមកតាមរយៈយន្តមុន ឬក៏ជើងមុន ជើងក្រោយអី គឺខ្ញុំឃើញ បានឃើញសំបុត្រទើបតែមួយហ្នឹងទេ។ តែពីមុន១មក តាមរយៈសារទូរលេខបញ្ជូនតាមរយៈក្នុងមន្ទីរខ្ញុំ ឬក៏៥០២ គាត់អីឲ្យអ៊ីចឹង គាត់ទៅប្រជុំធម្មតា ដូចថា ទៅតាមកប៉ាល់ដឹកសម្ភារៈអីអ៊ីចឹងទៅ មកវិញគាត់តាមការហោះហើរអី ហ្នឹងជាធម្មតា។ អានេះយើងសុំលើកជូនលោកព្រះរាជអាជ្ញាប៉ុណ្ណឹង។

**សៈ** បាទ អរគុណ ហើយតាមបទពិសោធន៍របស់លោក ដែលលោកបានធ្វើការងារក្នុងឋានៈជាអនុប្រធានមន្ទីរកងពល១១៧ តើលោកបានដឹងដែរទេថា ហេតុអ្វីបានជាមន្ទីរ៨៧០ហ្នឹង បានចេញបញ្ជាដោយផ្ទាល់ទៅកងពល១១៧ ហើយដោយមិនធ្វើតាមមេបញ្ជាការ មិនធ្វើតាមរយៈភូមិភាគ -- មិនធ្វើតាមរយៈតំបន់ ប្រធានតំបន់ពិសេស៥០៥?

[១៣:៣៨:៤៦]

**ឆៈ** បញ្ហាហ្នឹង ដូចខ្ញុំបានជម្រាបលោកខាងដើមហើយ ចង់ថា តំបន់ ហើយនិងកងពល អត់ចំណុះគ្នាទេ។ ដូច្នេះសារអីកន្លងទៅ ច្រើនតែសារតាមរយៈសារទូរលេខ តែដល់ពេលនេះ ឃើញសំបុត្រមួយហ្នឹង គឺដូចថាសភាពការណ៍ច្របូកច្របល់ ដូចថាខ្លាចសារទូរលេខចាប់ប្រព័ន្ធទាក់ទងបានអ៊ីចឹងទៅ

អាហ្នឹងៗតាមការស្មានរបស់ខ្ញុំទេ ប៉ុន្តែដល់ឃើញយកទៅហ្នឹង គឺអ្នកយកសំបុត្រទៅហ្នឹង ក៏មិនមែននៅនឹងពួកព្រលានយន្តហោះដែរ គឺឈ្មោះ ធី ហ្នឹង សារទូរលេខ បងមុត នេះ។ ឈ្មោះ គង់ ក៏អ្នកបញ្ជូនសារ, ធី អ្នកបក។ ពីរនាក់ហ្នឹងបកទៅបកមក ដូចជាពីរនាក់ក្នុងហ្នឹង។ ដល់អ៊ីចឹងទៅ ឃើញសំបុត្រហ្នឹង យកមកឲ្យផ្ទាល់ មកដល់ហើយ ក៏ឡានហ្នឹងចេញទៅជើងទៅ ទៅថ្មគ្រែទៅអី ទៅសំបូរអីទៅ ភ្នំសំបុកអីទៅ ចេញទៅខាងជើងទៅ ហើយខ្ញុំក៏ទុកសំបុត្រហ្នឹងនៅនុ៎ងទៅ។ ហើយគេហុចឲ្យគាត់ហើយនៅនឹងនៅតុហ្នឹងហើយ ដល់ហើយគាត់ថា មើល វ៉េត ឯងអានសំបុត្របន្តិចមើល៍។ ហ្នឹង គាត់ឲ្យខ្ញុំអានមើល៍ ដល់មើលទៅ ខ្ញុំថាពូ – ប៉ុន្តែខ្ញុំហៅគាត់បង – ថា “នេះបង យន់ យកម៉ោងប្រាំបួន” ហ្នឹងឃើញសារហ្នឹង ដាក់តែប៉ុណ្ណឹងមក។ គ្រាន់តែសូមអញ្ជើញទៅភ្នំពេញ។ យន់ មកទទួលម៉ោងប្រាំបួន អត់មានដាក់អីច្រើន ដាក់តែប៉ុណ្ណឹងហ្នឹង។ ប៉ុន្តែគ្រាន់តែការខ្ទងសំបុត្រ ឃើញដាក់ “ម-៨៧០” តែប៉ុណ្ណឹងហ្នឹង។ ខ្ញុំថាអើយ បែបបានសំបុត្រផ្ទាល់ពីលើហើយ។ អាហ្នឹងជាក់ស្តែង គឺខ្ញុំសូមបកស្រាយប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សីដែលបានបញ្ជាក់បំភ្លឺចំណុចនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤០:២១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោក។ លោកថាពេលដែលលោកនៅក្រចេះ កងពល១១៧ រាយការណ៍ផ្ទាល់ទៅអគ្គសេនាធិការ។ ដូច្នេះតើធ្លាប់មានការទំនាក់ទំនងគ្នារវាងកងពល១១៧ និងមន្ទីរ៨៧០ដែរឬទេ? លោកនិយាយថា មានការរាយ-ការណ៍ទៅអគ្គសេនាធិការ អ៊ីចឹងខ្ញុំចង់ដឹងថាតើមានរាយការណ៍ទៅមន្ទីរម-៨៧០ទេ?

**2-TCW-1005៖**

**ឆ៖** បាទ បញ្ហាហ្នឹង ខ្ញុំសូមជម្រាបថាខាងខ្ញុំមិនដែលប៊ានរាយការណ៍រំលងទេ អត់ប៊ានរំលងទៅ៨៧០ទេ។ នេះដែលតាមរាយការណ៍ជាប្រចាំថ្ងៃ គឺអត់ប៊ានរាយការណ៍រំលងទៅ៨៧០ទេ ព្រោះសារនេះបញ្ជូនបានទៅអគ្គសេនាធិការ ឬមក៥០២ខាងៗជើងអាកាសនេះ គ្រាន់ជួយចម្លងឲ្យអីប៉ុណ្ណឹងបាន។ អានេះតាមសាររាយការណ៍ប្រចាំថ្ងៃ។ តែម-៨៧០ មិនអាចប៊ានឆ្លងបានទេ លុះត្រាតែគាត់វាយសារផ្ទាល់មក ដូចសភាពការណ៍អ៊ីអ៊ីចឹង គ្រាន់តែថាដាក់ “សភាពការណ៍ឃ្លួនបុកហើយ” ដាក់ត្រឹមតែ

ប៉ុណ្ណឹងអីមកហ្នឹង ខាងក្រោមធ្វើតាមតែប៉ុណ្ណឹងមក ត្រៀមទ័ពតែប៉ុណ្ណឹងទេ តែរឿងអីផ្សេងអត់មានទេ។

**ស៖** ជួនកាលនិយាយអំពីសំបុត្រ ពេលខ្លះទៅនិយាយអំពីទូរលេខ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ចំពោះលោកនោះ តើលិខិតហើយនិងទូរលេខហ្នឹងខុសគ្នាទេ? ហើយការរាយការណ៍ហ្នឹងរាយការណ៍តែតាមទូរលេខ ឬក៏មានលិខិតដែលមានដឹកតាមយន្តហោះពីភ្នំពេញមកនោះ ពី៨៧០មកផ្ទាល់នោះ តើមានអ៊ីចឹងទេ?

[១៣:៤២:៣៥]

**ឆ៖** បាទ អាហ្នឹងលិខិតគឺអត់មានទេ បើនិយាយខ្ញុំធ្លាប់ដែលរស់នៅកន្លងទៅ ភាគច្រើនគឺមិនអាចមានលិខិតពីគាត់មកទេ មិនអាចបានបញ្ជូនមកដល់ខាងពួកខាងខ្ញុំ ខាងក្រោមនេះទេ គឺចង់និយាយថា ភាគច្រើនខាងខ្ញុំពីមុនច្រើនប្រើសារ ៗនោះគឺបញ្ជាក់ពីគ្នាទៅវិញទៅមក ឧទាហរណ៍ការណែនាំពី ៥០២ ថាឥឡូវឲ្យជួយអន្តរាគមន៍អីអ៊ីចឹងមក អាហ្នឹងបញ្ជូនសារទូរលេខ បញ្ជូនគ្នាទៅវិញទៅមក តែលិខិត វាដាក់លិខិតផ្ទាល់ វាអត់មានទេ។ អ៊ីចឹងដូចបានខ្ញុំបានបញ្ជាក់ហើយ លិខិតនេះលិខិតមួយនេះមួយច្បាប់ ដែលឃើញថាម-៨៧០ហ្នឹង ខាងខ្ញុំ -- ខាងគាត់ក៏មិនទុកចិត្តថា ម-៨៧០ហៅដែរ ព្រោះថាកន្លងទៅមិនដែលមានសំបុត្រទេ មានតែតាមរយៈសារទូរលេខ។ តែដោយឡែកសភាពការណ៍ទាន់ហន់នេះ ដែលសភាពការណ៍ដែលអា៧៨នេះ អាបុកខ្លាំងនេះ បានចង់និយាយថាឃើញសំបុត្រមួយហ្នឹងក៏បងៗមួយចំនួន គាត់ភ្ញាក់ផ្អើលណាស់។ ដែលកន្លងទៅច្រើនតែតាមរយៈសារទូរលេខទាំងអស់ ភាគច្រើនគឺគាត់មិនដែលបាននិយាយរឿងផ្ទាល់ តាមផ្ទាល់ជាលិខិតលាយលក្ខណ៍ជាអក្សររបស់ខាងលើអីអត់ៗបានដែលមានទេ។ ហើយខ្ញុំឃើញចំណារមួយទៅ សារទូរលេខឲ្យខ្ញុំមើលកាលលើកណា លើកទី១ ដែលខ្ញុំមកលើកទី១នោះ ឃើញចំណារហ្នឹង អាហ្នឹងចំណារហ្នឹងឃើញអក្សរអ៊ំគាត់ចារ គ្រាន់តែថា "យួនបុក" អីហ្នឹង អាហ្នឹងឃើញគាត់ដាក់ហ្នឹង ដាក់តែប៉ុណ្ណឹងឯង។ អាហ្នឹងចំណារមាន -- អាហ្នឹងចំណារហ្នឹងគាត់ចំណារក្រោមសារទូរលេខទៀត សារទូរលេខបញ្ជូនសារ ហើយក្បាលសារប៉ុន្មានអ៊ីចឹងអាហ្នឹងដឹងហើយ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង សូមអរគុណ។

**ស៖** លោកនិយាយអំពីអ៊ំ <តើលោកដឹងទេ>អ៊ំ<>ណា<ខ្លះ>នៅ៨៧០ហ្នឹង<>? លោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេ ថាអ្នកណាជាអ្នកសរសេរទូរលេខ ឬក៏សរសេរសំបុត្រដើម្បីឲ្យកម្មាភិបាលឡើងមកភ្នំពេញនោះ?

[១៣:៤៤:៤១]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បើអ៊ីចឹងបានន័យថា លោកចង់បញ្ជាក់សាចុះសាឡើងបញ្ហាសំបុត្រ។ ខ្ញុំក៏សូមបញ្ជាក់ទៅវិញថា ពាក្យថា "អ៊ំ" ថ្នាក់ដឹកនាំគឺខាងខ្ញុំហៅ "អ៊ំ" ទាំងអស់។ អាហ្នឹងខ្ញុំនិយាយជំនាន់នោះណា។ ដល់អ៊ីចឹងដូចអ៊ំឥឡូវ៨៧០ ថាអ្នកណាដឹងហើយ ទៅអ៊ំអគ្គសេនាធិការអ្នកណាដឹងហើយ។ ដល់អ៊ីចឹងទៅដូចថាអ៊ំ បញ្ជូនអំមិញ ខ្ញុំនិយាយដែលសារ ដែលថាយួនបុកអ៊ីចឹង សារពីអគ្គសេនាធិការមកអ៊ីចឹង អ្ហ! អ៊ំគាត់ចំណារពីក្រោមថា យួនបុកហើយ។ គ្រាន់តែបញ្ជាក់តាមសារហ្នឹងមក សារហ្នឹងបញ្ជាក់មកតាមកងពលទៀតមកអ៊ីចឹងមក។ អាហ្នឹងចង់និយាយហ្នឹង "អ៊ំ"។ អាហ្នឹងខ្ញុំសូមបញ្ជាក់ជូនលោកឱ្យច្បាស់កន្លែងហ្នឹងបន្តិច។ បានន័យថា ៨៧០ ឱ្យតែថ្នាក់ដឹកនាំ ឱ្យតែគេនិយាយថ្នាក់ដឹក គឺដឹងថា មន្ទីរ៨៧០ គឺថ្នាក់ដឹកនាំហើយ។ ដល់អ៊ីចឹង ត្រូវហៅ "អ៊ំ" ទាំងអស់។ អ្ហ! អគ្គសេនាធិការក៏អ៊ំទាំងអស់។ អគ្គសេនា-ធិការរងក៏អ៊ំ។ ភាគច្រើនខាងខ្ញុំពីមុន ច្រើនហៅអ៊ីចឹង។ សូមអរគុណ។

**ស៖** តើលោកបែងចែកដាច់ពីគ្នាទេ រវាងអគ្គសេនាធិការ និងមន្ទីរ ម-៨៧០ នោះ? ហើយតើ <លោកអាចបញ្ជាក់បានទេ តើមានទំនាក់ទំនងអ្វីរវាង> មន្ទីរ៨៧០ ហើយនិង<>សុន សេន ហើយនិង <មេដឹកនាំផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យ>?

[១៣:៤៦:២៤]

**ឆ៖** តាមដែលខ្ញុំយល់ តាមដែលខ្ញុំដឹងមក គឺជាហូរហែ ធម្មតាបទបញ្ជាត្រូវចេញពី ម-៨៧០ មុន បានជូនមកអគ្គសេនាធិការហើយ។ ព្រោះគ្រាន់ខាងខ្ញុំពីក្រោម ត្រូវឆ្លងអគ្គសេនាធិការ អត់ប៉ានទៅដល់លើទេ។ ដល់អ៊ីចឹង អាហ្នឹងខ្ញុំនិយាយត្រឹមកងខ្ញុំចុះ អត់មានប៉ានដែលឆ្លងទៅដល់៨៧០ទេ ព្រោះអាហ្នឹង ទុកឱ្យខាងលើៗ គាត់ចាត់ចែងគ្នាទេ។ តែករណីពិសេសយ៉ាងណា អាហ្នឹងជាក់ស្តែង។ តែឆ្លងបោះសន្ធចរំលងភ្នំហើយ ដែលខុស អត់ប៉ានទេអាហ្នឹង អាហ្នឹងខ្ញុំនិយាយត្រង់ជម្រាបលោកមេធាវីតាមជាក់ស្តែង។

**ស៖** តើលោកដឹងថា មានការទាក់ទងគ្នារវាង មាស មុត និង សុន សេន ទេ?

**ឆ៖** បាទ បញ្ហាទុំង ធម្មតាគាត់អគ្គសេនាធិការ និងអគ្គសេនាធិការរង បានន័យថា ប្រធាន អនុប្រធាន គាត់អាចទំនាក់ទំនងគ្នា។ សេចក្តីសម្រេចអ្វីៗ ហើយបញ្ហាយោធា អាហ្នឹងគឺនៅលើគាត់ហើយ គ្រាន់តែទទួលមួយជើងគោក មួយជើងទឹក មួយជើងអាកាស ប៉ុន្តែគាត់ គ្នាគាត់ក្នុងគណៈកម្មការគ្នាគាត់ គាត់ដឹងគ្នាគាត់ហើយ។ ដល់អ៊ីចឹងទៅ ខាងខ្ញុំបញ្ជូនតែទៅ ដូចថា ឥឡូវបើអ៊ំ ដូចអ៊ំមុត គាត់ទទួលខាងច្រកជួរមុខ ដូចទៅក្រចេះអ៊ីចឹង សារត្រូវបញ្ជូនឱ្យគាត់ មិនអាចបញ្ជូនទៅ ៗខាង "ម" អ៊ំប្រធានបាន

01329818



ទេ។ ដល់អ៊ីចឹងទៅ ខ្ញុំត្រូវទំនាក់ទំនងមកគាត់។ ដល់អ៊ីចឹងទៅ រឿងគាត់ គាត់ទំនាក់ទំនងគ្នាបានហើយ។ សម្ភារៈអី បើដឹក បើក៏មិនឆ្លងគាត់ទាំងអស់ ក៏ដឹកចេញមិនបាន។ ដូចគ្រាប់ ត្រូវគ្រាប់ប៉ុន្មានកប៉ាល់ ត្រូវអាវុធប៉ុន្មានពាន់ដើម។ ដល់អ៊ីចឹងត្រូវឆ្លងគាត់ ប៉ុន្តែបើអ៊ំមួយ គាត់ទទួលហើយ អ៊ំមួយអត់បានឲ្យទេ។ អាហ្នឹងជាក់ស្ដែង ខ្ញុំសូមបកស្រាយជូនលោកប៉ុណ្ណឹងចុះ។

**ស៖** ហើយចុះមេផ្ទាល់ហ្នឹង ជាអ្នកណា ជា មាស មុត ហ្នឹង មែនទេ?

[១៣:៤៨:៥១]

**ឆ៖** ទេ ដល់លោកសួរខ្ញុំថា ជាមេផ្ទាល់យ៉ាងម៉េច បើខ្ញុំនៅ១១៧ ដល់អ៊ំគាត់នៅអគ្គសេនាធិការ ដល់ថាអ៊ីចឹងទៅ ខ្ញុំលំបាកឆ្លើយដែរហ្នឹង។ ព្រោះគាត់អគ្គសេនាធិការ កន្លងទៅកម្ពុជាប្រជាធិបតេយ្យមានអ៊ំ សុន សេន អគ្គសេនាធិការ។ អ្ហ៎!មាន មាស មុត អគ្គសេនាធិការរង។ អ្ហ៎! មក ស៊ូ ម៉េត ជើងអាកាស អគ្គសេនាធិការរងទៀត។ ដល់អ៊ីចឹង ទាំងបីនេះបើតាមខ្ញុំ កងពលដែលខ្ញុំត្រូវឆ្លង ឆ្លងដូចថាខ្ញុំបញ្ជូនសារទៅខាងអ៊ំខៀវ ម៉េចគាត់មិនៗ អ៊ំសុន សេន គាត់មិនៗទទួល។ បញ្ជូនមក មាស មុត ក៏បានបញ្ជូនមក ស៊ូ ម៉េត នេះក៏បាន។ អាហ្នឹងខាងខ្ញុំបន្ទាន់ ដែលត្រូវការគ្រាប់ ឬត្រូវការដឹករបួស យន្តហោះអ៊ីចឹង ការហោះហើរ ត្រូវឆ្លងតាមអគ្គសេនាធិការហ្នឹងឯង។ ទៅ៨៧០គាត់ម៉េចដឹង។ អានេះខ្ញុំនិយាយពីបញ្ហាយោធាទេ។ ហើយបើលោកសួរខ្ញុំវិលទៅវិលមក សួរដដែលអ៊ីចឹង ខ្ញុំឆ្ងល់ដែរ។ សូមអរគុណ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយ តើលោកធ្លាប់ឃើញមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចុះទៅទស្សនកិច្ចនៅតំបន់៥០៥ដែរឬទេ?

[១៣:៥០:២១]

**ឆ៖** បាទ បញ្ហាហ្នឹងមាន។ មុនដែលយួនចូល មុនចាប់ទាំង១១នាក់នេះ អ៊ំវ៉ន វ៉េត បានទៅ មុនខែ១២ ចូលខែ១១ ដើមខែ -- ចុងខែ មុនចូលខែ១២។ គាត់ត្រឡប់មកភ្នំពេញបាន១ថ្ងៃ ឬ២ថ្ងៃ ថាចាប់គាត់ហើយ បានចាប់អ្នក១១នាក់នេះ។ ហ្នឹងកាលហ្នឹងគណៈប្រទេសដែរ អ៊ំវ៉ន វ៉េត ពីមុនគាត់ខាងក្រសួងឧស្សាហកម្មទូទាំងប្រទេសដែរ។ ក្រោយមកពេលប្រកាសដែលយួនបុកខ្លាំងនេះ ប្រកាសថាគាត់ជើងគោក គាត់ទៅត្រួតពិនិត្យនៅក្រចេះហ្នឹង ទៅ៣ថ្ងៃ។ អាហ្នឹងខ្ញុំនៅចាំបាន តែថ្ងៃហ្នឹងវាចន្លោះពីខែ១២ ខែ១១នេះ វានៅចន្លោះត្រង់ហ្នឹង។ ខ្ញុំវាមិនបានចាំថ្ងៃទេ ព្រោះខ្ញុំបានទទួលគាត់អី ហើយគាត់មកភ្នំពេញវិញ ឮដំណឹងថាចាប់គាត់ទៅ។ ហើយក្រោយមកបានប្រហែលជាប៉ុន្មានថ្ងៃទៀត ហ្នឹងថ្នាក់ដឹកនាំ។ ហើយមុនៗ ក៏មានបន្តបន្ទាប់ ដែលគ្រាន់តែខ្ញុំវាចាំមិនបានអស់ទេ តែខ្ញុំចាំចុងក្រោយហ្នឹងគឺ អ៊ំវ៉ន

វ៉េត បានទៅទស្សនកិច្ចហ្នឹងបានម្តង។ មកវិញក៏គាត់បាត់ មានគ្រោះថ្នាក់អ៊ីចឹងទៅ។ អានេះ ខ្ញុំនៅចាំបាន។ ហើយបើបញ្ហាលម្អិត ដូចបងឌល អីគាត់ដឹងច្បាស់។ ព្រោះ បងឌល គាត់គណៈតំបន់ គាត់រៀបចំកម្មវិធីទទួលអីហ្នឹង កាលនុ៎ង។ គាត់ទៅ៣ថ្ងៃ ទៅសម្រាកនុ៎ង ហើយទៅទស្សនកិច្ចនៅព្រែកទេរហ្នឹង កាលហ្នឹងយួនវាមកដល់ព្រែកទេរហើយ មកដល់ត្រើយកើតហើយ គាត់ទៅនុ៎ងនោះ។ អាហ្នឹងខ្ញុំនៅចាំបាន។ ដែលទៅថ្ងៃហ្នឹង ក៏អត់បានវ៉ៃគ្នាទៀត។ ដល់ហើយគាត់ត្រឡប់មកវិញ មកដល់ភ្នំពេញវិញហ្នឹង ក៏ឮថា ចាប់គាត់ទៅ ហើយបានបន្តបន្ទាប់នេះ តាមរយៈនុ៎ង។ អាហ្នឹងខ្ញុំនៅចាំបានប៉ុណ្ណឹង។ បាទ សូមជម្រាបប៉ុណ្ណឹងឯងសូមអរគុណ។

[១៣:៥២:២៨]

**ស៖** ចុះ នួន ជា ឬ ខៀវ សំផន អី លោកធ្លាប់ឃើញគាត់ចុះទៅតំបន់៥០៥ហ្នឹងទេ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! ឆ្លើយ!

**2-TCW-1005៖**

**ឆ៖** បាទ ជំនាន់នោះ ខ្ញុំអត់បានឃើញគាត់ទេ។ អត់ដែលគាត់បានទៅទស្សនកិច្ចដល់ហ្នឹងទេ។ អាហ្នឹងជំនាន់ដែលខ្ញុំនៅ។ តែដោយឡែកបើកាល ជួនកាលគាត់ទៅ ឬខ្ញុំមិនដឹង ឬក៏ថា បានឃើញគាត់ក៏អត់ដែរ។ ហ្នឹងខ្ញុំនិយាយជំនាន់នោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា បន្តសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះស្តាប់នូវមតិយោបល់របស់ភាគី ពាក់ព័ន្ធជាមួយនឹងសំណើសុំរបស់លោកមេធាវីការពារក្តីលោក នួន ជា ដែលគាត់បានផ្ញើមកអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែល កាលពីថ្ងៃត្រង់នេះ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ ថាឲ្យក្រុមរបស់ខ្លួនហ្នឹងអាចតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ហាង់រី ឡូកា នៅថ្ងៃចន្ទ ទី០១ ខែសីហា ឆ្នាំ២០១៦។ ហើយសូមផ្តល់វេទិកាជូនទៅសហព្រះរាជ

អាជ្ញា។ តំណាងសហព្រះរាជអាជ្ញា តើមានមតិយោបល់អ្វីដែរឬទេ សំណើនេះ?

លោកបានឃើញនេះទេ លោក ស្មីត? លោកបានឃើញអ៊ីម៉ែលរបស់ខាងក្រុមមេធាវីការពារក្ដីទេ ដែលគាត់ស្នើសុំការស្ដាប់ -- ការសួរដេញដោលរបស់គាត់ ក្រុមគាត់សួរដេញដោលសាក្សីអ្នកជំនាញ ហាង់រី ឡូកា ហ្នឹងគាត់សុំធ្វើទៅថ្ងៃ០១ សីហា ២០១៦?

[១៣:៥៥:០១]

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន។ យើងខ្ញុំបានឃើញអ៊ីម៉ែលនេះហើយ។ តាមការប៉ាន់ប្រមាណរបស់ខ្ញុំ មេធាវីការពារក្ដី នួន ជា អាចនឹងចាប់សួរនៅរសៀលថ្ងៃសុក្រ ហើយសាក្សីរូបនេះអាចបញ្ចប់នៅថ្ងៃស្អែកនៅពេលឈប់សម្រាកបាយថ្ងៃត្រង់។ <សៀវភៅនោះត្រូវបាន>អង្គជំនុំជម្រះសាលាដំបូង<ដាក់ចូលទៅក្នុងឃ្លាំងឯកសាររួមក្នុងពេលថ្មីៗនេះ។ មានការខុសប្លែកគ្នាខ្លះរវាងការបោះពុម្ព>ឆ្នាំ២០១៣ <និងឆ្នាំ២០១៦។> យើងខ្ញុំមិនជំទាស់នោះទេ <បើលោកចៅក្រមចង់ឱ្យ>មេធាវីការពារក្ដីចាប់ផ្ដើមសាកសួរនៅថ្ងៃចន្ទ។ បើសិនណាជាសាក្សីរូបនេះអាចនឹងបន្តសួរទៅដល់ថ្ងៃព្រឹកពេញស្អែក ព្រឹកស្អែកនេះទៀត <យើងខ្ញុំស្នើថា ឱ្យសហព្រះរាជអាជ្ញាចាប់ផ្ដើមសួរនៅថ្ងៃសុក្រ ជាជាងនិយាយថា នៅពេលណាមួយនៅថ្ងៃស្អែក> ដោយសារតែសៀវភៅថ្មីនេះ។ <ប៉ុន្តែយើងគោរពតាមការសម្រេចរបស់លោកចៅក្រម>។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះខាងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខាងដើមបណ្ដឹងរដ្ឋប្បវេណីក៏មិនមានអ្វីជំទាស់ទៅនឹងសំណើនេះដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន មានបញ្ហាអីដែរទេ លើសំណើរបស់មេធាវីការពារក្ដីលោក នួន ជា?

[១៣:៥៦:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគិតថា យើងអត់មានបញ្ហាអីទេ យើងគាំទ្រសំណើរបស់មេធាវី នួន ជា។ ហើយកាលពីម្សិលមិញ យើងបានស្នើសុំដែរ ថាមានឯកសារ២៥០ទំព័រជាង ដែលត្រូវបានស្នើសុំឱ្យដាក់ទៅក្នុងសំណុំរឿង ហើយខ្ញុំបានសុំឱ្យព្រះរាជអាជ្ញាហ្នឹងបញ្ជាក់ឱ្យបានច្បាស់ ថាតើគាត់ចង់ប្រើប្រាស់កន្លែងណាខ្លះនៅក្នុងឯកសារទាំង២០០ទំព័រជាងហ្នឹង ដើម្បីឱ្យយើងបានដឹងច្បាស់។ <ដូច្នេះ យ៉ាងហោចណាស់ក៏ដើម្បីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែរ ប៉ុន្តែសម្រាប់អ្នកដែលមិននិយាយភាសាបារាំង នឹងមានបញ្ហាខាងការបកប្រែ> ព្រោះថាបើតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងឯកសារ E406/1 អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងកថាខណ្ឌ១៧រួចហើយថា ភាគីត្រូវស្នើសុំឃ្លាប្រយោគពាក់ព័ន្ធនៃសៀវភៅណាមួយ ហើយត្រូវសុំឱ្យមានការបកប្រែផងដែរ។ អ៊ីចឹងនៅចន្លោះថ្ងៃនេះដល់ថ្ងៃស្អែកហ្នឹង ខ្ញុំគិតថាមានបញ្ហាពាក់ព័ន្ធនឹងការបកប្រែហើយ។ ព្រោះបកប្រែមិនទាន់ទេ ឯកសារហ្នឹងវាមានច្រើន ហើយបើយើងចង់<យក>សៀវភៅហ្នឹងមកសួរនាំអ្នកជំនាញនោះ យើងត្រូវតែមានឯកសារហ្នឹងមួយច្បាប់ដែរ សម្រាប់អ្នកបកប្រែ ដើម្បីឱ្យពួកគាត់អាចមើលបាន ពីព្រោះថាមិនទាន់មានការបកប្រែពេញលេញនៅឡើយទេ។ អ៊ីចឹងការលើកទៅសួរនៅថ្ងៃចន្ទ ខ្ញុំគិតថាមិនជាបញ្ហាអ្វីទេ វាគឺជារឿងមួយដ៏គួរឱ្យគាំទ្រ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោក វីល្លៀម ស្មីត តើលោកអាចបញ្ជាក់បានទេ លើសំណើសុំរបស់ក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដែលគាត់បានស្នើសុំរួចហើយ ហើយបញ្ជាក់អម្បាញ់មិញទៀត អំពីបញ្ហាទំព័រដែលមានជាង២៥០ទំព័រនោះ? ហើយចំណុចណាខ្លះដែលមានបំណងក្នុងការដកស្រង់យកមកសួរដេញដោលនោះ តើអាចបញ្ជាក់បានដែរឬទេ? តាមពិត គាត់សួរតាំងពីម្សិលមិញ។

[១៣:៥៨:២៧]

**លោក វីល្លៀម ស្មីត៖**

សារដែលត្រូវយកមកប្រើប្រាស់កំពុងតែពិនិត្យនៅឡើយទេ ហើយបើអាចធ្វើឱ្យរួសរាន់ទៅបាន យើងខ្ញុំអាចបញ្ជូនសារទៅឱ្យមេធាវីការពារក្តី។ យើងខ្ញុំយល់ឃើញថា ខាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីមានជំហរដូចគ្នាទេ ពាក់ព័ន្ធទៅនឹងសៀវភៅថ្មីៗនេះ ជាពិសេសពាក់ព័ន្ធទៅនឹងសៀវ-ភៅដែលត្រូវបានធ្វើការកែប្រែ។ ខ្ញុំយល់ឃើញថា នេះអាស្រ័យទៅលើក្រុមមេធាវីការពារក្តីទេ។ <ពិតប្រាកដណាស់ វានឹងចំណាយពេលវេលាបន្តិច។ ដូច្នេះវា>កំពុងតែ<នៅក្នុងដំណាក់កាល>ពិនិត្យមើល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅលើការកែប្រែទៅលើសៀវភៅនេះនៅឡើយ ហើយខ្ញុំ<>អាចធ្វើបច្ចុប្បន្នភាពជូនមេធាវីការពារក្ដី <និងអង្គជំនុំជម្រះ>បាន <>នៅពេលឈប់សម្រាករសៀលនេះ សឹមខ្ញុំផ្ដល់ព័ត៌មានបច្ចុប្បន្នភាពជូនទៅគាត់បាន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបផងដែរ។ យើងខ្ញុំមិនមានជំហរដូចគ្នានោះទេ ដោយសារខាងសហព្រះរាជអាជ្ញាហ្នឹង គឺថាស្នើសុំឲ្យទទួលយកសៀវភៅដែលមានចំនួន២៥០ទំព័រនេះ <ប្រហែលជាក្រោយពេលបានពិនិត្យមើល>ទៅលើខ្លឹមសាររបស់វា ហើយបន្ថែមទាំង<១១៧>ទំព័រទៀត<នៅក្នុងសៀវភៅនោះ>។ <បញ្ហាតែមួយគត់ ដែល>ឥឡូវនេះ យើងកំពុងតែប្រឈមមុខ <គឺ>សៀវភៅមួយដែល<>សរសេរដោយអ្នកជំនាញចំនួន៣៦៧ទំព័រ <មានតែ>ជាភាសាបារាំង<តែប៉ុណ្ណោះ។ ទោះបីជាយើងមានទីប្រឹក្សាផ្នែកភាសាបារាំងនៅក្នុងក្រុមយើង ហើយខ្ញុំអាចអានភាសាបារាំងបានខ្លះៗក៏ដោយ ក៏បុគ្គលិកផ្នែកជាតិរបស់ខ្ញុំមិនចេះទេ>។ ដូច្នេះ យើងខ្ញុំមិនមានជំហរដូចដែលការលើកឡើងនេះទេ។ អ៊ីចឹងអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងថា ស្ថិតនៅក្នុងជំហរដូចគ្នាមិនត្រឹមត្រូវគ្នាទេ មិនត្រឹមត្រូវទេ។ <បន្ថែមពីលើនោះទៀត> យើងខ្ញុំ<កត់សម្គាល់>ថា យើងខ្ញុំប្រហែលជាអាចបញ្ចប់ការសាកសួរជាមួយសាក្សីរូបនេះនៅថ្ងៃនេះតែម្ដង។ យើងខ្ញុំយល់ឃើញថា យើងខ្ញុំនឹងមិនបន្តសួររហូតទៅដល់ពេលបាយថ្ងៃត្រង់ស្អែកនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើ<ជាការសង្កេត ឬក៏>លោកជំទាស់ទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែល<ចាប់ផ្ដើម>សួរ<នៅព្រឹក>ថ្ងៃសុក្រ<>?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនបញ្ហាទេ យើងខ្ញុំមិនជំទាស់ទេ។ <យើងអាចចាប់ផ្ដើមនៅថ្ងៃសុក្រ។>

[១៤:០១:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៤:១៨]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន យើងខ្ញុំទើបតែទទួលព័ត៌មានថ្មីពាក់ព័ន្ធទៅនឹងការពិនិត្យមើលទៅលើសៀវភៅនេះ

ដោយសារតែវាមានផ្នែកច្រើនណាស់នៅក្នុងសៀវភៅនេះ ដែលពាក់ព័ន្ធទៅនឹងសំណុំរឿងយើងនេះ។ ប្រហែលជាយើងខ្ញុំមិនអាចលើកឡើងអំពីផ្នែកណាមួយដែលវាមិនសំខាន់ យកមកជម្រាបជូនទាំងអស់នោះទេ។ ផ្នែកជាច្រើននៃសៀវភៅស្ទើរតែទាំងអស់នេះ ត្រូវបានយកមកប្រើប្រាស់ហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើអាចប៉ាន់ប្រមាណពេលវេលាថា នឹងត្រូវសួរតែមួយថ្ងៃទេសម្រាប់សហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញា?

**លោក វីល្លៀម ស្មីត៖**

វាអាស្រ័យទៅលើអ្នកជំនាញទេ ផ្នែកខ្លះនឹងត្រូវលើកមកសួរ ព័ត៌មានខ្លះនឹង<មិន>សួរ<ទេ>។ អ៊ីចឹងដូចខ្ញុំជម្រាបហើយ គឺថាមានផ្នែកច្រើនណាស់នៅក្នុងសៀវភៅនេះ ដែលយើងត្រូវយកមកប្រើប្រាស់ដើម្បីសួរទៅកាន់គាត់។

[១៤:០៥:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី អង់តា ហ្គិសសេ!

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអភ័យទោសលោកប្រធាន ដែលខ្ញុំត្រូវឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា។ គាត់ពន្យល់ថា សៀវភៅទាំង២៥០ទំព័រនុ៎ង នឹងត្រូវប្រើប្រាស់ទាំងស្រុងក្នុងពេលសួរអ្នកជំនាញសម្រាប់រយៈពេលមួយថ្ងៃ <ឬក៏តិចជាងនេះបន្តិច បើសិនជាគេនឹងបែងចែកពេលវេលា>ជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ ទោះបីជាសៀវភៅហ្នឹងមានកែប្រែនៅឆ្នាំ២០១៦ ក៏ដោយ ក៏ប៉ុន្តែសៀវភៅហ្នឹងមានសំណៅមួយទៀត នៅឆ្នាំ២០១៣ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាទើបតែសុំប៉ុន្មានថ្ងៃហ្នឹងមុនទេ ហើយមេធាវីការពារក្ដីធ្វើសំណើដែរ។ អ៊ីចឹងត្រូវតែមានការប្រព្រឹត្តឱ្យបានត្រឹមត្រូវចំពោះសហព្រះរាជអាជ្ញា ដែលមិនគោរពទៅតាមការបង្គាប់របស់អង្គជំនុំជម្រះក្នុងការសុំឱ្យផ្ដល់ ERN ឱ្យបានច្បាស់លាស់នូវអ្វីដែលខ្លួនចង់យកមកសួរនោះ។ គាត់មិនអាចមកឆ្លើយថា សួរស្ទើរតែទាំងអស់អ៊ីចឹងទេ គាត់ត្រូវតែផ្ដល់នូវកន្លែងណា ប្រយោគណា ផ្នែកណា មិនអាចយកមកថា២៥០ទំព័រទាំងអស់មកនិយាយអ៊ីចឹងទេ។ ភាគី

ទាំងអស់ត្រូវតែគោរពទៅតាមការបង្គាប់របស់អង្គជំនុំជម្រះ នៅក្នុងការផ្តល់នូវERN ជាក់លាក់នូវចំណុច ឬក៏ផ្នែកណាជាក់លាក់ ដែលខ្លួនចង់ប្រើប្រាស់ដើម្បីសួរអ្នកជំនាញនោះ មិនអាចមកនិយាយច្បោលៗ សរុបទាំងអស់អ៊ីចឹងទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរទៅសហព្រះរាជអាជ្ញា។ ឧបមាថា អង្គជំនុំជម្រះសម្រេច<>ថា <អត់ធ្វើសវនាការសឹងតែពេញមួយថ្ងៃ មិនមែនពេញមួយថ្ងៃទេ គឺសឹងតែពេញមួយថ្ងៃ> តើសហព្រះរាជអាជ្ញាអាចព្យាយាមបញ្ជាក់ផ្នែកណាពាក់ព័ន្ធ ឬក៏សរសេរបញ្ជាក់ជូននូវផ្នែកណាដែលពាក់ព័ន្ធបានទេ?

[១៤:០៧:៣៦]

**លោក វីល្លៀម ស្មីត៖**

លោកស្រីចៅក្រម តាមដែលព័ត៌មានដែលខ្ញុំបានទទួលមកថា សហព្រះរាជអាជ្ញា ដែលត្រូវសួរទៅអ្នកជំនាញនេះគឺថា <វា>មិនសំដៅទៅលើតែផ្នែកជាក់លាក់ទេ គឺពាក់ព័ន្ធទៅនឹងជំពូក ឬក៏សារកន្លែងណាមួយដែលវាសំខាន់ៗនោះ។ <នេះជាព័ត៌មានដែលខ្ញុំទទួលបានពី>សហព្រះរាជអាជ្ញាដែលត្រូវសាកសួរនេះ។ <អ្វីដែលខ្ញុំនិយាយនេះ>គឺថា <>ប្រហែលជាយើងមិនលើកយកកថាខណ្ឌជាក់លាក់ណាមួយ ឬក៏គំនិតយោបល់ណាមួយដែលលើកមកសរសេរនៅក្នុងជំពូកណាមួយ មកសាកសួរនោះទេ។ ប៉ុន្តែ<>ប្រហែលជា<គំនិតដែលបានលើកឡើងនៅក្នុងជំពូកមួយ។ ដូច្នេះ ក្នុងន័យនេះ សម្រង់ជាក់លាក់ ប្រហែលជា>មិនយកមកសាកសួរដូចធម្មតានោះដែរ។ ប៉ុន្តែអ្វីដែលខ្ញុំអាចជម្រាបជូនបាននាពេលនេះ គឺថាខ្ញុំនឹងសាកសួរទៅម្តងទៀត ថាតើមានផ្នែកជាក់លាក់ណាមួយ នឹងត្រូវយកមកប្រើប្រាស់នោះឬទេ? ហើយនៅពេលដែលខ្ញុំទទួលបានព័ត៌មាននេះ គឺថាខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះវិញ។ ប៉ុន្តែដូចនៅពេលនេះ គឺថាខ្ញុំចង់ជម្រាបថាសៀវភៅទាំងមូលនេះ គឺថានឹងត្រូវយកមកប្រើប្រាស់ហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកអាចលើកយកទស្សនៈទាំងអស់ដែលមាននៅក្នុងសៀវភៅយកមកសួរ ប៉ុន្តែខ្ញុំចង់សួរ <តើផ្នែកណានៃសៀវភៅ>ដែលត្រូវសាកសួរនេះ លោកបានគិតទេ?

[១៤:០៩:០៦]

**លោក វីល្លៀម ស្មីត៖**

<គេប្រាប់>ខ្ញុំ<ថា យើង>មានផែនការថា នឹងប្រើប្រាស់គ្រប់ផ្នែកទាំងអស់នៃសៀវភៅនេះ។

01329825



ឥឡូវនេះខ្ញុំនឹងសាកសួរទៅសហព្រះរាជអាជ្ញាដែល<ត្រូវ>សួរទៅកាន់អ្នកជំនាញ ថាតើគាត់នឹងអាចកាត់បន្ថយផ្នែកណាបានដែរឬទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

តើលោកកំពុងតែនិយាយសំដៅទៅលើឯកសារសៀវភៅនេះ ទាំង៣៦៧ទំព័រនេះ ឬមួយក៏<តែ២៥០ទំព័រទេ>?

**លោក វីល្លៀម ស្មីត៖**

យើងនិយាយអំពីសៀវភៅថ្មីនេះតែម្តង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺផ្នែកដែលបានទទួលយក សម្រេចទទួលមកហើយមែនទេ?

**លោក វីល្លៀម ស្មីត៖**

បាទ ត្រឹមត្រូវហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

តាមដែលខ្ញុំដឹងគឺថា២៥០ទំព័រ ប្រាំ<បួន>ជំពូក គឺត្រូវទទួលយកមកហើយ <ប៉ុន្តែផ្នែកដែលនៅសល់ផ្សេងទៀត មិនទាន់ទទួលយកទេ។> ប៉ុន្តែឥឡូវនេះ លោកសហព្រះរាជអាជ្ញារងឆ្លើយថា គឺសៀវភៅទាំងមូលតែម្តង។

**លោក វីល្លៀម ស្មីត៖**

គឺខ្ញុំសំដៅទៅលើផ្នែកដែលអង្គជំនុំជម្រះបានសម្រេចទទួលយករួចមកហើយ។ សូមអរគុណ។

[១៤:១០:០២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១០:២២]

**លោក វីល្លៀម ស្មីត៖**

ផ្នែកដែលត្រូវសួរនេះ គឺថាអាចនឹងយកមកជម្រាបជូនបាន តែទោះជាយ៉ាងណាក៏ដោយ គឺថាសហព្រះរាជអាជ្ញាដែលគាត់ត្រូវតាំងសំណួរ គាត់ថា គាត់ចង់សួរសៀវភៅទាំងមូលនេះតែម្តង។ ប្រហែលជានៅជិតចុងបញ្ចប់នៃថ្ងៃនេះ យើងខ្ញុំនឹងអញ្ជើញសហព្រះរាជអាជ្ញា--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<នៅចុងម៉ោងថ្ងៃនេះឬ?>

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំនឹងទំនាក់ទំនងរបស់គាត់ ហើយឱ្យគាត់ជម្រាបជូនមកអង្គជំនុំជម្រះ។

[១៤:១០:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១១:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីបញ្ជាក់បញ្ហានេះឱ្យច្បាស់លាស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ទី១ អង្គជំនុំជម្រះ គឺថាសម្រេចទទួលយកសំណើសុំទាំងពីររបស់សហ<ព្រះរាជអាជ្ញា> ក៏ដូចជាសហមេធាវីការពារក្តី ខៀវ សំផន ដែរ។ ស្អែកនេះ គឺថានឹងមានការតាំងសំណួរពីសំណាក់អង្គជំនុំជម្រះ។ យើងសង្ឃឹមថា សហព្រះរាជអាជ្ញាក៏ដូចជា សហមេធាវីនាំមុខចាប់ផ្តើមសួរនៅថ្ងៃសុក្រ ហើយក្រោយពេលបញ្ចប់រួចហើយ គឺថាយើងនឹងផ្តល់ទៅតាមសំណើសុំរបស់មេធាវីការពារក្តី នួន ជា។ អង្គជំនុំជម្រះក៏បានទទួលយកចំពោះអ្វីដែលលើកឡើងថា នឹងព្យាយាមកាត់បន្ថយ ហើយនិងព្យាយាមប្រើប្រាស់តែផ្នែកណាដែលបានសម្រេចទទួលយកមកហើយ គឺផ្នែកនៅពាក់ព័ន្ធនៅក្នុងសៀវភៅនោះ រហូតដល់ចុងបញ្ចប់ គឺរហូតនៅចុងបញ្ចប់នៅថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយដោះស្រាយបានហើយ។ ឥឡូវនេះ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា លោកមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៤:១៣:០៨]

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរជាថ្មីលោកសាក្សី។ មុនពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់ យើងបានពិភាក្សាគ្នាអំពីការវាយលុករបស់ទាហានវៀតណាម នៅខែមីនា<-មេសា> ឆ្នាំ៧៧។ ខ្ញុំចាំថា លោកនិយាយនៅមុនពេលឈប់សម្រាកថា កងទ័ពវៀតណាមបានវាយបុកពីខាងក្រោយ ហើយបានវាយប្រហារនៅតាមកន្លែងផ្សេងៗគ្នាជាច្រើន <ខណៈដែលសមាជិកនៃកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"ចូលដៃ" ជាមួយកងកម្លាំងវៀតណាម>។ តើលោកមានន័យយ៉ាងម៉េចនៅពេលដែលលោកនិយាយថា <"ចូលដៃ">ហ្នឹង? តើ<>កងទ័ពកម្ពុជាប្រជាធិបតេយ្យ <ឬសមាជិកកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានធ្វើអ្វីខ្លះ ដែលនាំឱ្យលោកនិយាយថា ពួកគេ>ហ្នឹងចូលដៃជាមួយវៀតណាម<>?

**2-TCW-1005៖**

**ឆ៖** បាទ សំណួរដែលលោកសួរខ្ញុំ ខ្ញុំឆ្លើយដោយតាមត្រង់ទៅ ចង់ថា ឧទាហរណ៍ថា ឥឡូវកងទ័ពខ្ញុំមានចំនួនទ័ពតិចជាងកងទ័ពយួន តិចជាទ័ពវៀតណាម។ ដល់អ៊ីចឹង ការខ្សែត្រៀមវាយពីព្រំប្រទល់មណ្ឌលគិរីមកទល់នឹងស្រុកៗចន្ទ្រា ម្តុំខាងកំពង់ចាមនេះ វាដីធំណាស់លាតសន្ធឹង។ ដល់អ៊ីចឹងទៅពឹងតាមទ័ពតំបន់ ទ័ពអីមួយចំនួន ដល់បុកព្រឹបមក គេចូលអាប្រលោះហ្នឹង ប្រលោះតំបន់ហ្នឹង។ ដល់អ៊ីចឹងប្រាវមកមិនបាក់ បាក់មក មិនរត់បណ្តោយខ្សែត្រៀម មិនពួកខ្ញុំ មិនជាប់បាត់ហើយ។ អាហ្នឹងខ្ញុំចង់និយាយអ៊ីចឹង ថាសំដៅហ្នឹង ថាមិនមែនមិនទុកចិត្តគ្នាទេ តែដល់វាបុកធំមក បាក់ទៅ ប៉ះគ្រោះថ្នាក់តែគ្នាឯង។ អាហ្នឹងចង់ អាហ្នឹងខ្ញុំសំដៅអ៊ីចឹង។ ហើយកម្លាំងគេ ក៏វាធំ។ មិនមែនមិនទុកចិត្តគ្នាឯង ប៉ុន្តែយូរទៅ អត់ទុកចិត្តមែន ដល់៧៨ ឃើញទេ! មានទុកចិត្តគ្នាឯណា។ ៧៨ចាប់ផ្តើមរករឿងគ្នា ដោយសារអី? ដោយសារមិនទុកចិត្តគ្នា វៃខាងមួយឈ្នះទៅអរទៅ ខាងមួយចាញ់ទៀត ចោទគ្នាទៅ។ អាហ្នឹងខ្ញុំចង់និយាយអ៊ីចឹង។ ដល់យូរៗ គ្រោះថ្នាក់ទ័ព មានគ្រោះថ្នាក់អ្នកណា។ អស់មេហើយ អស់ទាំងកូនទៀត។ អាហ្នឹងខ្ញុំចង់បញ្ជាក់ឱ្យលោកបានយល់ថាត្រង់នុ៎ង ព្រោះសង្គ្រាមអាបែកការណ៍នេះក៏គ្រោះថ្នាក់ អាបាក់ទ័ពនេះក៏គ្រោះថ្នាក់។ បើសិនណាជាអត់បាក់ទេ នៅអត់រត់ចោលត្រង់សេ រស់។ លោតែបាក់តែបីបួនត្រង់សេ រត់ចោលត្រង់សេហ្នឹង រថក្រោះដេញជាន់ គ្រោះថ្នាក់ទាំងអស់ហ្នឹង អត់មានរត់រួចទេ។ កុំថា៥០០ម៉ែត្រ ក៏នៅតែបាញ់ចំដែរ អាហ្នឹងខ្ញុំចង់និយាយអ៊ីចឹង។ ហើយក៏មិនដឹងទុកចិត្តខាងណាបើខាង ពឹងខាងនេះបាក់ ខាងនេះបាក់ ហើយយកទៅជួយម៉េចជាប់ ដីវាប់រយ ជិតប្រហែលហាហុកសិបគីឡូ។ អានេះខ្ញុំជម្រាបត្រង់ចុះ អាហ្នឹងដីដែលខ្ញុំធ្លាប់ដែលដឹង ច្រកខ្ញុំ។ បាទ សូមអរគុណ។

[១៤:១៦:៤០]

**ស៖** ខ្ញុំសង្ខេបអ្វីដែលលោកនិយាយអ៊ីចេះទៅចុះថា គឺថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យគឺថាលួចលាក់ ឬក៏ចែកព័ត៌មានសម្ងាត់ទៅឱ្យកងទ័ពវៀតណាមនៅតាមកន្លែងមួយចំនួន។ អ៊ីចឹងមែនទេ?

**ឆ៖** លោកសួរនេះ ចង់និយាយថា មិនមែនខ្ញុំថាទេ អានេះគឺលោកចង់សួរខ្ញុំថា អាចដឹងខ្លះអត់អ៊ីចឹងអ្ហ៊ុ? បើអ៊ីចឹង អាហ្នឹងខ្ញុំអាចឆ្លើយបានបាទ។ លោកសួរម្តងទៀត។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01329828



**ស៖** ការពិតទៅ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់ ថាតើខ្ញុំយល់អ្វីដែលលោកនិយាយ គឺថាខ្ញុំសន្និដ្ឋានត្រឹមត្រូវទេដែលថា លោកនិយាយថា មានភស្តុតាង ឬក៏ថាមានការបង្ហាញថា កងទ័ពកម្ពុជាប្រជាធិបតេយ្យលួចលាក់ផ្ដល់ព័ត៌មាន ឬក៏ផ្ដល់ព័ត៌មានសម្ងាត់ទៅឲ្យកងទ័ពវៀតណាម?

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមជំទាស់។ នេះមិនមែនជាអ្វីដែលសាក្សីនិយាយនោះទេ។ ហើយខ្ញុំក៏សុំ<សួរ>មេធាវីការពារក្ដី<ផងដែរ> ខ្ញុំមិន<>មានបញ្ហានៅក្នុងខ្លឹមសារនៃការសួរ<>នោះទេ <ហើយបើសិនជាគាត់បានទទួលព័ត៌មានខ្លះ ឬក៏ឯកសារមួយដែលគាំទ្រដល់សំណើនោះ សូមឲ្យគាត់ផ្ដល់ព័ត៌មាននោះមកហើយសួរទៅសាក្សីចុះ ព្រោះអ្វីដែលគាត់សួរនោះ មិនមែនជាអ្វី> ដែល<>សាក្សី<បាន>និយាយ<នោះទេ>។

[១៤:១៨:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំឮសាក្សីនិយាយថា កងទ័ពកម្ពុជាប្រជាធិបតេយ្យចូលដៃជាមួយកងទ័ពវៀតណាម <ហើយពួកគេបាន>ចូលមកដល់ក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ<នៅកន្លែងដែលអត់មានកងទ័ព។ ដូច្នេះ ផ្នែកទាំងពីរនេះហើយ ដែលបញ្ចូលគ្នាបង្កើតបានជាសំណួរនោះ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំសួរចំណុចអ៊ីចេះវិញ លោកប្រធាន។ ខ្ញុំចង់សួរថា តើកងទ័ពកម្ពុជាប្រជាធិប-តេយ្យទម្លាយព័ត៌មានសម្ងាត់ទៅឲ្យកងទ័ពវៀតណាមដែរឬទេ?

**2-TCW-1005៖**

**ឆ៖** បាទ បញ្ហានេះដែលខ្ញុំក្ដាប់មិនជុំទូទាំងប្រទេសទេ ក៏ប៉ុន្តែគ្រាន់ច្រកខ្ញុំមួយចុះ អានេះខ្ញុំនិយាយច្រកខ្ញុំមួយទេ។ នៅថ្ងៃទីប៉ុន្មានទេ តែក្នុងខែ១១ មិនដល់ខែ១២ទេ អាហ្នឹងនៅច្រកខ្ញុំមួយប្រហែលជាពីរបីរយនាក់ស្លាប់នៅនឹងព្រែកទេរហ្នឹងតែម្ដង កងទ័ពកំពុងតែជប់លៀងរៀបទៅវ៉ៃនេះ។ អាហ្នឹងខ្ញុំនិយាយច្រកខ្ញុំមួយចុះ។ តេអ្វូនិយាយកោក១អ៊ីចឹង។ គ្រាន់តែអ្នកមករត់មកប្រាប់ថា តេអ្វូគេហៅគ្រាប់ផ្ដោងហើយ យួនវានៅមុខហ្នឹង។ ហើយដល់អ៊ីចឹងមក មកជាន់អាចង្ក្រានបាយហ្នឹង កំពុងតែហូបបាយ ហើយជ្រក់ស្ពៃអី ឆាសាច់គោអីអ៊ីចឹង។ អាហ្នឹងខ្ញុំចង់និយាយ មិនមែនដល់រួមទេ ខ្ញុំនិយាយមួយច្រកខ្ញុំចុះ។ អស់មួយវរសេនាធំហ្នឹងប្រហែលជា២០០នាក់ គ្រាន់តែមួយប្រឹះ។ អានេះ មិនមែនខ្ញុំ

និយាយឆ្លងដល់មួយប្រទេសទេ អាហ្នឹងខ្ញុំដឹងគ្រាន់តែមួយក្រវិចខ្ញុំតូចប៉ុណ្ណឹង គឺមានការសង្ស័យគ្នា ប៉ុណ្ណឹង។ អាហ្នឹងខ្ញុំចង់ជម្រាបលោកដោយត្រង់ ព្រោះកាលពីបកស្រាយ ខ្ញុំមិនបានបកស្រាយចំដល់ ម្ល៉ឹងទេ ថាអាហ្នឹង ក្នុងនុំងវាមាន១បញ្ហានុំងហើយ។ ដល់អីចឹងងាប់អ្នកណា ស្លាប់ទ័ពមេក្បត់ ប៉ុន្តែដល់ ស្លាប់ ស្លាប់ទ័ព ស្លាប់គ្រោះថ្នាក់យុទ្ធជន។ នេះខ្ញុំ១ចង់និយាយប្រៀបធៀប។ ហើយជំនាន់នោះ តែអូ មានឯណា មានតែវរសេនាធំ មានវរសេនាតូច កងពលទេ គឺអីចឹង។ ដល់ហើយ គេរត់ចូលយួនបាត់ទៅ នៅអាទ័ពនេះស្លាប់បាត់។ អាហ្នឹងខ្ញុំសូមជម្រាបបានប៉ុណ្ណឹងសិនចុះ បើលោកចង់ឆ្ងល់អីទៀត ខ្ញុំសួរបាន -- ឆ្លើយបាន បញ្ហានុំង។ បាទ សូមអរគុណ។

**ស៖** តើកងទ័ពមួយណាដែលក្បត់ ហើយរត់ចូលទៅវៀតណាម តើលោកអាចប្រាប់បានទេ?

[១៤:២០:៥០]

**ឆ៖** ខ្ញុំចង់និយាយថា ឥឡូវខ្ញុំអាចជម្រាបបានយ៉ាងណា ព្រោះថាកាលពីជំនាន់ខ្ញុំទៅ ពីលង្វែក ទៅ គឺសុទ្ធតែអ្នកបង១ គាត់នៅនឹងកំពង់ឆ្នាំង។ ខ្ញុំមិនអាចស្គាល់គាត់បានទាំងស្រុងទេ តែដោយឡែក ចង់និយាយថា ដល់តែកងខ្ញុំទៅនៅនុំង ក៏អ្នកកំពង់ឆ្នាំងដែរ តែមិនដឹងជារត់បានចូលយួនរហូតដល់ឥឡូវ បើអត់បានឃើញគាត់ទៀត។ អាចគាត់រត់ទៅស្លាប់តាមផ្លូវ ឬក៏យ៉ាងណា។ អ៊ូដូច បងអឿង ហ្នឹង វរសេនាធំនៅខាងទៅពីខ្ញុំទៅ។ បងអឿង ហ្នឹងពេលហៅគ្រាប់ផ្លោងហើយហ្នឹង ក៏គាត់បាត់ខ្លួនទៅ។ ពេលរត់មក ក៏មិនឃើញគាត់ កងទ័ពហ្នឹងក៏អត់ឃើញ។ បងអឿង ហ្នឹងគឺគាត់ចង់និយាយពីដើមគាត់ នៅខាងស្រុកខ្ញុំ ខាងស្រែរនោង។ អាហ្នឹងខ្ញុំនិយាយពិសោធន៍ អាហ្នឹងដឹងស្គាល់មុខមួយ ដល់ បងអឿង ហ្នឹង។ ពេលដែលខ្ញុំរត់ធ្លាក់ទឹកទន្លេហើយនេះ មកដល់ត្រើយលិច អត់ឃើញគាត់ នីរសារគាត់ទាំងអស់ ក៏អត់ឃើញ មិនដឹងជាយួនបាញ់ស្លាប់ ឬក៏យ៉ាងណា។ ហ្នឹងខ្ញុំនិយាយ ចង់និយាយថាហ្នឹងដែលខ្ញុំដឹងខាង ច្រកខ្ញុំមួយទេ ខ្ញុំអត់និយាយខាងកងគេផ្សេង ព្រោះខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែកងមួយចំពោះមួយក្រវិចដីខ្ញុំ ប៉ុន្មានម្ភៃសាមសិបគីឡូហ្នឹងទេ ខ្ញុំចង់ជម្រាបលោកដោយ១ត្រង់ចុះ។ តែបើវាបាត់ខ្លួនទាំងអស់រហូតដល់ ពេលមកដល់ព្រំដែន ក៏អត់ឃើញ អ៊ូ!សន្តិភាពហើយហ្នឹងក៏មិនឃើញ អីចឹងបានន័យថា បាត់ខ្លួនជំនាន់ នុំង អត់ដឹងមុខទេ។ វរសេនាធំបាត់ខ្លួនពីរ អនុសេនាតូចប៉ុន្មានទៀត ហ្នឹងគ្រាប់ផ្លោងដែលស្លាប់ថ្ងៃ២០០ នាក់ជាងហ្នឹងអាហ្នឹង អាហ្នឹងផ្លោងចំហ្នង នៅជាប់នឹងព្រែកស្ពាន ព្រែកទេរ នៅខាងជើងស្ពានព្រែកទេរ ប្រហែលជាដី១០០ម៉ែត្រទេ ប៉ុន្តែថ្ងៃទី ខ្ញុំមិនបានចាំទេ កាលជំនាន់នុំង វាប្រចំរឿងទ័ពស្លាប់ ដឹករបួស ដឹកអីមក១មន្ទីរពេទ្យ។ ហ្នឹងខ្ញុំសូមសង្ខេបជូនលោកប៉ុណ្ណឹងចុះ។

[១៤:២២:៤២]

**ស៖** តើលោកមានស្គាល់សមាជិកកងពល១១៧ណា ដែលរត់ចូលទៅវៀតណាមក្នុងខែឧសភា <> ឬក៏មិថុនា ឬក៏ខែមេសា ឆ្នាំ៧៧ទេ? លោកអាចចាំឈ្មោះ ឬក៏ស្គាល់ឈ្មោះមេបញ្ជាការ ឬក៏ទាហានណាម្នាក់ដែលរត់ទៅវៀតណាមទេ?

**ឆ៖** លោកសួរខ្ញុំ ដល់សួរខ្ញុំអ៊ីចឹង ខ្ញុំអត់ដឹង ព្រោះជំនាន់នោះ ពេលយួនបុកខ្លាំង៧៧ហ្នឹង អត់មានចាប់អារម្មណ៍បញ្ហាអ្នកណារត់ចូលអ្នកណា ព្រោះស្លាប់ៗច្រើន។ ទៅដល់ថ្នាក់មួយប្រាវ ប្រហែលជាមិនទាន់៣ខែ អស់៧០០។ ហើយដល់លោកឯងសួរខ្ញុំថា រត់ចូលយួន មិនរត់ ខ្ញុំអត់ៗ អាបញ្ហាហ្នឹង ខ្ញុំក្តាប់អត់បាន។ ទី១ ព្រោះថាឥឡូវនៅគល់កៅស៊ូ យួនវាដាក់មីនគល់កៅស៊ូខាងលិច យើងទៅលុតជង្គង់នៅគល់ខាងលិច ៣ថ្ងៃបាន ៣ថ្ងៃទៅ៤ថ្ងៃ បានយកសពបាន។ ដូច្នេះដល់អ៊ីចឹងទៅ គិតអុកឡុករឿងទ័ពអត់ស្បៀង រឿងយកសពចេញអីអ៊ីចឹង។ ដល់រឿងរត់ចូល ខ្ញុំអត់បានដឹង ព្រោះក្នុងកងពលដែលខ្ញុំស្គាល់ទៅពីលង្វែកទៅ គឺដូច ពូនីម អីក៏នៅ ដូច រុំ អីក៏នៅអ៊ីចឹង ហ្នឹងខ្ញុំដូច បងលាង អីក៏នៅអ៊ីចឹង ហ្នឹងខ្ញុំដឹងហើយវរសេនាធំអី ក៏មានស្លាប់។ ហ្នឹងឃើញជាក់ស្តែង តែដោយឡែក អារឿងថារត់ចូលវៀតណាមហ្នឹងខ្ញុំៗអត់ៗក្តាប់បានទេ ព្រោះខ្ញុំនៅខាងក្រោយនេះ ខ្ញុំនៅខាងទូរលេខ នៅខាងដឹកស្បៀង ដឹកអីនេះ។ ហ្នឹងជម្រាបជូនលោកដោយសង្ខេបប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ឮគេនិយាយក្រោយខែមករា ៧៩នេះទេ ថាមានទ័ពមកពីកងពល៣១០ ឬក៏កងទ័ពមកពីខាងបូព៌ារត់ចូលទៅវៀតណាមនៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ទេ?

[១៤:២៤:៥០]

**ឆ៖** លោកសួរចម្លើយនេះ ដល់អ៊ីចឹងឲ្យខ្ញុំបកស្រាយ កាន់តែៗធ្ងន់ដល់ខ្ញុំទៀត អាហ្នឹងខ្ញុំក៏ដឹងៗ។ បើលោកសួរបញ្ហាហ្នឹងលម្អិតទៅ វាទៅទាំងស្រុងទៅហើយ ឲ្យខ្ញុំធ្វើម៉េចទប់ជាប់។ អ៊ីចឹងបានរឿងហ្នឹង លោកសួរហ្នឹង សួរចេះតែវែងទៅៗ ខ្ញុំចេះឆ្លើយ ចេះតែវែងទៅទៀតហើយ ព្រោះដឹងថាបញ្ហានុ៎ងហើយនេះ បានរឿងដែលមិនទុកចិត្តគ្នា។ អាហ្នឹងខ្ញុំចង់និយាយឲ្យចំទៀតចុះ។ រត់ទៅមិនមែនមួយកងពលទេ រត់ទៅពាក់កណ្តាលៗលើសទៅទៀត។ អានេះ ខ្ញុំៗនិយាយត្រង់ជំនាន់នោះ។ ការពិតយួនចូលក្រចេះមុនគេហ្នឹង ភ្នំប្រាំពាន់នេះ នៅស្វាយជ្រះនេះ អាហ្នឹងវាៗ អាហ្នឹងនៅកន្លែងទីតាំងកងពលនៅមួយហ្នឹង នាំបណ្តោះមករបួសហើយ ដែលខ្ញុំ អាហ្នឹងខ្ញុំនិយាយដែលចូលក្រចេះមុនគេលឿនជាងគេនេះ។ អ៊ើពីម៉ោងប្រាំមួយព្រឹក ទល់គ្នាម៉ោងប្រាំបីយប់យកបានស្នួលហ្នឹងមួយ មកពីកាត់ផ្លូវយន្ត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហោះប្អូនគ្រឿងទម្លាក់វាយផ្លូវ តាំងពីព្រែកឆ្លង ឃ្លាំងគ្រាប់ខ្ញុំ ព្រែកឆ្លងទល់មកដល់ស្រែរនាម ប្អូនគ្រឿងស្មើហ្នឹងប្រាំបីគ្រាប់ ត្រូវសាលាស្រុកស្នួល មកត្រូវឃ្លាំងគ្រាប់ មកត្រូវប្រជាជនប៉ុន្មានឃុំខាងកើតនោះ។ អានេះខ្ញុំដឹង ម៉ោងបីខ្ញុំចេញមក។ បើលោកសួរខាងនោះ ឱ្យខ្ញុំឆ្លើយ ពិបាកឱ្យខ្ញុំឆ្លើយវណ្ណកខ្ញុំទៀត។ អានេះខ្ញុំជម្រាបលោកព្រះរាជអាជ្ញាត្រង់ លោកខាងអីខាង មិនសូវចេះដែរ អាហ្នឹងខ្ញុំពិការភ្នែកតែគ្រាន់នៅចាំ ទើបងងឹតដែរទេភ្នែកនេះ ពីមុននោះភ្លឺតើ។ សូមទោស បន្តយ៉ាងម៉េចទៀត កុំឱ្យវែងពេកដឹង។

**ស៖** តើលោកដឹងទេថា មានសមាជិកប៉ុន្មាននាក់មកពីកងពល១១៧រត់ចូលទៅវៀតណាមក្រោយការវាយប្រហារខែមេសា, ឧសភា ៧៧ហ្នឹង? តើលោកដឹងទេមានកងទ័ពប៉ុន្មានដែលរត់ទៅវៀតណាម?

[១៤:២៦:៥៣]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរនេះ។ សាក្សីមិនបាននិយាយអំពីការវាយប្រហារខែមីនា មេសា <ឧសភា> ៧៧ណាមួយទេ ហើយគាត់ក៏មិនបានយោងទៅលើកងទ័ពណារត់ទៅវៀតណាមក្រោយការវាយប្រហារទាំងអស់នោះដែរ។ ដូច្នេះខ្ញុំគិតថានេះជាសំណួរនាំមុខ។ សាក្សីគាត់អត់បានបញ្ជាក់អ្វីនៅក្នុងសក្ខីកម្មរបស់គាត់ទេ។ ដូច្នេះខ្ញុំគិតថា <គាត់កំពុងតែយល់ខុសចំពោះសក្ខីកម្មរបស់សាក្សី។> យើងបានស្តាប់ឮចម្លើយគាត់ឆ្លើយអស់ហើយថាគាត់មានព័ត៌មានតិចតួចប៉ុណ្ណោះ ឬក៏សឹងតែមិនមានទាល់តែសោះអំពីអ្នកណាដែលរត់ទៅវៀតណាមនៅពេលនោះ។ ដូច្នេះ ខ្ញុំគិតថាសំណួរនេះវាមិនត្រឹមត្រូវ វាមិនសមស្រប។ បើសិនមេធាវីការពារក្តីមានព័ត៌មានជាក់លាក់ណាមួយ អាចថាជាឯកសារជាក់លាក់ណាមួយ ឬក៏ឯកសារយោងជាក់លាក់ណាមួយដែលថាមានអ្នកណាម្នាក់រត់ទៅវៀតណាមនៅក្នុង<ខែឧសភា ឬ>ខែមេសា ខែមីនា ៧៧នោះ គាត់គួរតែបញ្ជាក់អំពីឯកសារនោះដើម្បីជាកំណត់ត្រា។ <ប៉ុន្តែសាក្សីនេះមិនបានផ្តល់ព័ត៌មាននោះដល់អង្គជំនុំជម្រះទេ។> ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរបែបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំប្រហែលជាច្រឡំ ឬក៏យល់ខុស ប៉ុន្តែខ្ញុំបានឮច្បាស់ថា សមាជិកកងពល១១៧បានរត់ចូលទៅវៀតណាម ហេតុដូច្នេះហើយទើបខ្ញុំសួរថាមានប៉ុន្មាន។ ដូច្នេះមិនអីទេ ខ្ញុំនឹងបញ្ជាក់ឱ្យបានច្បាស់ពី

ចំណុចនេះ។ ពាក់ព័ន្ធទៅនឹងព័ត៌មានដែលថា មានកងទ័ពបដិវត្តន៍កម្ពុជា <-- កម្ពុជាប្រជាធិបតេយ្យ> ណាមួយរត់ចូលទៅវៀតណាម ខែ<ឧសភា> ឬក៏<ខែមិថុនា> ៧៧ គឺថាភាគច្រើនយើងដឹងថា កងទ័ពរបស់នាយករដ្ឋមន្ត្រីបច្ចុប្បន្ន គឺសម្តេច ហ៊ុន សែន ហ្នឹងបានរត់ចូលទៅវៀតណាម។

**លោក វីល្លៀម ស្មឹត៖**

<បាទ លោកប្រធាន។>

[១៤:២៨:៣៩]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ? យ៉ាងម៉េចទៅឥឡូវពីរនាក់ងើបឈរ។ អញ្ជើញៗរៀបចំសំណួរសាជាថ្មី លោកមេធាវី វ៉ិចទ័រ កូប៉េ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ប្រហែលជាខ្ញុំស្តាប់លោកច្រឡំ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បើលោកមិនច្បាស់លាស់ លោកអាចសួរបញ្ជាក់គាត់សាជាថ្មីម្តងទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីអាចសំណួរបើកតែម្តងទៅ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមទោសឧបករណ៍ស្តាប់សំឡេងរបស់ខ្ញុំវាមិនឮសំណួរ។ ខ្ញុំចង់សួរថាតើមានសមាជិកកងពល១១៧ណាខ្លះ ដែលរត់ទៅវៀតណាមក្នុងខែ<ឧសភា មិថុនា> ៧៧ដែរទេ តើមានដែរឬទេ? ប្រសិនបើមាន តើមានប៉ុន្មាននាក់ដែរ? សូមលោកឆ្លើយ។

[១៤:២៩:៥៧]

**2-TCW-1005៖**

**ឆ៖** ខ្ញុំសូមឆ្លើយជូនថា បញ្ហាហ្នឹង ខ្ញុំក្តាប់អត់បាន។ ព្រោះខ្ញុំអត់បានដឹង ដល់អ៊ីចឹង ខ្ញុំដឹងឆ្លើយម៉េច ព្រោះខាងខ្ញុំដូចអត់មាន បើមានស្តាប់មាន។ តែដល់ថា មានរត់ចូលទៅយួន ខ្ញុំថាអត់មានទេ។ នេះជម្រាបត្រង់ ហើយតែបើកងតំបន់ កងអីយ៉ាងណា អាហ្នឹងខ្ញុំក្តាប់មិនបានទេ។ ប៉ុន្តែដោយឡែក ដែលយកទៅពីកំពង់ឆ្នាំងទៅ គឺអត់ទេ មានតែស្តាប់ ដោយៗរើគ្នាតែម្តង។ នេះដែលខ្ញុំដឹងតែប៉ុណ្ណឹងទេ តែដល់

កន្លែងផ្សេងទៀត អាហ្នឹងវាអាចដឹងបាន តែអាហ្នឹងផ្សេង វាក្រៅពីកន្លែងខ្ញុំ ខ្ញុំមិនអាចនិយាយបាន អាហ្នឹងដូចនិយាយ វាដឹង គ្រាន់តែបានមួយដឹង អាហ្នឹងធ្វើម៉េច។ អានេះ ខ្ញុំនិយាយត្រង់អ៊ីចឹងហ្នងទៅ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអរគុណ ដែលលោកសូមឆ្លើយតែអ្វីនៅទីតាំងចំពោះមុខលោក ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំបានហើយ។ ទីតាំងផ្សេងទៀត លោកមិនបាច់ឆ្លើយទេ វាជាការឆ្លើយស្មាន អាហ្នឹងមិនយកជាបានការទេ ណា៎។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកសាក្សី យើងបាននិយាយអំពីការវាយប្រហារ ឬក៏ការលុកលុយរបស់វៀតណាមនៅក្នុងខែ<> មេសា <ឬឧសភា> ៧៧ ជាពិសេសគឺការវាយប្រហារទៅលើចម្ការកៅស៊ូស្នួល។ ហើយព្រឹកមិញ លោកក៏បានផ្តល់ព័ត៌មានអំពីកាវាយលុករបស់កងទ័ពវៀតណាមនៅស្វាយរៀង ហើយនិងផ្នែកដទៃទៀត។ ដូច្នេះតើលោកធ្លាប់ឮដែរឬទេ ថាមានការវាយប្រហារនៅចម្ការកៅស៊ូស្នួល គឺជាផ្នែកមួយនៃផែនការដែលមានការរៀបចំក្នុងការវាយប្រហារ អាចថាជាការវាយប្រហារនៅចម្ការកៅស៊ូ ឬក៏ការវាយប្រហារនៅស្នួល គឺជាផ្នែកមួយនៃការវាយប្រហារជាច្រើនដែលធ្វើឡើងក្នុងពេលជាមួយគ្នា។ តើលោកធ្លាប់ឮអំពីការនិយាយអំពីផែនការនេះទេ?

[១៤:៣២:១១]

**2-TCW-1005៖**

**ឆ៖** ទេ អ៊ីចឹងបានព្រឹកមិញខ្ញុំបកអ៊ីចឹង បានលោកចេះតែសួរខ្ញុំ ដល់អ៊ីចឹងខ្ញុំចេះតែឆ្លល់ដែរ។ បញ្ហាបុកវ៉ៃលុកដែលខ្ញុំនិយាយពីព្រឹកនោះ ខ្ញុំបកចុះបកឡើងនោះ សាចុះសាឡើង ដល់សួរមកក្រឡឹងមកទៀត បញ្ហាហ្នឹងដដែលៗទេ។ បានន័យថា ឥឡូវបុក វាបុកទូទាំងប្រទេស មិនមែនបុកតែមួយច្រកខ្ញុំទេ។ អ្ហ៊! ដល់អ៊ីចឹង ដឹងយកពីណាទប់ត្រង់ណា។ អាហ្នឹងចង់និយាយពីត្រឹម៧៧ ៧៨អត់ទេ អាហ្នឹងខ្ញុំនិយាយអត់ទាន់ដល់ និយាយ៧៧នោះ។ ដូច្នេះខ្ញុំចង់និយាយថា បើលោកសួរខ្ញុំថា ព្រោះម៉េចក៏សួរហ្នឹងដល់ឥឡូវនេះ សួរអាហ្នឹងទៀត។ ដល់អ៊ីចឹងខ្ញុំឆ្លើយតែដដែលៗហ្នឹង ពីរថ្ងៃទៀត អត់ទាន់អស់រឿងផង។ នេះខ្ញុំនិយាយជាមួយលោកត្រង់អ៊ីចឹងហ្នង។ ចុះឥឡូវរឿងថាបុក ខ្ញុំដឹងថាបុកហើយពេលនុ៎ង តែបុកផែនការដឹងទាំងអស់ហើយ ព្រោះសារទូរលេខ ខាងលើណែនាំថា យួនបុកហើយ។ ដល់អ៊ីចឹងមិនមែនបុកតែច្រកខ្ញុំមួយឯណាទេ រតនគិរីក៏បុក មណ្ឌលគិរីក៏បុក ក្រចេះក៏បុក ខាងបូព៌ានេះក៏បុក មកតាកែវ

កណ្ដាលអីនេះ ក៏បុក ដល់អ៊ីចឹងទៅ កំពតក៏បុក។ អាហ្នឹង ខ្ញុំជម្រាបលោកត្រង់ទៅចុះ។ ដល់អ៊ីចឹងមួយប្រើប នៅតាកែវ ចូលដល់ប៉ុន្មាន តាកែវចូលដល់ឡើងគិរីវង់អស់មួយស្រុក កោះអណ្ដែតទៀត អាហ្នឹងខ្ញុំនិយាយខាងនុ៎ង។ បើខាងខ្ញុំនៅបានទប់ត្រឹមជាប់គល់ចម្ការកៅស៊ូ។ អានេះខ្ញុំជម្រាបលោកត្រង់ ប៉ុណ្ណឹងចុះ ហើយម៉េច លោកថាម៉េច។ សូមអរគុណ។

[១៤:៣៣:៤២]

**ស៖** សូមអរគុណច្រើនលោកសាក្សីដែលបានឆ្លើយ។ ប្រហែលខ្ញុំសួរលោកមិនច្បាស់ ខ្ញុំចង់សួរថា តើលោកធ្លាប់ឮថា ការវាយប្រហារទាំងអស់នេះ គឺជាការវាយប្រហារដែលមានការសម្របសម្រួលដែលមានការដឹកនាំ មានការរៀបចំ មានការបញ្ជា ឬមួយក៏ថា តើជាការវាយប្រហារដោយចៃដន្យនោះទេ? ដូច្នេះខ្ញុំចង់សួរលោកថា តើការវាយប្រហារទាំងអស់ដែលលោកបាននិយាយកន្លងមកនេះ ដែលកើតឡើងនៅក្នុងខែមេសា ៧៧ហ្នឹង ថាតើមានការរៀបចំដឹកនាំ ឬមួយក៏លោកអត់ដឹងទេ?

**ឆ៖** បញ្ហាលោកសួរខ្ញុំខាងក្រោម ខ្ញុំចង់និយាយខាងលើ ឲ្យសារទូរលេខមក គ្រាន់តែថា យួនបុកយើងហើយ អាហ្នឹងតាមសារណ៍។ ដូច្នេះខ្ញុំចង់ឲ្យបកទៅវិញថា ដឹងថា សភាពការណ៍យួនបុកហើយ អ៊ូ! ដឹងតែប៉ុណ្ណឹងទេអាហ្នឹងខ្ញុំ។ ដល់អ៊ីចឹង វាបុកទូទាំងប្រទេសមែន។ ហើយលោកសួរខ្ញុំថាម៉េចទៀត បើថាដឹង រឿងទ្រង់ទ្រាយ ដឹងថាទ្រង់ទ្រាយហើយ បើ២៥០.០០០ មក៧៨នេះ អាហ្នឹងខ្ញុំនិយាយរំលងហួស៧៧ចុះ។ ហើយទ័ពកម្ពុជាប្រជាធិបតេយ្យមានប៉ុន្មាន អត់ដល់១០០.០០០នាក់ផងហ្នឹង។ អាហ្នឹងខ្ញុំនិយាយកាត់ជាមួយលោកឲ្យត្រង់បណ្ដោយចុះ។ ព្រោះព្រឹកមិញលោកសួរខ្ញុំអាហ្នឹងដែរ ព្រោះឥឡូវខ្ញុំឆ្លើយអាហ្នឹងហើយ ព្រោះថាខ្ញុំមិនមែនបានដឹងអីទាំងអស់ទេ។ ខ្ញុំដឹងតែច្រកខ្ញុំបុកហើយ តែបុកមិនបុកពីខាងខ្ញុំទេ បុកទូទាំងប្រទេស។ ហើយខ្ញុំដឹងតែច្រកខ្ញុំទេ គ្រាន់តែខាងលើណែនាំមកថា យួនបុកហើយ ត្រូវត្រៀម តែប៉ុណ្ណឹង។ សូមអរគុណ។

[១៤:៣៥:២១]

**ស៖** ខ្ញុំនឹងលើកនូវអ្វីដែលលោកបានផ្ដល់សក្ខីកម្មកន្លងមក ដែលលោកនិយាយអំពី<> កងទ័ពកម្ពុជាប្រជាធិបតេយ្យមួយចំនួនដែលចូលដៃជាមួយកងទ័ពវៀតណាម។ តើលោកដឹងទេថា មានព័ត៌មានដែលថា កងទ័ពកម្ពុជាប្រជាធិបតេយ្យផ្ដល់ស្បៀងអាហារ ឬក៏អាវុធទៅដល់កងទ័ពវៀតណាមទេ?

**ឆ៖** ដល់លោកសួរខ្ញុំអ៊ីចឹងទៅ ទៅជាខ្ញុំហ្នឹងដឹកនាំជាន់ខ្ពស់ទៅទៀត វាពិបាកខ្ញុំឆ្លើយ។ បើខ្ញុំដឹង

ក៏មិនដឹងឆ្លើយថាម៉េច។ អានេះខ្ញុំឆ្លើយត្រង់តែម្តងទៅចុះ ព្រោះឥឡូវបើលោកនិយាយសួរអ៊ីចឹង ធម្មតាកាំភ្លើងជំនាន់នោះ ខ្វះអី។ វៀតណាមទៅខ្វះអីកាំភ្លើង គេមកយកពីខាងយើងធ្វើអី សំខាន់បើគេបុកមកយើង អាហ្នឹងលោកសួរខ្ញុំហ្នឹង ចង់ឲ្យខ្ញុំឆ្លើយទៅបង្វែរទៅផ្សេងទៅទៀតហើយនេះ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី គេគ្រាន់តែសួរថា តើលោកដឹងឬអត់ បានហើយ។ ប្រសិនបើលោកមិនដឹងទេ ឆ្លើយថាមិនដឹងទៅ ចប់ហើយ ជាការឆ្លើយតបនឹងសំណួរហើយ។ បើលោកដឹង អាហ្នឹងសូមលោករៀបរាប់ជាបន្តទៀតនូវការដឹងរបស់លោក។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដឹងទេថា តើលោកស្គាល់មេបញ្ជាការកងពល៨០១ទេ?

**2-TCW-1005៖**

**ឆ៖** បាទ ខ្ញុំស្គាល់តើ! បង០៥ បងសារឿន គាត់គណៈភូមិភាគឦសាន។ ហ្នឹងខ្ញុំស្គាល់ច្បាស់តែម្តង។

[១៤:៣៧:៣១]

**ស៖** តើលោកស្គាល់ -- លោកថា លោកស្គាល់គាត់ច្បាស់ តើលោកស្គាល់គាត់ច្បាស់ហ្នឹងច្បាស់ដល់កម្រិតណាដែរ?

**ឆ៖** ខ្ញុំមិនមែនស្គាល់ច្បាស់ដល់កម្រិតរាក់ទាក់ស្និទ្ធស្នាលទេ គ្រាន់តែស្គាល់ថា ស្រុកកំណើតគាត់នៅស្រែក្នុង ហើយគាត់មកនៅទីនុ៎ង។ អាហ្នឹងដឹង ព្រោះថាស្រុកកំណើតជិតគ្នាដែរ វាមិនឆ្ងាយទេ ព្រោះគាត់បញ្ជូនមកពីខាងកើត ស្រុកខាងកើតហ្នឹងដែរបាទ។ ហ្នឹងខ្ញុំចង់ថាស្គាល់ហ្នឹង គឺស្គាល់អ៊ីចឹង។ ហើយដល់ការទំនាក់ទំនង ក៏ចេះតែហូរហែមករហូតអ៊ីចឹងមក។ តាមសារទូរលេខ តាមសារអីហ្នឹងក៏ទំនាក់ទំនង ព្រោះកន្លងទៅដឹកសម្ភារៈអីក៏ចេញចូលពីកន្លែងខ្ញុំទៅអ៊ីចឹងទៅ ព្រោះខាងគាត់ទៅណោះទៅឆ្លងកប៉ាល់ទៅ បានតែកប៉ាល់តូចៗទេ បានតែទូកអីតូចៗដឹកសម្ភារៈទៅគាត់។ ដល់អ៊ីចឹងយកមកទុកតែកន្លែងខ្ញុំ ថ្មគ្រែហ្នឹង ៨០១, ៩២០ នៅជិតគ្នាហ្នឹងហើយ។ នៅថ្មគ្រែហ្នឹង ហើយខ្ញុំដាក់នៅក្រគរហ្នឹងជិតគ្នាហ្នឹង។ ដល់អ៊ីចឹងការទំនាក់ទំនងប្រាស្រ័យទាក់ទងខ្វះខាត ខ្វះជាសម្លៀកបំពាក់កងទ័ព ឬក៏ខ្វះជាគ្រាប់ ឬក៏ជាស្អី អាហ្នឹងខ្ញុំអាចជូនគាត់បាន ដឹកជូនគាត់។ អាហ្នឹងចង់និយាយថាជិតស្និទ្ធ មិនជិតស្និទ្ធអីធំដុំទេ គ្រាន់តែការទំនាក់ទំនងប្រាស្រ័យទាក់ទងគ្នាវាផ្លូវច្រកតែមួយ។ នេះជម្រាបលោកប៉ុណ្ណឹង។ សូម

អរគុណ។

[១៤:៣៩:០០]

**ស៖** មេបញ្ជាការ<កងពល>១១៧ គឺឈ្មោះ រុំ។ តើ រុំ មានឋានៈ ឬក៏មានឋានានុក្រមស្មើ រឿន ដែលយើងហៅថា បង០៥ ហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំចម្លើយនេះ ខ្ញុំភ្លាប់បាន ហើយក៏ខ្ញុំរស់នៅជាមួយគាត់ មិនអាចសិទ្ធិស្មើនឹង ពូ០៥ ទេ ព្រោះ ពូ០៥ គាត់គណៈភូមិភាគផង គាត់មេបញ្ជាការកងពលផង។ បើបងរុំ គឺគាត់ត្រឹមឋានៈកងពល ឡើងក្រោយនេះទេ។ បងរុំ បើគិតទៅសិទ្ធិគាត់ទើបឡើង៧៧នេះទេ ពីមុនគាត់នៅអីណោះ អីកោះកុងនោះទេ។ គាត់ទើបយកមកដាក់នៅជាមួយ បងឡូញ ឯកោះកុងនោះទេ។ អាហ្នឹងខ្ញុំនិយាយ អាហ្នឹងតាមខ្ញុំដឹងប្រវត្តិ អ៊ីចឹងបានខ្ញុំរាយការណ៍ដោយត្រង់ដែលខ្ញុំដឹង។ តែកន្លែងណាដែលខ្ញុំអត់ដឹង ខ្ញុំនិយាយអត់កើតទេ។ ព្រោះ ពូ០៥ គាត់ ឋានៈគាត់គណៈភូមិភាគ គាត់គ្រប់គ្រងបីខេត្តផង។ កងពលគាត់គ្រប់គ្រង៨០១ផង ៩២០នៅមណ្ឌលគិរីនេះផង ខាងខ្ញុំនេះទើបកាត់ចេញពីគាត់ ពេលឃ្មួនបុក៧៨ហើយនេះទេ។ អាហ្នឹងខ្ញុំជម្រាបត្រង់។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកមេធាវី។ ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅលោក

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01329837



មេធាវី វ៉ិចទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី យើងបាននិយាយគ្នាអំពីកងពល៨១០ គឺមេបញ្ជាការឈ្មោះ រឿន ៨០១ គឺមេបញ្ជាការ រឿន និង<កងពល១១៧> បញ្ជាការឈ្មោះ រ៉ុ។ តើលោកដឹងថា រ៉ុ និង រឿន ទាក់ទងគ្នាដោយផ្ទាល់ ឬក៏ពួកគាត់ទាក់ទងគ្នាតាមរយៈអគ្គសេនាធិការ? គឺតាមរយៈបង៨៩ – សុន សេន នេះឯង លោកដឹងដែរទេ?

**2-TCW-1005៖**

**ឆ៖** បញ្ហានេះ ខ្ញុំសូមជម្រាបលោកដោយត្រង់ ដែលខ្ញុំដឹងទេ ព្រោះគាត់ បញ្ហាទំនាក់ទំនងគ្នាគាត់ទាក់ទងតាមរយៈសារទូរលេខ ឬក៏ផ្ទាល់ ព្រោះគាត់ចេញចូលមក ព្រោះសម្ភារៈនៅទុកនៅនឹងថ្មគ្រែនោះ ៨០១នៅជិតខ្ញុំនេះឯង។ ដែលយើង សម្ភារៈជាសម្លៀកបំពាក់ ឬក៏ជាអាវុធអី គ្រាប់អីវាត្រូវនៅឃ្លាំងគាត់នៅត្រង់ហ្នឹងជិតហ្នឹងមួយកន្លែង ជិតខ្ញុំហ្នឹង ជិតកន្លែងខ្ញុំហ្នឹង។ ដល់អ៊ីចឹងទៅ ការទំនាក់ទំនងមិនមែនឆ្លងទៅដល់អគ្គសេនាធិការអីទេ ព្រោះអាហ្នឹងវានៅហ្នឹង អាចទាក់ទងគ្នាបាន ជិតហ្នឹងតាមរយៈសារទូរលេខ តាមរយៈអី តេអូមួយចំនួន។ អាហ្នឹងផ្ទាល់ គាត់មិនដែលបានជួបផ្ទាល់ប៉ុន្មាន ព្រោះ ពូរ៉ុគាត់នៅមុខអ៊ីចឹងទៅ បង០៥ គាត់នៅ ពូ០៥ គាត់នៅរតនគិរីឯណោះ។ អាហ្នឹងបញ្ហាការទំនាក់ទំនងបញ្ហាទៅអគ្គសេនាធិការហ្នឹង ខ្ញុំអត់បានយល់ទេបញ្ហាហ្នឹង ប៉ុន្តែកន្លងទៅគាត់មិនដែលបានទំនាក់ទំនងអារឿងទៅអគ្គសេនាធិការជុំគ្នាទេ ព្រោះរាយការណ៍ផ្សេងគ្នា ខាងគាត់រាយការណ៍ទៅផ្សេងទៅ ខាងខ្ញុំរាយការណ៍ផ្សេងទៅ។ បាទ អាហ្នឹងបញ្ហាដែលខ្ញុំដឹង គឺប៉ុណ្ណឹង។ សូមអរគុណ។

[១៥:០៣:០៤]

**ស៖** តើនៅពេលនោះ លោកដឹងថា មេបញ្ជាការ រឿន ឬក៏មេបញ្ជាការរបស់លោកឈ្មោះ រ៉ុនេះ នៅបំណាច់ខែមីនានោះ ដឹងថាកងទ័ពវៀតណាមមានផែនការវាយប្រហារចូលមកក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុង<ខែមេសា> ឆ្នាំ១៩៧៧នោះដែរទេ?

**ឆ៖** បាទ បញ្ហាហ្នឹងគាត់ដឹងតើ មានផែនការដូចគ្នា។ មិនមែនគាត់មិនដឹងឯណា គាត់ដឹងតើថ្ងៃ អាថ្ងៃរឿងបុករឿងអីហ្នឹងគាត់ដឹងតើ គាត់បានទំនាក់ទំនងគ្នាតាមរយៈទូរលេខ តាមរយៈតេអូអី

ហើយអស់ ដឹងតើ តែគ្រាន់តែកម្លាំងយើងវាតិច កម្លាំងគេវាច្រើនតែប៉ុណ្ណឹង។ អាហ្នឹងដែលៗតាមខ្ញុំដឹង ព្រោះសម្ភារៈអីត្រៀមហើយអស់ ហើយគ្រាប់អីដឹកទៅអស់ហើយ។ ដឹកបញ្ជូនពីកន្លែងខ្ញុំទៅ ព្រោះខ្ញុំផែហ្នឹងត្រូវដឹកមេគង្គអាធំ អាកប៉ាល់០៧ អាធំៗហ្នឹង យកមកដាក់កន្លែងខ្ញុំពីរគ្រឿង សម្រាប់បញ្ជូនចេញពីភ្នំពេញតែម្តង សម្រាប់ចែកចាយឲ្យគាត់ទៅនោះ។ ឃ្លាំងគាត់នៅកន្លែងថ្មក្រែហ្នឹង ត្រូវបញ្ជូនឡានចេញពីហ្នឹងទៅ ព្រោះដឹកតាមកាណូតតូចៗ មិនងាយបានដឹកទៅដល់ទេ។ អាហ្នឹងខ្ញុំចង់បញ្ជាក់ជូនលោកប៉ុណ្ណឹង ព្រោះថាដឹងផែនការ ដឹង តែគ្រាន់ថា ត្រង់ទប់ជាប់មិនជាប់ ហ្នឹងដែលខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង។ សូមអរគុណ។

[១៥:០៤:៤២]

**ស៖** តើលោកដឹងថា រុំ និង វឿន ប្រហែលជាអាចមេបញ្ជាការកងពលដទៃៗទៀតផងដែរ ដឹងថានៅបំណាច់ខែមីនា ឆ្នាំ១៩៧៧ គឺថាកងទ័ពវៀតណាមរៀបផែនការនឹងវាយប្រយុទ្ធចូលមកនៅក្នុងខែមេសានោះដែរទេ? <តើបានប្រភពព័ត៌មាននោះមកពីណា? តើលោកដឹងទេ?>

**ឆ៖** ខ្ញុំសូមជម្រាបលោកដដែលៗថា ខាងលើគាត់ដឹងហើយ ដឹងរៀបចំហើយអស់ហើយក្នុងអំឡុងនុ៎ង។ តែដោយឡែកខាងខ្ញុំ គឺដឹងតែច្រកដែលជិតៗគ្នាហ្នឹង គឺដឹងបានត្រៀមលក្ខណៈសម្បត្តិ។ តែខាងជិតៗហ្នឹង ហើយនិងខាងខ្ញុំដឹងហ្នឹង គឺដឹងតែប៉ុណ្ណឹងទេ។ តែដល់តែទៅកន្លែងផ្សេង ក៏ដឹងដូចគ្នាដែរ តែខាងនុ៎ង ខ្ញុំមិនបានដឹងទាំងស្រុកទេ ព្រោះខ្ញុំគិតតែកន្លែងខ្ញុំដែរ ហើយគិតតែកន្លែងជិតខ្ញុំដែរ។ ដល់ទៅខ្ញុំដឹងកន្លែងផ្សេងទៀត ខ្ញុំអត់បានដឹងទេ។ តែគ្រាន់តែផែនការតែមួយទេ បើតាមខ្ញុំយល់។ បាទ មានតែប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់ដឹងឲ្យបានច្បាស់បន្តិច តើពេលហ្នឹងនៅមុំថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ មែនទេ?

**ឆ៖** ខ្ញុំទៅ កាលពីខ្ញុំទៅហ្នឹង ខ្ញុំទៅមុន មិនដល់ទេ រួចដល់ក្រោយហ្នឹងក៏មិនដឹង មុនហ្នឹងក៏មិនដឹង ខ្ញុំមិនបានចាំទេ អាហ្នឹងកាលពីខ្ញុំទៅខែបីនោះ ព្រោះខ្ញុំទៅដល់ហ្នឹង វាសភាពការណ៍បុកទៅហើយ។ តែដល់ពេលអ៊ីចឹងទៅ ការត្រៀមខាងក្រោយទៀត ទៅដល់រុញគ្នាបានខ្លះ អាហ្នឹងបើតាមថ្ងៃទី ខ្ញុំមិនបានចាំទេ។ ខ្ញុំដឹងតែក្នុងខែ អំឡុងខែ៣, ខែ៤ហ្នឹងគឺខ្ញុំដឹង ព្រោះពេលហ្នឹងខ្ញុំមិនទាន់បានគិតចាប់អារម្មណ៍ថារឿងថ្ងៃទីអីឲ្យច្បាស់លាស់ទេ អាហ្នឹង។ សូមអរគុណ។

[១៥:០៦:៥៣]

**ស៖** ក្រោយការប្រយុទ្ធនៅខែមេសា ឆ្នាំ១៩៧៧ ពីសំណាក់កងទ័ពវៀតណាម តើមានការចាត់

វិធានការណាមួយពាក់ព័ន្ធទៅនឹងការរឹតបន្តឹងការប្រើប្រាស់វិទ្យុទាក់ទង ឬក៏សារទូលេខនៅក្នុងកងពល ១១៧ នោះដែរទេ? តើមានការលំបាកនៅក្នុងការប្រើប្រាស់សារទូលេខ ឬក៏វិទ្យុទាក់ទងនោះដែរទេ?

**ឆ៖** បញ្ហានុ៎ង ខ្ញុំសូមជម្រាបថា សម្ភារៈយោធា ចង់និយាយថា បើនិយាយចំហដូចបច្ចុប្បន្ននេះ មិនបានទេ។ ធម្មតារឹតបន្តឹង ៗសុំដូរអក្ខរៈ ឬក៏សុំដូរអ្នកបញ្ជូនសារ។ អាហ្នឹងបញ្ហាហ្នឹង វាមានមែន។ ធម្មតាត្រូវតែដូរខ្លះហើយ ព្រោះធម្មតាសារទូលេខ ពីព្រោះវាមានបែកការណ៍អ៊ីចឹង។ អ៊ីចឹងបញ្ហាលោកសួរអ៊ីចឹង ខ្ញុំសូមជម្រាបទៅតាមខ្ញុំដឹងហ្នឹង ចង់និយាយថា ឥឡូវយើងអ្នកបញ្ជូនហ្នឹង ត្រូវដូរអ្នកនុ៎ងមក អ្នកបកក៏ត្រូវដូរអ្នកមក ព្រោះអ្នកបកផ្សេង អ្នកបញ្ជូនផ្សេង អត់មានឲ្យលាយលំគ្នាដូចឥឡូវទេ។ ការរឹតបន្តឹងមិនមែនទេ។ បើតែអូនិយាយធម្មតាចុះ។ តែអូក៏មានអក្ខរៈដែរ ហៅលេខ តែហៅលេខ ជួនកាលគេបន្ថំលេខហ្នឹងបានទៀត។ ឧទាហរណ៍ថា ដាក់លេខអក្ខរៈថាស្លាប់ហ្នឹង ត្រូវលេខ១០០អ៊ីចឹង ឧទាហរណ៍អ៊ីចឹង ដល់មានគេបន្ថំមក បន្ថែមពីលើហ្នឹង ២០០អ៊ីចឹងទៀត ឧទាហរណ៍អ៊ីចឹង។ អ៊ីចឹងបានថាការរឹងបន្តឹង ធម្មតាច្បាប់យោធា ត្រូវផ្លាស់ប្ដូរជាប្រចាំក្នុងមួយខែ ឬកន្លះខែ ត្រូវដូរអក្ខរៈម្ដងហើយ។ អាហ្នឹងខ្ញុំសូមជម្រាបលោក ជូនលោកជាដំណឹងដែលខ្ញុំដឹងប៉ុណ្ណឹងចុះ។ បាទ សូមអរគុណ។

[១៥:០៨:៣៨]

**ស៖** ក៏ប៉ុន្តែព្រឹកមិញនេះ លោកនិយាយថា កងទ័ពវៀតណាមបានវាយប្រយុទ្ធពីខាងក្រោយមកតាមទីតាំងផ្សេងៗ ដោយមិនបានដឹងជាមុន។ ក្រោយការវាយប្រហារនេះ ថាតើមានការចាត់វិធានការប្រុងប្រយ័ត្ន ដោយកំណត់ថាអ្នកណាត្រូវជាអ្នកប្រើប្រាស់សារទូលេខ ឬវិទ្យុទាក់ទងទេ? តើមានវិធានការណាមួយត្រូវបានធ្វើឡើងដើម្បីរឹតបន្តឹងទៅលើបញ្ហាសុវត្ថិភាពហ្នឹងទេ<ក្រោយការវាយប្រហារនៅខែមេសានោះ>?

**លោក វីណ្ដៀម ស្មីត៖**

ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរនេះ។ ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរនេះ ដោយមានយកអង្គហេតុមួយចំនួនយកមកដាក់បញ្ចូល។ គឺថាមានអង្គហេតុពីរដែលដាក់បញ្ចូលរួមគ្នា ដោយសាក្សីមិនបានលើកឡើងយកមកនិយាយទេ គឺនៅខែមីនា និងខែមេសា ឆ្នាំ១៩៧៧ នៅពេលដែលមានការវាយប្រហារនៅស្រុកស្នួល មានការវាយប្រហារមកពីខាងក្រោយ ក៏ដូចជាការវាយប្រហារពីខាងមុខតែម្ដង <ដែលនិយាយអំពីគំនិតចូលដៃគ្នា>។ សាក្សីមិនបាននិយាយពីរឿងនេះពាក់ព័ន្ធទៅនឹងការវាយប្រយុទ្ធនៅខែមីនា និងខែមេសា ឆ្នាំ១៩៧៧ នោះទេ។ អ៊ីចឹងការតាំងសំណួរបែបនេះ គឺថាយកអង្គហេតុពីរមក

ច្របាច់បញ្ចូលគ្នា ដោយលើកឡើងថាមានការវាយប្រយុទ្ធពីខាងក្រោយ និងមានការវាយប្រយុទ្ធមកពីខាងមុខផងដែរ នៅក្នុងខែមីនា និងខែមេសា ឆ្នាំ១៩៧៧ ដែលសាក្សីមិនបានលើកឡើងអំពីរឿងនេះទាល់តែសោះ។ ដូច្នេះ គួរតែបំបែកបញ្ហានេះទៅជាពីរ ដើម្បីកុំឲ្យមានការច្រឡូកច្របល់។

[១៥:១០:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាមានការជំទាស់ពីខាងដើមរួចមកហើយ គឺថាខ្ញុំបានដកស្រង់សម្ដីរបស់សាក្សី ប្រហែលជាទាក់ទងទៅនឹងព្រឹត្តិការណ៍នៅចុងឆ្នាំ១៩៧៨ អ៊ីចឹងហើយខ្ញុំសួរសំណួរបើក។ ហើយនៅក្នុងចម្លើយរបស់គាត់ទាក់ទងទៅនឹងព្រឹត្តិការណ៍ខែមីនា, មេសា ៧៧ នោះគឺ គាត់បាននិយាយថា វៀតណាមនេះជាអ្នកចាប់ផ្ដើមវាយប្រហារមកមុន ហើយវាយប្រហារទាំងពីខាងមុខ ពីខាងក្រោយផងដែរ<ដោយមិនបានដឹងជាមុន។ ដូច្នេះខ្ញុំជឿថា នេះជាចម្លើយរបស់គាត់។>។ ខ្ញុំទទួលស្គាល់<ថា> ពេលនោះ<>មានការជំទាស់<>។ ខ្ញុំក៏រៀបចំសំណួរឡើងវិញ ហើយសាក្សីគាត់លើកឡើងពីព្រឹត្តិការណ៍ជាក់លាក់នៅក្នុងឆ្នាំ១៩៧៧នេះ។ ដូច្នេះខ្ញុំយល់ថា ខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យតាំងសំណួរបែបនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១២:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្ដីសម្រេចរបស់ -- នូវសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិចំពោះសំណួរនេះ។ ហើយសូមលោកមេធាវី វ៉ិចទ័រ កូប៉េ រៀបចំសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត ដើម្បីឲ្យសាក្សីស្ដាប់បាន ហើយនិងអាចឆ្លើយតបនឹងសំណួរបាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីការពារក្ដីរៀបសំណួរឲ្យបានស្រួលបួលបន្តិចមក ខ្ញុំយល់ថាសាក្សីមិនយល់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ លោកសាក្សី ក្រោយការវាយប្រហារនៅខែមេសា ឆ្នាំ១៩៧៧។ តើគេមានចាត់វិធានការអ្វីបន្ថែមពាក់ព័ន្ធទៅនឹងការប្រើប្រាស់វិទ្យុទាក់ទង ឬក៏ឧបករណ៍សារទូរលេខណាមួយដែរទេ? តើគេមានចាត់វិធានការប្រុងប្រយ័ត្នណាបន្ថែមទៀត ពាក់ព័ន្ធទៅនឹងការប្រើ

ប្រាស់សារទូរលេខ និងវិទ្យុទាក់ទងដែរឬទេ?

[១៥:១៣:១១]

**2-TCW-1005៖**

**ឆ៖** បាទបញ្ហាហ្នឹងខ្ញុំសូមបកស្រាយជូនលោកថា ការរៀបចំរបស់យោធាតែងតែមានផ្លាស់ប្ដូរ ព្រោះឧទាហរណ៍ខែហ្នឹង ត្រូវដូរក្នុងកន្លះខែម្ដង ឬក៏មួយខែម្ដង តាមអក្ខរៈ តាមវិទ្យុទាក់ទងនៅប្រើធម្មតា តែដូរតែអក្ខរៈ និងដូរមនុស្សមួយចំនួនដែលបញ្ជូនសារ ឬអ្នកបក។ ធម្មតាអ្នកបកអត់ចេះវាយទេ ជួនកាលអាហ្នឹងវាប្រើពីរនាក់ បកម្នាក់ បញ្ជូនសារម្នាក់។ អ៊ីចឹងអាចដូរតែអក្ខរៈ និងដូរមនុស្សមួយចំនួនអ៊ីចឹង ផ្លាស់ពីកងនេះ មកកងនេះអ៊ីចឹងមក ផ្លាស់ពីៗមុខមកក្រោយអ៊ីចឹងតែប៉ុណ្ណឹងទេ។ ដូច្នេះអត់មានកែប្រែអីទេ គ្រាន់តែដូរអក្ខរៈ បកសារតែប៉ុណ្ណឹង ហើយនិងវិទ្យុទាក់ទងក៏ប្រើជាអក្ខរៈទៅ ប្រើជាសារដូចទូរលេខដែរអ៊ីចឹងក៏អាចប្រើបាន អត់មានរឹតបន្តឹងអីប៉ុន្មានទេកាលជំនាន់ខ្ញុំនៅ ព្រោះសំខាន់គឺយើងដូរអក្ខរៈអស់ហើយ។ ប៉ុន្តែក្នុងហ្នឹងហើយ វាអាចនូវមានប៉ះទង្គិចឆ្លងកាត់ទៀត អាហ្នឹងវាបន្តទៅកន្លះខែ ឬអីមួយខែហ្នឹងត្រូវដូរម្ដង មិនអាចទុកយូរបានទេ។ បាទ សូមអរគុណ។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរបន្តពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយពីខាងដើមរួចមកហើយ។ នៅក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺE3/9647, អង់គ្លេស <01212312>, ខ្មែរ 00975742, បារាំង 00996581។ លោកត្រូវបានគេសួរពីឈ្មោះ វន វ៉េត ថា វន វ៉េត នៅពេលនោះគឺជាអ្នកទទួលខុសត្រូវនៅសមរភូមិ។ ហើយខ្ញុំនឹងដកស្រង់សម្ដីរបស់លោកនៅក្នុងចម្លើយនេះ។ “ខ្ញុំសូមឲ្យខ្ញុំជម្រាបលោកអំពី អ៊ំវន វ៉េត។ យួននេះគឺថាវាយប្រយុទ្ធពីគ្រប់ទិសទីទាំងអស់។ ពេលនោះគេមិនទាន់កាន់កាប់ស្នួលបាននៅឡើយទេ។ ស្នួលហ្នឹង គឺថាគឺជាកន្លែងដែលគេអារឈើ។ ខ្ញុំស្ដាប់ឮតាមវិទ្យុ។ ម្នាក់ៗ បានសម្រេចព្រមគ្នាថា អ៊ំវន វ៉េត នេះគួរតែមកចុះមកបញ្ជាកងទ័ពតែម្ដង។ នេះឮតាមតាមវិទ្យុថា គាត់គួរតែចុះមកបញ្ជាកងទ័ពផ្ទាល់តែម្ដង។”

ខ្ញុំគិតថា នេះនៅក្នុងឆ្នាំ១៩៧៨ទេ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោក លោកថា កងទ័ពវៀតណាមមិនទាន់រឹបអូសបានស្នួលនៅឡើយទេ។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ ថាតើស្នួល ឬក៏ចម្ការកៅស៊ូនេះ ត្រូវរឹបអូសបាននៅខែមេសា ឆ្នាំ៧៧ ហើយកងទ័ពវៀតណាមចេញទៅវិញ ឬក៏យ៉ាងម៉េច? ហើយកងទ័ពវៀតណាម<មិនទាន់>រឹបអូសបាននៅចុងឆ្នាំ៧៨ ឬក៏យ៉ាងណា?

[១៥:១៦:២១]

**ឆ៖** បាទ ខ្ញុំសូមបកស្រាយជូនលោកឲ្យច្បាស់ ថាខ្ញុំនិយាយជាមួយឯកសារកម្ពុជា មិនមែនឲ្យ អ៊ំវន វ៉េត ទៅបញ្ជាកងទ័ពនៅខាងនោះទេ។ ការបញ្ជាហ្នឹង មិនដឹងជាខ្ញុំនិយាយយ៉ាងម៉េច ព្រោះថា ខ្ញុំថា អ៊ំវន វ៉េត ទៅពី៧៨នេះទេនេះ។ ក្នុងនិយាយ ខ្ញុំនិយាយថា យួនបុកមកចម្ការកៅស៊ូស្នួល មិនមែនយកបានស្រុកស្នួលទាំងមូលទេ។ ខ្ញុំនិយាយសំដៅថា ចម្ការកៅស៊ូស្នួល យួនវាយពី៧៧។ រុញគ្នាទៅ រុញគ្នាមកដដែល នៅតែត្រង់នុ៎ង ឡើងចុះ ខ្ញុំរុញគេទៅ គេរុញខ្ញុំមក ក៏នៅតែចម្ការកៅស៊ូស្នួល តែមិនមែនស្រុកស្នួលទាំងមូលទេ។ ទើបតែ៧៨នេះទេ រោងចក្រអារឈើយ្យើមហ្នឹងគឺ ស្នួលហ្នឹងគឺនៅដដែល។ វាៗយករោងចក្រអារឈើហ្នឹង តែដល់៧៨នេះ យើងក៏យើងយកបានវិញ ក្រោយ៧៨ ចុង៧៨នេះ បានវាបុកមកវិញមួយសាទៀត បានវាយកស្នួលបានទាំងមូលនេះ ពីថ្ងៃទី១១ ខែ១០ទេ។ នេះខ្ញុំចង់ជម្រាបលោកឲ្យដឹងថា មិនមែនយកស្រុកស្នួលបានទាំងមូលពី៧៧នុ៎ងទេ គឺយកស្រុកស្នួលបានទាំងមូលត្រឹមថ្ងៃទី១១ ខែ១០ ៧៨ ដែលយកយន្តហោះវាបួនគ្រឿង និងទ័ពវៀតណាមមកបុកហ្នឹង គឺខ្ញុំចង់ជម្រាបលោកអ៊ីចឹង។ ហ្នឹងស្តាប់ឲ្យទាន់ កុំឲ្យថាបកច្រឡំនោះ។ បកច្រឡំថា យកស្នួលបានពី៧៧ មិនមែនទេ ៧៧ខ្ញុំនៅនុ៎ងទេ។ ក្នុងនុ៎ង តែគ្រាន់រុញគ្នាក្នុងខែ៤នេះ ខែ៤ដែលវាបុកមកខាងហ្នឹង រុញទៅរុញមក រុញទៅដល់ខាងកើតផ្លូវលេខ៧ ទៅដល់វាលស្រែ វាលអីជាប់ឯតែនិញអីអ៊ីចឹង។ រុញចុះរុញឡើងហ្នឹង អាហ្នឹងចង់និយាយក្នុងអំឡុង៧៧ ចិត ចុងដើម៧៨ហើយហ្នឹង អត់ទាន់បានទេស្រុកស្នួល គឺនៅៗក្នុងៗៗខាងខ្ញុំកាន់កាប់ទេ តែដល់៧៨បានយកទាំងស្រុង។ ចង់និយាយ ហ្នឹងសូមលោកបកអាហ្នឹងចំ ព្រោះភាសាអង់គ្លេស ខ្លាចៗខ្ញុំនិយាយច្រឡំ។ ហើយអ៊ំវន វ៉េត ក៏ខ្ញុំមិនបានថា ស្តាប់វិទ្យុទាក់ទងពីណាឲ្យ អ៊ំវន វ៉េត ទៅបញ្ជានៅខាងនុ៎ង។ នេះខ្ញុំសូមៗបកៗត្រឡប់ជូនលោកវិញ ព្រោះអ៊ំវន វ៉េត គាត់ទើបនឹងឡើងជើងគោកហ្នឹង ពេលដែលយួនបុកខ្លាំងនេះទេ ពី៧៨នេះទេ តាមខ្ញុំដឹង ដែលគាត់ទៅទស្សនកិច្ចហើយមកវិញចាប់នេះ។ ព្រោះវិទ្យុហ្នឹង បើតាមខ្ញុំដឹង វិទ្យុដែលៗដែលវិទ្យុ២ធ្នូទេ ដែលវិទ្យុហ្នឹង ព្រោះ វន វ៉េត ចាប់ហើយ បានៗមាន២ធ្នូនេះ។ ហ្នឹងខ្ញុំជម្រាបដែលខ្ញុំដឹងទេអាហ្នឹង វិទ្យុហ្នឹងឮចាក់ភ្លេងការនៅត្រង់នុ៎ង ហើយខ្ញុំនៅព្រែកទេរខាងលិចព្រែកទេរនុ៎ង។ ហ្នឹងខ្ញុំនិយាយឲ្យវែង ខ្ញុំជម្រាបលោកដែលខ្ញុំនៅត្រង់នុ៎ងចុះ។ សូមអរគុណ។

[១៥:១៨:៤៩]

**ស៖** លោកបានលើកឡើងអំពីការវាយប្រយុទ្ធមួយទៀត ពីសំណាក់វៀតណាមនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ៧៨។ វន វ៉េត គឺថាត្រូវបានចាប់នៅថ្ងៃទី០២ វិច្ឆិកា ៧៨។ អ៊ីចឹងមានការប្រកាសថា វន វ៉េត នេះគួរតែចុះមកបញ្ជាកងទ័ពតែម្តង។ តើពេលដែលលោកឮហ្នឹង គឺមុនថ្ងៃទី០២ ខែវិច្ឆិកា ៧៨ ឬក៏មុនៗ

01329843



ពេលនេះ ឬក៏អាចថា លោកឮនៅក្នុងខែមេសា ឆ្នាំ<១៩៧៧>?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំសូមបកស្រាយជូនលោក។ សូម្បីតែលោកបកអាខ្ញុំនិយាយហ្នឹង អត់ត្រូវផង ហ្នឹង។ ខ្ញុំនិយាយថ្ងៃ១១ ខែ១០ ១៩៧៨ ដែលយួនយកស្នួលបាន។ បាទ ដល់សេចក្ដីប្រកាសរបស់កងទ័ព ជើង១ ដែលឲ្យរោងចក្រគាត់នេះ ដែលនៅនឹងភ្នំពេញ ដែលប្រកាសឲ្យទៅវាយយួននេះ ៧៨ ក្នុងដែល យួនបុកអំឡុងបុកស្នួលនេះ។ ហើយ អ៊ំវន វ៉េត ក៏គាត់ទៅទស្សនកិច្ចនៅស្នួលហ្នឹង រយៈ២ថ្ងៃ ៣ថ្ងៃនេះ ដែល១មុនចាប់បង១ដែលមួយដណ្ដប់នាក់នេះ។ ដូច្នេះយកពីថ្ងៃហ្នឹងមក គាត់មកដល់ភ្នំពេញ ចាប់១ បានក្នុងមួយដណ្ដប់នាក់នេះក្រោយ។ ដូច្នេះខ្ញុំចង់ឲ្យលោកបកស្រាយអាហ្នឹងឲ្យចំឲ្យខ្ញុំមក បានខ្ញុំ ព្រោះ ខ្ញុំនិយាយ វាអាច ដល់គាត់និយាយទៅ គាត់បកភាសាអង់គ្លេស យកមកបកខ្មែរវិញខុសអាថ្ងៃទីខ្ញុំ។ ដល់ អ៊ីចឹងខ្ញុំច្រឡំបល់ត្រង់ហ្នឹងដែរ ខ្ញុំសូមឲ្យលោកជួយសម្រួលអាហ្នឹង ព្រោះយួនបុកយកស្នួលបានថ្ងៃ១១ ខែ១០ ៧៨ណ៎ា ថ្ងៃទី១១ហ្នឹង មិនមែនខែវិច្ឆិកា ថ្ងៃ១០ ខែវិច្ឆិកាទេ គឺខែតុលាដែល ឆ្នាំ៧៨ដដែល។ ហើយអ៊ំ វន វ៉េត ក៏ចាប់មិនបានប្រកាសពី៧៧ទេ គាត់នេះក្នុងអំឡុងដែលមុនចាប់បង១១១នាក់នេះ គាត់ មកដល់ភ្នំពេញពីរថ្ងៃចាប់។ បានដំណឹងហ្នឹង បានន៎ែព្រោះកាលពីទៅ បង១១១នាក់នេះទទួលគាត់ ទស្សនកិច្ច ទៅទស្សនកិច្ចហ្នឹងដោយបង១១១នាក់ហ្នឹង គឺបានទៅប្រជុំគាត់នៅសាលាតំបន់នេះ កន្លែង បងមឿន នេះ។ អាហ្នឹងខ្ញុំសូមជម្រាបឲ្យលម្អិតឲ្យលោក។ ហើយអាហ្នឹងដល់បកខុសរឿងខ្ញុំបណ្ដោយ ថាខ្ញុំនិយាយអត់ចំទិស អាហ្នឹងដែលខ្ញុំចង់ឲ្យលោកកែសម្រួលអាហ្នឹងឲ្យខ្ញុំបន្តិចទៅ។ សូមអរគុណ។

[១៥:២១:២២]

**ស៖** បាទ លោកសាក្សី ខ្ញុំនឹងសួរឲ្យច្បាស់លាស់បែបនេះ។ ប៉ុន្តែខ្ញុំចង់យល់ឲ្យច្បាស់ ថាតើនៅ ពេលណាដែលលោកស្ដាប់ឮតាមវិទ្យុថា ម្នាក់ៗបានយល់ស្របគ្នាថា វន វ៉េត នេះគួរតែជាអ្នកបញ្ជាកង ទ័ព? តើលោកស្ដាប់ឮពាក្យសម្ដីនេះតាមវិទ្យុនៅពេលណាដែរ?

**ឆ៖** ទេ បញ្ហាស្ដាប់វិទ្យុនេះ ខ្ញុំចង់ថាមិនដឹងថាស្ដាប់វិទ្យុណានេះ ខ្ញុំអត់បានស្ដាប់ថាឲ្យគាត់ជា មេទ័ព ខ្ញុំឆ្ងល់។ បកពី លោកចង់បកពីណាមកឲ្យខ្ញុំឆ្លើយត្រង់ហ្នឹង អ៊ំវន វ៉េត ខ្ញុំចង់ថាបើចង់និយាយ រាងនៅ ពីដើមខ្ញុំនិយាយអ៊ីចេះ ថារាងគាត់ស្អាតណាស់ ខ្ញុំនិយាយណ៎ា ខ្ញុំចង់និយាយរាងគាត់ ពីខ្ញុំនិយាយ ឃើញសាច់គាត់មក១១ក្រចេះហ្នឹងណ៎ា។ អាហ្នឹងខ្ញុំចង់និយាយរាងគាត់ស្អាតណាស់ បើសិនណាជាមេ ទ័ពក៏ស្អាត និយាយរួមរាងនៅនោះ ខ្ញុំចង់និយាយ បើនិយាយអាចអ៊ីចឹងបាន។ អាហ្នឹងអាចបកខុសទៅ ទៀត ព្រោះដល់និយាយទៅ អាហ្នឹងខ្ញុំចង់កែសម្រួលអាហ្នឹងទៀត។ រួចគាត់ទៅតែពីរថ្ងៃទេ មកវិញបាន

01329844



នេះគាត់ហ្នឹង។ ចង់និយាយ ខ្ញុំចង់ថា រឿងខ្ញុំថាឱ្យរឿងខាងស្ដាប់វិទ្យុថាឱ្យៗគាត់នោះជាមេទ័ព ខ្ញុំម៉េចដឹង បើខ្ញុំអត់បាននិយាយ។ តែបើនិយាយក្នុងហ្នឹង គឺនិយាយលេងជា គាត់ទៅសួរខ្ញុំនុ៎ង ថ្ងៃនុ៎ងទៅសម្ភាសនៅផ្ទះ ខ្ញុំមិនបានៗចាប់អារម្មណ៍។ អាហ្នឹងខ្ញុំសួរដំបូងចេះតែអង្គុយព្រោកប្រាជ្ញគ្នា។ អ៊ីចឹងខ្ញុំសូមអរគុណ មានប៉ុណ្ណឹង។

**ស៖** មុននេះគឺលោកបាននិយាយអំពីបង ឧល <សមាជិកគណៈ>មន្ទីរ។ តើលោកដឹងថា ឧល មានជួបប្រជុំជាមួយនឹង វន វ៉េត ដែរឬទេ នៅពេលដែល វន វ៉េត គាត់ចុះទៅក្រចេះ?

[១៥:២៣:២៥]

**ឆ៖** បញ្ហាហ្នឹង បើជួបគាត់បានយល់បញ្ហាច្រើន ព្រោះគាត់ក្នុងមន្ទីរតំបន់ហ្នឹងគាត់អ្នកចាត់ចែងថ្ងៃដែលអ៊ំ វន វ៉េត មកនេះ។ អានេះខ្ញុំចង់ អ៊ីចឹងបានគាត់អាចច្បាស់ជាងខ្ញុំ ព្រោះថ្ងៃហ្នឹងខ្ញុំគ្រាន់តែគាត់អញ្ជើញមកដល់កប៉ាល់ ឡើងកប៉ាល់នៅកន្លែង បងមឿន ទៅខ្ញុំក៏ដឹកសម្ភារៈទៅមុខទៀតទៅ។ ដូច្នេះទៅដល់មានតែគណៈមន្ទីរ ហើយនិងកងពលមួយចំនួនដែលគាត់នៅរៀបចំជួបគាត់។ អាហ្នឹងខ្ញុំចង់ជម្រាបជូនលោកឱ្យច្បាស់ត្រង់ហ្នឹងទេ។ បើបង ឧល គាត់ច្បាស់ជាងខ្ញុំ។ បាទ ខ្ញុំសូមបកបញ្ជូនទៅវិញ ព្រោះបង ឧល បើ បងឧល ដឹងតែច្បាស់ហើយ ព្រោះថាគាត់ទី១ គាត់នៅក្នុងគណៈមន្ទីរហ្នឹង ការរៀបចំរបស់ខាងលើមក គឺគាត់ត្រូវរៀបចំហើយ។ ពិតមែនតែគាត់របួសជើងជិះម៉ូតូមែនតែគាត់នៅធ្វើបាន។ បាទ សូមអរគុណ។

**ស៖** ពីមុននេះ សហព្រះរាជអាជ្ញារងអន្តរជាតិបានសួរលោកអំពីមនុស្សប្រាំមួយ<នាក់ ក្នុងចំណោមមនុស្ស>១១នាក់ដែលត្រូវបានកោះហៅឱ្យមកភ្នំពេញមានឈ្មោះ លាង, ឈ្មោះ <ស្វាយ ណូញ>, ឈ្មោះមឿន, ឈ្មោះ រុំ, ឈុំ ចិន ហៅភ័ន <និងឈ្មោះ យ៉េង>។ តើលោកដឹងថា មនុស្សទាំងប្រាំមួយនាក់ដែលបានមកភ្នំពេញនេះ មានជាប់ទាក់ទងអីជាមួយនឹង វន វ៉េត ដែរឬទេ?

[១៥:២៥:១០]

**ឆ៖** ការស្ដាប់បានរបស់ខ្ញុំ ខ្ញុំសូមជម្រាបចង់បញ្ជាក់លោកឱ្យជ្រាបថាអ៊ីចេះ ចង់ថាបងៗទាំងអស់នេះ ក្នុង១១នាក់នេះ បានចូលរួមប្រជុំជាមួយ អ៊ំវន វ៉េត អានេះខ្ញុំនិយាយឱ្យច្បាស់ ឲ្យលម្អិតទៅចុះ។ ដូច្នេះបើសិនណាជាចង់លម្អិតទៅទៀត ខ្ញុំអត់ដឹងថា មិនដឹងស៊ីជម្រៅយ៉ាងណា ព្រោះគាត់ចូលប្រជុំ ក៏ខ្ញុំអត់នេះ ខ្ញុំនៅក្រៅទេ ខ្ញុំមានបានទៅប្រជុំអីជាមួយគាត់។ ត្រង់ហ្នឹងហើយ ដែលខ្ញុំចង់បញ្ជាក់ថាអាចមានពាក់ព័ន្ធ។ ព្រោះថ្ងៃដែលគាត់ អ៊ំវន វ៉េត ទៅដល់នោះ ក៏អត់មានឃ្លួន អត់មានបានវ៉ៃគ្នាទេ។

ជំនាន់គាត់ទៅដល់ហ្នឹង ក្នុងមួយថ្ងៃពេញហ្នឹង បានទៅទស្សនកិច្ច គាត់ទៅមើលព្រែកទេវ ព្រោះឃ្លួនវានៅក្រោយព្រែកទេវហើយ។ ហើយបើលោកអាចស្គាល់ព្រែកទេវ ចុះព្រែកទេវជម្រៅណា។ រថក្រោះចុះអត់កើតផង។ អាហ្នឹងខ្ញុំចង់បញ្ជាក់ជូនលោកថា ដល់អ៊ីចឹង ពេលដែល វន វើត ត្រឡប់មកភ្នំពេញវិញ ថាចាប់គាត់ទៅ បាន១១នាក់នេះឆ្លងកាត់អត់ចាប់ អ្នកមួយចំនួនដែលអត់បានចូលរួមប្រជុំ អត់បានចាប់ទេ។ សូម្បីតែគណៈស្រុកសំបូរ ក៏អត់បានចាប់ដែរ ព្រោះបងរឿន ហ្នឹងអត់បានមកប្រជុំទេ។ អាហ្នឹងខ្ញុំសូមជម្រាប វាអាចពាក់ព័ន្ធអាហ្នឹង ខ្ញុំចង់ការវិភាគទេ ព្រោះខ្ញុំអត់បានចូលរួមប្រជុំជាមួយគាត់ទេ ខ្ញុំនៅយាមឯក្រៅណោះ ហើយក៏ខ្ញុំដឹកសម្ភារៈចេញទៅឯកន្ទួត ទៅអូរដាទៅ ក៏មកវិញ គាត់ប្រជុំចប់បាត់ហើយ គាត់ប្រជុំប៉ុន្មាន គាត់មកវិញ គាត់ប្រជុំមួយបន្តិច គាត់ទៅឡើងកប៉ាល់មកវិញមក។ អាហ្នឹងខ្ញុំចង់ជម្រាបលោក ជូនលោកប៉ុណ្ណឹង។ បាទ សូមអរគុណ។

[១៥:២៦:៤០]

**ស៖** ដូច្នេះមនុស្សទាំង១១នាក់ដែលមកភ្នំពេញ មុនពួកគាត់ចេញមកភ្នំពេញនេះ គឺថាអ្នកទាំង១១នាក់នេះ មានបានជួបប្រជុំជាមួយនឹង វន វើន ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ បញ្ហានេះដូចខ្ញុំបកស្រាយជូនលោកហើយ បញ្ហាហ្នឹង។ ពាក់ព័ន្ធរឿងហ្នឹង ដែលខ្ញុំដឹង គឺថា១១នាក់ហ្នឹង ដែលបានចូលរួមប្រជុំជាមួយគាត់។ បាទ សូមអរគុណ។

**ស៖** ហើយតើត្រឹមត្រូវដែរឬទេ ដែលថា បងឌល ដែលលោកលើកឈ្មោះគាត់មកនិយាយញឹកញាប់ថ្ងៃនេះ គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សទាំង១១នាក់នេះ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ ត្រង់ថាគាត់គណៈមន្ទីរ។ ចង់និយាយថា គាត់ហ្នឹងគ្រាន់តែការរៀបចំប្រជុំអី គាត់អ្នករៀបចំឲ្យបងៗគាត់អ្នកប្រជុំ គាត់ក្នុងនាមគាត់គណៈមន្ទីរទេ មិនមែនគាត់បានចូលប្រជុំទៀតបើតាមឲ្យដឹង គាត់អត់បានចូលរួមប្រជុំទេ។ គ្រាន់តែការរៀបចំបន្ទប់ ការរៀបចំអី កន្លែងស្នាក់នៅអីអាហ្នឹង ខ្ញុំចង់ជម្រាបឲ្យលោកដឹងអ៊ីចេះ កុំឲ្យដល់ហើយទៅ ថាអ្ហេ្ន! គាត់ចូលប្រជុំដែរ មិនមែនទេ។ តែគាត់បានមកភ្នំពេញជាមួយបងៗ១១នេះដែរ ប៉ុន្តែគាត់ត្រឡប់ទៅវិញ កាលជំនាន់នោះណា។ គាត់មកមួយយប់ហើយ គាត់ត្រឡប់ទៅវិញ។ បាទ សូមអរគុណ។

[១៥:២៨:០៨]

**ស៖** តើលោកដឹងថា មានអ្វីកើតឡើងចំពោះ ឌល ដែរឬទេ នៅពេលដែលគាត់មកភ្នំពេញនោះ?

**ឆ៖** បាទ សូមជម្រាបថា គាត់គ្រាន់បានបញ្ជាក់ប្រាប់ខ្ញុំ និងប្រាប់ម្ដាយមីងខ្ញុំដែលប្រពន្ធពូ ចិន

– ភ័ន នេះ ហៅ ភ័ន នេះណ៎ា។ គាត់ថា ពូខ្ញុំផ្ដាំទេ គ្រាន់តែផ្ដាំថា ឲ្យមើលប្រពន្ធពូខ្ញុំនេះផង។ ដល់អ៊ីចឹង បាន ឌល មករត់ជាមួយខ្ញុំមករហូត រត់៧៩ រត់មកជាមួយគ្នារហូតមក។ ដល់ម្ដាយមីងខ្ញុំហ្នឹង ក៏បែក យួន វ៉ៃនៅម្តុំភ្នំជី កំពង់ធំ ក៏បែក ពី ឌល ខ្ញុំតាម បងឌល មករហូតដល់ដងរែក។ បាទ សូមអរគុណ។

**ស៖** តើលោកដឹងថា ឌល ត្រូវបានគេចាប់ខ្លួនដែរឬទេ នៅពេលដែលគាត់មកភ្នំពេញនៅចុងឆ្នាំ ១៩៧៨?

**ឆ៖** ទេ លោកសួរខ្ញុំអត់ច្បាស់អំមិញ។ អ្នកណាត្រូវចាប់ខ្លួន? បើខ្ញុំនិយាយថា ឌល ទៅវិញ។ បាទៗ សូមបញ្ជាក់ម្តងទៀត។

**ស៖** វាហាក់ដូចជាថា ឌល នេះគាត់ប្រាប់ទៅអ្នកស៊ើបអង្កេតថា គាត់ត្រូវបានគេឃុំឃាំងខ្លួនដោយកងទ័ព កងពល<៥០១*(ស៊ីក)*>នៅព្រលានយន្តហោះពោធិ៍ចិនតុងអស់រយៈពេល៣ថ្ងៃ។ មិននិយាយអំពីពេលដែលគាត់ត្រឡប់ទៅវិញទេ និយាយមុនហ្នឹង ថាតើលោកដឹងថា ឌល ត្រូវបានគេចាប់ខ្លួន និងឃុំឃាំងមួយរយៈពេលខ្លីដែរទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកអាចផ្តល់លេខឯកសារយោងបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម គឺនៅក្នុងឯកសារដែលទើបទទួលយកគឺឯកសារ E3/10639។ ខ្ញុំសូមផ្តល់លេខ សំណួរចម្លើយឲ្យបានច្បាស់លាស់ជូនលោកស្រី។

[១៥:៣០:៣៣]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនជំទាស់ទេ ប៉ុន្តែខ្ញុំគិតថា <លោកយោងទៅកងពល៥០២ មិនមែន៥០១ទេ តើអ៊ីចឹងមែនទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមទោសដែលខ្ញុំនិយាយ។ ឥឡូវនេះខ្ញុំនឹង -- គឺថា<តើ>លោកដឹង<ទេ>ថា <ឌល> ត្រូវបានគេចាប់ខ្លួន ហើយឃុំពីរបីថ្ងៃដោយកងពល៥០៤ តើលោកដឹង -- ៥០២ -- តើលោកដឹងអំពីចំណុចនេះទេ?

**2-TCW-1005៖**

**ឆ៖** បញ្ហាហ្នឹងលម្អិត ខ្ញុំមិនបាន គាត់មិនបានប្រាប់ថាគេឃុំទេ តែគាត់មកភ្នំពេញដដែល។ មកភ្នំពេញដែរហ្នឹង ត្រឡប់ទៅវិញបានគាត់ដឹងថា អ្នក១១នាក់នេះត្រូវចាប់ខ្លួន។ ដូច្នេះបញ្ហាឃុំខ្លួន ខ្ញុំឃើញគាត់ត្រឡប់មកវិញធម្មតា ភ្នំពេញចេញចូលជាធម្មតា អាហ្នឹងខ្ញុំអត់បានសួរនាំព្រោះសភាពការណ៍កាលហ្នឹងវាកៀក វាណាស់ទៅហើយ ព្រោះត្រូវ គាត់មកត្រូវរៀបចំអីវ៉ាន់ឆ្លងមកលិច ត្រូវឆ្លងមកព្រែកប្រសព្វ ហើយខ្ញុំត្រូវទប់នៅឲ្យ ទូកឲ្យអី កាណូតអីឆ្លងដឹកចេញពីព្រែកប្រសព្វ ខ្ញុំវាត្រូវធ្លាក់ទឹក ហែលទឹកមួយព្រឹកដែរ។ ដូច្នេះខ្ញុំចង់និយាយពេលប្រចុចញ៉ុច យួនវ៉ៃហើយនេះ គឺអាបញ្ហាហ្នឹងលែងគិតហើយ ឲ្យតែរស់រៀងខ្លួនសិន អាហ្នឹងខ្ញុំចង់ជម្រាបលោកអ៊ីចេះ ព្រោះដល់រត់មក បងឌល រត់តាមខ្ញុំរហូត។ កម្លាំងខ្ញុំសែងគាត់រហូត ព្រោះខ្ញុំរត់ជាមួយ បងញ៉ាន់ កងពលថ្មីហ្នឹង មាន តាផុន ហ្នឹង បានមកអ៊ំខៀវ ជាប់នៅស្នួង នៅចម្ការកៅស៊ូជប់នេះ បានរត់មកវ៉ៃគាត់នៅ ដើរឆ្លងកាត់មកហ្នឹងទៀត មកវ៉ៃរំដោះយកអ៊ំខៀវ អ៊ំសុន សេន ហៅ ខៀវ នេះ។ បានពួកខ្ញុំមកជាប់ ជួបគ្នារហូតបានទៅដងរែក ឡើងទៅជាមួយគ្នា។ បាទ សូមអរគុណ។

[១៥:៣២:១២]

**សៈ** ឥឡូវនេះគឺខ្ញុំនិយាយពីឯកសារ E3/10639 គឺសំណួរចម្លើយ៣០៤ រហូតទៅដល់៣១១។ ហើយនៅក្នុងភស្តុតាងនេះ គាត់និយាយថា គេចាប់ខ្លួនគាត់ឃុំ៣ថ្ងៃ ហើយគេស្នើសុំឲ្យគាត់ប្រាប់ពីមូលហេតុ<គាត់គ្មានកំហុស>។ លោកសាក្សី <ឌល>គឺស្ថិតនៅក្នុងចំណោមមនុស្ស<១១នាក់>ដែលត្រឡប់ទៅខេត្តក្រចេះវិញ។ ហើយមុននេះលោកបាននិយាយថា <មនុស្សមួយចំនួន ឬអាចមនុស្សម្នាក់> ខ្ញុំមិនប្រាកដថាតើប៉ុន្មាននាក់<ក្នុងចំណោមមនុស្ស១១នាក់នោះ គឺថាត្រូវបានគេ>បញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង<>។ តើលោកពិតជាបាននិយាយថា មានពួកគាត់ក្នុងចំណោម១១នាក់ហ្នឹងត្រូវបានគេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងមែនទេ? <បើលោកបានដឹង តើលោកដឹងដោយតាមរបៀបណា?>

**ឆ៖** បញ្ហាទាំងអស់ដែលខ្ញុំចង់ជម្រាបលោកហើយ ដែលចង់ថាអ៊ីចេះ ចង់ថាក្នុងចំណោម១១នាក់នេះ ខ្ញុំនឹងអាចវិភាគថាមានចូលព្រលានយន្តហោះកំពង់ឆ្នាំងមួយចំនួនហើយ ព្រោះក្នុងហ្នឹងគឺ ចូល ស-២១ រាប់អំមិញប្រាំមួយនាក់។ ដល់អ៊ីចឹង អ្នកក្រៅពីនោះ ខ្ញុំថាប្រហែលជាមានអាច អាហ្នឹងគ្រាន់តែជាការវិភាគទេ ដល់តែ បងឌល គាត់ទៅ គឺគាត់ អាការឃុំខ្លួន៥០២នេះ ព្រោះ៥០២ ហើយនិងពួកខ្ញុំហ្នឹង អត់ត្រូវគ្នាទេ ព្រោះខាងខ្ញុំសុំឲ្យយន្តហោះទៅជួយ មិនងាយទាក់ទងនឹងបាន។ ដល់អ៊ីចឹងវាទំនាស់

គ្នាតាំងពីអារឿងវ៉ៃនេះ អាវ៉ៃគ្នានេះ។ អាហ្នឹងខ្ញុំសូមជម្រាប។ ដល់អ៊ីចឹងចោទប្រកាន់គ្នា។ ដល់ បងឌល គាត់ទៅ ព្រោះ បងឌល គាត់នៅក្រចេះ ដឹងថាពួកក្រចេះហ្នឹងខ្លាំងហើយ ខុសជាមួយ៥០២។ អាហ្នឹង ចង់និយាយ ខ្ញុំនិយាយសុំបកស្រាយរឿងផ្ទៃក្នុងនោះណា។ អាហ្នឹងសូមជម្រាបឲ្យវែងបន្តិចចុះ។ ដល់ អ៊ីចឹងខាង ខ្ញុំហៅបញ្ជូនសារទៅព្រលានយន្តហោះហ្នឹង បីបួនថ្ងៃអី អត់ទាន់សុំជួយបានទេ។ ដល់អ៊ីចឹង អាហ្នឹងរឿងដែលប៉ះទង្គិចគ្នា អាកៀកមែនទែនហើយនេះ។ សូមជម្រាបប៉ុណ្ណឹងបាទ។

[១៥:៣៤:៣០]

**ស៖** អ៊ីចឹងបានន័យថា គេហៅមនុស្ស១១នាក់មក ឌល បានត្រឡប់ទៅវិញ។ តើមនុស្សបួននាក់ ក្នុងចំណោម១១នាក់ហ្នឹង បានទៅព្រលានយន្តហោះកំពង់ឆ្នាំងមែនទេ? ប្រសិនបើអ៊ីចឹងមែន តើលោក ស្គាល់ឈ្មោះពួកគាត់ទាំងបួននាក់ដែលត្រូវទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងទេ?

**ឆ៖** ព្រោះកាលណោះ ខ្ញុំសូមជម្រាបថា ខ្ញុំមិនបានស្គាល់ទេ ព្រោះគាត់នៅវរសេនាធំនៅមុខ មានវរសេនាធំ។ ឥឡូវបើក្នុងនេះ បងមឿន ចូលនេះហើយ, បងខុន ចូលក្នុងនេះហើយ, ពូរុំ ចូលក្នុងនេះ ហើយ, បងយ៉េង ចូលនេះ, បងចិន ចូលនេះហើយ អ៊ំដល់អ៊ីចឹងវានៅត្រង់ណោះ ដឹងថាបងផន មួយ ហើយ។ អ៊ំមកក្រោយវរៈនេះ កងបងៗវរសេនាធំឡើងក្រោយនេះ ក្នុងចំណោមដែលមកបួននាក់នេះ ខ្ញុំ និយាយរួម ខ្ញុំអត់បានមើលប្រវត្តិរូបភ្ជាប់បានទេ ព្រោះចាត់តាំងដែលមេស្លាប់ទៅ ត្រូវឡើងអនុអ៊ីចឹងមក អាហ្នឹង ដល់អ៊ីចឹងខ្ញុំមិនសូវបានចាប់អារម្មណ៍ និយាយត្រង់ អាហ្នឹងជម្រាបលោក ថាខ្ញុំអត់បានស្គាល់ អត់បានច្បាស់លាស់បញ្ហាហ្នឹងបាទ។

**ស៖** តើលោកដឹងទេថា មនុស្សបួននាក់នេះត្រូវបានគេបញ្ជាឲ្យធ្វើអ្វីដែរនៅព្រលានយន្តហោះ កំពង់ឆ្នាំង?

[១៥:៣៦:០៧]

**ឆ៖** ដល់លោកសួរខ្ញុំចុងកន្ទុយអ៊ីចឹង ឲ្យខ្ញុំឆ្លើយយ៉ាងណាទេ។ ដល់សភាពការណ៍យួនបុកទៅ ហើយ ហើយបានបញ្ជូនមនុស្សទៅហើយៗ មានធ្វើអីទាន់។ អាហ្នឹងតាមខ្ញុំគិត ធ្វើអីវាមិនទាន់ទេ។ ព្រោះខាងខ្ញុំនេះក៏កុន ខាងនុ៎ងក៏កុនដែរ ខាងភ្នំពេញហ្នឹង ខាងកំពង់ឆ្នាំងហ្នឹង។ អាហ្នឹងខ្ញុំចង់ជម្រាប លោកឲ្យត្រង់ទៅចុះ។ ឥឡូវទៅធ្វើអីទាន់ ប៉ុន្តែដល់បាត់ខ្លួនទាល់ឥឡូវនេះ អាហ្នឹងមិនដឹងធ្វើម៉េច។ គ្រាន់ តែកន្លែងព្រលានកំពង់ឆ្នាំង គឺកន្លែងដែលលត់ដំ កន្លែងណាដកពីកម្មាភិបាលថ្នាក់ណាទៅ ដែលថាឲ្យធូរ ស្រាលនៅត្រង់នុ៎ង អាហ្នឹងយកទៅកំពង់ឆ្នាំង អាហ្នឹងខ្ញុំដឹង ព្រលានកំពង់ឆ្នាំង។ ទៅវ៉ៃថ្ម ទៅអី អាហ្នឹង

ខ្ញុំដឹង ដឹងថាកម្មាភិបាលដែលៗដកចេញពីភារកិច្ច គឺយកទៅន៉ុង។ ហ្នឹងដឹងតែទោស ដូចថាអាហ្នឹងនៅរស់ហើយ បាននៅរស់។ សូមអរគុណ។

**សៈ** ខ្ញុំនិយាយអំពីប្រាំមួយនាក់ មនុស្សប្រាំមួយនាក់។ តើត្រឹមត្រូវទេនៅពេលនោះ ដែលថាលោកមិនដឹងទេថា នៅពេលហ្នឹងលោកមិនដឹងថា ពួកគាត់ទាំងប្រាំមួយនាក់ត្រូវបានគេបញ្ជូនទៅស-២១ទេ មែនទេ? ខ្ញុំចង់និយាយថានៅ<ខែធ្នូ>ឆ្នាំ<៧៨>ហ្នឹង លោកអត់ដឹងថាគេបញ្ជូនពួកគាត់ប្រាំមួយនាក់ហ្នឹងទៅ ស-២១ ទេ?

[១៥:៣៧:៤២]

**ឆៈ** លោកសួរខ្ញុំគាត់៧៧មក ហើយបើគាត់ទៅ៧៨ លោកសួរខ្ញុំអ៊ីចឹង ដល់អ៊ីចឹងខ្ញុំឆ្លើយម៉េចវិញ។ ខ្ញុំចង់និយាយ គ្រាន់តែអ្នកសួរខ្ញុំពីម្សិល គ្រាន់ថាចង់ដឹងមុនក្រោយហ្នឹង ខ្ញុំវាអាហ្នឹងក៏មិនបានចាំទេ តែដល់ព្រឹកមិញ ខ្ញុំមើលឃើញឯកសារហ្នឹង ក្នុងចំណោម ក្នុងប្រាំមួយនាក់ហ្នឹងត្រឹមត្រូវ ដែលចូល ស-២១ ព្រោះតែមុនក្រោយគ្នាហ្នឹង ប៉ុន្តែវាទៅដំណើរគ្នា ដូចបងឌល អ៊ីចឹង ដូចបងឌល ទៅអ៊ីចឹង ៥០២ ឃុំ៣ថ្ងៃ ដល់មកវិញ គាត់មាននិយាយអី គាត់គ្រាន់ថា អ្នកឲ្យមើលប្រពន្ធកូនពូចិន អ៊ីចឹង ឃុំ ចិន នេះ។ ដល់អ៊ីចឹងខ្ញុំអីរត់តាមគាត់អ៊ីចឹងមក ជាមួយកងពលថ្មីរៀបរយមកទាំងអស់ មកចេះតែសាមគ្គីគ្នាមក រត់បានមកដល់ដងរែក, ១០០៣, ១០០១ហ្នឹងមក នៅជុំគ្នាទាល់ឥឡូវហ្នឹងមក។ ខ្ញុំក៏បែកបាក់មកនេះហ្នឹង ដោយសារខ្ញុំមករកម្ដាយខ្ញុំអីអ៊ីចឹងមក។ អាហ្នឹងនិយាយៗដែលៗឲ្យឃើញទៅចុះ។ អាការចាំ ចងចាំវាមិនបានចាំអស់ទេ។

**សៈ** ខ្ញុំយល់ថាវាច្របូកច្របល់មែន លោកសាក្សី។ ប៉ុន្តែខ្ញុំព្យាយាមញែកឲ្យដាច់អំពីអ្វីដែលលោកបានដឹងនៅពេលនោះ គឺនៅ<ខែធ្នូ> ៧៨ហ្នឹង ហើយនិងអ្វីដែលលោកដឹងនៅពេលក្រោយមកវិញ។ តើត្រឹមត្រូវទេនៅក្នុងខែ<ធ្នូ> ៧៨ គឺលោកមិនបានដឹងថា មនុស្សទាំងប្រាំមួយនាក់ហ្នឹង ត្រូវបានគេចាប់ខ្លួន ហើយយកទៅឃុំនៅស-២១ទេ អ៊ីចឹងមែនទេ?

[១៥:៣៩:១៨]

**ឆៈ** បាទ ខាងខ្ញុំអត់បានដឹងទេបាទ។ អត់ដឹងថាគាត់បាត់ខ្លួនទៅដាក់ស-២១ ឬគាត់យកទៅព្រលានកំពង់ឆ្នាំង ក៏ខ្ញុំអត់បានដឹងដែរ។ ទើបខ្ញុំនឹងឃើញ ដឹងថាចូលស-២១។ អានេះខ្ញុំ តែមិនមែនខែកញ្ញា ទេណា។ ចង់និយាយក្នុងខែវិច្ឆិកាអីទេ ខែវិច្ឆិកា ឬខែធ្នូនេះទេ ៧៨។ ដូច្នេះបើលោកនិយាយពីខែកញ្ញា ដល់អ៊ីចឹងខ្ញុំមិនដឹងរកនិយាយទៅបកថាម៉េចទេអាហ្នឹង។ សូមអរគុណ។

**សៈ** ឥឡូវនេះខ្ញុំសួរអ៊ីចេះវិញ តើលោកមិនបានដឹងអំពីការចាប់ខ្លួនមនុស្សប្រាំមួយនាក់ គឺថាលោកមិនបានឃើញការសួរចម្លើយមនុស្សទាំងប្រាំមួយនាក់ នៅពេលដែលលោកបានៗន័យថា នៅពេលដែលលោកជូនពួកគាត់ឡើងយន្តហោះហ្នឹង គឺជាពេលចុងក្រោយដែលលោកបានឃើញពួកគាត់។ គឺថានៅសម័យនុ៎ង នៅពេលនុ៎ង គឺលោកអត់ដឹងទេ ថាមានអីកើតឡើងចំពោះគាត់ អ៊ីចឹងមែនទេ?

**ឆៈ** បាទៗ សូមអរគុណបាទ។ ខ្ញុំម៉េចដឹងបើគាត់មកផុតហើយ។ ដូច្នេះខ្ញុំអត់ដឹងទេ គាត់មកផុតហើយ នឹកឃើញបានគាត់មកធ្វើការ មកប្រជុំអ៊ីចឹង អាហ្នឹងខ្ញុំអរណាស់។ អត់បាន អត់ដឹងទេបាទ។ អរគុណ។

**សៈ** ព្រឹកនេះលោកបានប្រាប់ថា នៅពេលដែលលោកឃើញគេស្នើសុំមនុស្សទាំង១១នាក់ហ្នឹង គឺលោកសប្បាយចិត្ត ព្រោះថាលោកអាចមានពេលទំនេរ។ តើត្រឹមត្រូវទេ ដែលថានៅពេលដែលលោកឃើញថា គេស្នើសុំមនុស្សទាំង១១នាក់ហ្នឹង លោកសប្បាយចិត្ត?

[១៥:៤១:១៧]

**ឆៈ** បាទៗ ខ្ញុំអរគុណណាស់បាទ។ ព្រោះថាសប្បាយចិត្ត អ៊ីចេះបានមេចេញផុតចេញទៅនុ៎ង បានខ្ញុំនេះបានដើរលេងដូចថាទៅមណ្ឌលគិរីអ៊ីចឹង បានទៅ បានសាច់ បានម្ហូបអីយកមកធ្វើទំពហូបដែរ ព្រោះត្រង់ណោះសម្បូរឈ្លូស សម្បូរខ្ទីងអ៊ីចឹងណ៎ា អាហ្នឹងខ្ញុំចង់និយាយអ៊ីចេះ។ ខាងខ្ញុំដល់គាត់ចេញផុតទៅ ខ្ញុំទៅតើ ខ្ញុំទៅមណ្ឌលគិរីពីរយប់ដែរហ្នឹង។ បាទ អាហ្នឹងត្រឹមត្រូវ។ បាទ អរគុណ។

**សៈ** តើលោកអាចនិយាយថា ប្រសិនបើសមាជិករដ្ឋបាលក្រចេះ ឧទាហរណ៍ថាជាប្រធានតំបន់ ឬក៏ស្អីមួយអ៊ីចឹង ប្រសិនបើពួកគាត់ត្រូវបានគេកោះហៅមកភ្នំពេញ ខ្ញុំចង់ថាតើសមាជិករបស់តំបន់ ឬក៏ស្រុកហ្នឹងត្រូវបានគេកោះហៅមកភ្នំពេញញឹកញាប់ទេ? ឧទាហរណ៍ដូចជា <ឈុំ> ចិន ហៅ <ភ័ន> ហ្នឹង តើគាត់ឧស្សាហ៍មកភ្នំពេញដែរទេ? តើគាត់ធ្លាប់ទទួលលិខិតបញ្ជាឲ្យទៅភ្នំពេញញឹកញាប់ទេ?

**ឆៈ** បាទកាលជំនាន់នោះ ខ្ញុំសូមជម្រាបដោយត្រង់ថា អត់ដែលមានទេ អត់ដែលមានទេ ព្រោះកាលសភាពការណ៍កាលណោះវាដូចថា នៅសភាពការណ៍យួនធូរស្រាល។ អាហ្នឹងដែលមានសំបុត្រស្នាម ហើយគាត់ត្រូវមកអីអត់ទេ បើគាត់មកលេងស្រុកមកអីហ្នឹង គាត់មកជាធម្មតាទេអាហ្នឹង។ ការប្រជុំ ការអី រៀនសូត្រថ្នាក់លើហ្នឹង ក៏គាត់មិនសូវដែលមកដែរ ព្រោះការទំនាក់ទំនងអី គឺដូចថាមិនងាយនឹងបានមកៗដូចក្បៀកៗអាហ្នឹងអី។ ដល់អ៊ីចឹងការសំបុត្រស្នាមអីនេះ ខ្ញុំចង់និយាយថា ខ្ញុំបានទទួល

តែមួយនេះឯង ដឹងតែមួយនេះឯង មុនៗមកដូចមិនដែលមានទេ។ ទាំង បងមឿន ក៏ដោយ, ទាំង ពូរុំ ហ្នឹងក៏ដោយ។ និយាយរួមខ្ញុំត្រង់ហ្នឹង កាលដែលខ្ញុំនៅជិតហ្នឹង ខ្ញុំដឹង។ ដូច្នេះអាហ្នឹងខ្ញុំអត់ដែល អ្វីដែលខ្ញុំអត់ដឹង គឺខ្ញុំដឹងតែប៉ុណ្ណឹង ខ្ញុំប្រាប់តែប៉ុណ្ណឹង។ បាទ សូមអរគុណ។

[១៥:៤៣:៣៣]

**ស៖** ឥឡូវៗខ្ញុំសួរអ៊ីចេះវិញ តើលោកមានដឹងទេថា សមាជិកកងពល១១៧ ឬក៏<តំបន់>៥០៥ ហ្នឹង តើគេ តើមានសមាជិកណាមួយដែលឧស្សាហ៍ទៅទីក្រុងភ្នំពេញញឹកញាប់ទេ? ខ្ញុំមិននិយាយថាត្រឡប់ទៅផ្ទះទេ ប៉ុន្តែនិយាយថាទៅភ្នំពេញ។

**ឆ៖** ដល់លោកសួរខ្ញុំ ដល់លោកសួរខ្ញុំអ៊ីចឹង ខ្ញុំចង់និយាយថា ការទៅភ្នំពេញញឹកញាប់ ព្រោះខ្ញុំទៅពីក្រចេះទៅ គឺឆ្លងកាត់ភ្នំពេញទាំងអស់។ សូម្បីខ្ញុំមកលេងស្រុកក៏ឆ្លងកាត់ភ្នំពេញ សូម្បីខ្ញុំដឹកសម្ភារៈក៏មកភ្នំពេញ ព្រោះសម្ភារៈខ្ញុំ ពីដើមហៅឃ្លាំងរដ្ឋ ខ្ញុំចង់និយាយថា យកពីឃ្លាំងរដ្ឋទៅៗនៅកន្លែងភ្នំពេញរាល់ថ្ងៃ អាផ្ទះ១១៣ ផ្សារចាស់ហ្នឹង អាហ្នឹងកន្លែងខ្ញុំផ្ទះស្នាក់ ខ្ញុំសម្រាប់ពីមុនដែលកងពលមណ្ឌលគិរី រតនគិរី ក្រចេះនៅហ្នឹងជាប់គ្នា។ ដល់អ៊ីចឹងលោកសួរខ្ញុំអ៊ីចឹង មកឆ្លងកាត់ភ្នំពេញទាំងអស់ សូម្បីតែអ្នកពីជនជាតិមកពីមណ្ឌលគិរីក៏មកនៅភ្នំពេញ។ ដូច្នេះការមក ជួនកាលដឹករបួសមកស្រាលៗដឹកមកអ៊ីចឹងក៏មកតាមអ៊ីចឹងមក ហើយការទំនាក់ទំនងគាត់មកប្រជុំអី អាច៧៨ហ្នឹងគាត់ទៅប្រជុំ បានទៅប្រជុំជាមួយខាងលើម្តងនៅស្តាតអ៊ីចឹងមក រឿងរបស់ខាងលើ ខ្ញុំរួចខ្លួន ខ្ញុំបានមេប្រជុំ ណោះទៅលេងស្រុកអ៊ីចឹង។ អាហ្នឹងខ្ញុំសូមបញ្ជាក់បន្ថែមឲ្យដឹងបន្តិចចុះ ព្រោះដល់លោកសួរអ៊ីចឹងមក បានខ្ញុំបកទៅវិញទៅអាហ្នឹង ដែលកន្លែងខ្ញុំដឹងមានជម្រាបបានប៉ុណ្ណឹង បាទ។ សូមអរគុណ។

**ស៖** ឥឡូវនេះខ្ញុំសួរអ៊ីចេះវិញ តើមេដឹកនាំតំបន់៥០៥ ឬក៏មេស្រុកស្នួល ឬក៏មេកងពលហ្នឹង តើពួកគាត់ទៅភ្នំពេញហ្នឹង <ទៅជារៀងរាល់>ខែ <ឬ> ទៅ<ញឹកញាប់ប៉ុនណា>ដែរ?

[១៥:៤៥:៣៦]

**ឆ៖** ដល់លោកសួរអ៊ីចឹង ខ្ញុំឆ្លើយអត់កើតទេ។ កិច្ចការទាំងអស់ ខ្ញុំដឹងតែក្នុងអង្គភាពកងពលទេ។ តំបន់ ហើយនិងស្រុក គឺនៅក្រោមការគ្រប់ -- ស្រុកនៅក្រោមការគ្រប់គ្រង់របស់តំបន់ទេ។ ក៏ប៉ុន្តែបើតាមខ្ញុំដឹង ក្តាប់បានគឺ មិនងាយនឹងបានមកភ្នំពេញទេ ចង់និយាយអ៊ីចេះ។ បើមកក្នុងលក្ខណៈថាមួយឆ្នាំអី ដឹងមកបានមិនបាន។ អាហ្នឹងខ្ញុំចង់និយាយការប្រជុំអី ព្រោះវិទ្យុទាក់ទងមានហើយ សារទូលេខមាន។ ដូច្នេះវាដល់សួរខ្ញុំអ៊ីចឹង ខ្ញុំឆ្លើយតាមតែខ្ញុំដឹង បាទ។ ហ្នឹងសូមអរគុណ។

**ស៖** ខ្ញុំសួរបន្តអំពីបញ្ហាដែលលោកថាសប្បាយចិត្ត ដែលមនុស្ស១១នាក់ហ្នឹងបានទៅភ្នំពេញ ដោយសារលោកមានពេលទំនេរវិញ។ តើចង់មានន័យថា លោកមិនគិតថា ពួកគាត់ហ្នឹងត្រូវបានគេចាប់ខ្លួននៅភ្នំពេញទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ការពិតគឺខ្ញុំចង់ថា បានបងៗគាត់ទៅភ្នំពេញទៅ ការរើតប់គ្នានៅមុខក៏មិនសូវ មិនទាន់មានផែនការដែរ។ ដល់អ៊ីចឹង ខ្ញុំចង់ថា ខ្ញុំហ្នឹងចង់បានទៅលេងមណ្ឌលគិរីនោះ ទៅលេងនុំង ដើម្បីថាទៅរកម្ហូបម្ហា សាច់ សាច់ព្រៃអីអ៊ីចឹងយកមកហូបមក។ អាហ្នឹងបានខ្ញុំជម្រាបត្រង់។ តែដោយឡែកគឺខ្ញុំទៅមែន ទៅយកឡានហ្ស៊ីបទៅពីរគ្រឿង ឡានហ្ស៊ីបតុងហ្វុងហ្នឹងបីគ្រឿងទៅ ទាំងអស់ខ្ញុំទៅប្រាំគ្រឿងហ្នឹង បានម្ហូបបានម្ហាមកមែន។ ដល់មកដល់វិញ បានមានឧប្បត្តិហេតុអ៊ីចឹងទៅ។ អាហ្នឹងខ្ញុំដឹងប៉ុណ្ណឹង។ បាទ សូមអរគុណ។

[១៥:៤៧:២៧]

**ស៖** មុននេះខ្ញុំបានសួរលោកអំពីការរឹតបន្តឹង ការប្រើប្រាស់វិទ្យុទាក់ទងនៅក្នុង<ខែមេសា> ឆ្នាំ៧៧<>។ ប៉ុន្តែខ្ញុំចង់សួរថា តើមានការរឹតបន្តឹងលើការប្រើប្រាស់វិទ្យុទាក់ទងរបស់លោកទេ ក្រោយពេលមនុស្ស១១នាក់<បានចេញទៅភ្នំពេញ>នោះ?

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថា ការវាយតម្លៃហ្នឹង ដូចជាមិនត្រឹមត្រូវទេ ព្រោះថាយើងបានសួរអំពីការប្រើប្រាស់វិទ្យុទាក់ទង ហើយនិងការរឹតបន្តឹងក្រោយ<ខែមេសា> ឆ្នាំ៧៧។ ហើយគាត់ឆ្លើយថា វាជាទម្លាប់ទៅ ហើយដែលថា វិទ្យុទាក់ទងក៏ដូចជាការផ្ញើទូរសារនានា មាន<ការផ្លាស់ប្តូរតាមពេលវេលា>ជា<ធម្មតា។ ដូច្នេះ គាត់មិនបាននិយាយថា មានការរឹតបន្តឹងនោះទេ> គឺគាត់និយាយអំពីប្រព័ន្ធជាទូទៅក្នុងការដំណើរការ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ ដោយកែសំណួររបស់ខ្ញុំ។ ខ្ញុំមិននិយាយអំពី<ឆ្នាំ>៧៧ទេ ខ្ញុំសួរលោកសាក្សីថា តើមានការរឹតបន្តឹងក្នុងការប្រើប្រាស់វិទ្យុទាក់ទង ក្រោយពេលដែលមនុស្សទាំង១១នាក់ហ្នឹងបានចាកចេញមកភ្នំពេញទេ?

[១៥:៤៨:៤៤]

**2-TCW-1005៖**

**ឆ៖** ខ្ញុំសូមជម្រាបដោយត្រង់ថា វិទ្យុទាក់ទងពេលដែលគាត់មកហើយ គឺសភាពការណ៍ពេលនោះ គឺច្របូកច្របល់ហើយ។ នេះខ្ញុំសូមជម្រាបថា មិនបានអ្នកណាទៅបញ្ជាអ្នកណាបានទេ ព្រោះពេលនោះ ពេលគាត់មកផុតហើយនេះ ផ្តាក់ទឹកទន្លេបាត់ហើយ។ អានេះខ្ញុំចង់និយាយយួនវ៉ៃផ្តាក់ទឹកទន្លេហើយ។ ដល់អ៊ីចឹងទៅ មិនអាចបញ្ជាអីបានទៀតទេ សូម្បីតែអ្នកមកភ្នំពេញហើយផុត ក៏អត់មានផ្លូវទៅវិញបាន ខ្ញុំអី សូម្បីតែខ្ញុំមកដល់ព្រែកប្រសព្វហើយ ក៏មិនឆ្លងទៅកើតវិញបាន។ ដល់អ៊ីចឹងវិទ្យុទាក់ទងពេលហ្នឹងត្រូវឈប់អាហ្នឹង បើខ្ញុំនិយាយវិទ្យុទាក់ទងរឹតបន្តឹងដែលទៅ១១នាក់ហើយហ្នឹង។ ត្រូវទូលេខខ្ញុំទាំងកប៉ាល់ នៅក្នុងឃ្លាំងទាំងប៉ុន្មាន ខ្ទង់ប្រហែលជា៥០០គ្រឿងនៅក្នុងឃ្លាំងក្រគរខាងជើងក្រចេះ ក៏ខ្ញុំត្រូវចាក់សាំងដុតចោលដែរ។ គ្រាប់ផ្ទុះ៣ថ្ងៃ អត់ឈប់ទេ ហ្នឹងក៏ត្រូវដុតចោល។ បានកាំភ្លើងមកដាក់នៅកប៉ាល់នៅខាងលិចទន្លេនេះ គ្រាប់មួយកប៉ាល់ ហើយនិងកាំភ្លើងហ្នឹងមួយកប៉ាល់ហ្នឹង គឺយកមក យកមិនរួចទៀត។ អាហ្នឹងខ្ញុំសូមជម្រាបថា អាហ្នឹងពេលដែលមកហើយផុតហើយ។ គ្រាន់តែចេញផុត រំលងប្រហែលជាប្រាំប្រាំមួយថ្ងៃ ឬដប់ថ្ងៃហ្នឹង គឺយួនបុកដល់បាត់ហើយហ្នឹង។ ដូច្នេះអាវិទ្យុទាក់ទងមិនអាចរឹតបន្តឹងបានទៀតទេ។ នៅតែប្រព័ន្ធចាស់ អាចទាក់ទងមកលើបានពេលដែលរត់ចេញមកព្រែកប្រសព្វ មកភ្នំជីហើយមក ឡើងមកពញាដងក្ការអ៊ីចឹងមក មកដងរែក។ ដល់ឆ្នាំ៨០, ៨១ បានឡើងមកដល់ដងរែកនៅភ្នំជីហ្នឹង មួយឆ្នាំពីរឆ្នាំទៀតបាទ។ សូមអរគុណ។

[១៥:៥០:១៨]

**ស៖** ឥឡូវនេះ ខ្ញុំប្តូរទៅប្រធានបទថ្មីមួយទៀតលោកសាក្សី។ តើលោកដឹងថាមានអ្វីកើតឡើងចំពោះជនជាតិចាមនៅខេត្តក្រចេះទេ? តើលោកដឹងថាមានហេតុការណ៍អ្វីកើតឡើងចំពោះប្រជាជនចាមនៅខេត្តក្រចេះដែរឬទេ?

**ឆ៖** បញ្ហាហ្នឹងខ្ញុំក្តាប់អត់បាន។ ចង់និយាយថាខ្ញុំអត់ដឹង។ បើនិយាយមួយម៉ាត់ទៅ ខាងមូលដ្ឋានខ្ញុំ សួរខ្ញុំ ខ្ញុំអត់បានដឹងទេ។ បើសួរខ្ញុំបញ្ហាប៉ះពាល់ចាម ប៉ះពាល់អីអ៊ីចឹង ខ្ញុំអត់ដឹងទេអាហ្នឹង។ បាទអរគុណ។

**ស៖** តើលោកដឹងទេថា មានចាម ឬក៏មានអ្នកកាន់សាសនាអ៊ីស្លាមនៅក្នុងកងពល១១៧ទេ?

**ឆ៖** ខាងខ្ញុំកាលហ្នឹងដូចជាអត់មានបានគិតបញ្ហាហ្នឹងទេ។ គិតថាឲ្យមានតែកម្លាំងទប់ទល់យួនហើយដល់លោកសួរមកថារឿងគិតថាសាសនានេះ សាសនានោះអ៊ីចឹង ខ្ញុំនិយាយរួមឲ្យតែមូលដ្ឋានគេប្រមូលឲ្យ ដូចថាស្អីអ៊ីចឹងទៅ បានទ័ពមកឈ្លបអីគេបញ្ជូលមកអ៊ីចឹង អរណាស់អាហ្នឹង។ ចង់និយាយ

បើខ្ញុំនិយាយឲ្យវែងទៅទៀត អ៊ីចឹងដល់លោកសួរអាបញ្ហា អាហ្នឹងខ្ញុំអត់យល់ទេ ព្រោះខ្ញុំអត់បានក្ដាប់ប្រវត្តិរូបមើលទៅដូចដាក់ខ្មែរទាំងអស់។ បើអ្នកកំពង់ឆ្នាំងដូចមិនសួរមានចាមទេ ទៅកំពង់ឆ្នាំងទៅ ទៅពីតាកែវ កំពតអីទៅ ដូចមិនសួរមានចាមទេ អាហ្នឹងខ្ញុំចង់និយាយអ៊ីចេះ។ សូមអរគុណបាទ។

[១៥:៥២:២៤]

**ស៖** តើលោកមានដឹងអំពីការប៉ះទង្គិចរវាងកងពលលោក ជាមួយកងកម្លាំង ឬក៏ពួកបះបោរខ្មែរទេ? គឺខ្ញុំមិននិយាយអំពីវៀតណាមទេ និយាយអំពីការប៉ះទង្គិចរវាងកងកម្លាំង<មជ្ឈិម>ជាមួយនឹងអ្នកបះបោរខ្មែរ?

**ឆ៖** បញ្ហានុ៎ងអាចមានខ្លះដែរលោក មិនអត់ទេ។ អាហ្នឹងចង់ជម្រាបតាមដោយដឹង គឺថាអ៊ីចេះធម្មតា ឧទាហរណ៍ឥឡូវឡានខ្ញុំដឹកគ្រាប់ទៅ ដឹកគ្រាន់ទៅយកដុំឈើទៅដាក់កណ្ដាលផ្លូវ។ ដល់អ៊ីចឹងបាញ់ហើយ ត្រូវបាញ់ហើយ ត្រូវឈប់ឡានបាញ់សិនហើយ។ ដល់គ្រោះថ្នាក់ ដឹងត្រូវមិនត្រូវអាហ្នឹងមិនដឹង មិនមែនឡានខ្ញុំ ក្នុងឡានកងខ្ញុំហ្នឹង។ អាហ្នឹងខ្ញុំចង់ជម្រាបអ៊ីចឹង អាហ្នឹងអាចមានប៉ះទង្គិចខ្លះគ្នាឯង មិនអត់ទេ មិនដឹងកងណាៗ។ អាហ្នឹងដល់ច្របូកច្របល់ពិបាក ១ថាដែរ ធ្វើម៉េចឲ្យគ្រាប់ដឹកមុខដល់មុខបាទ។ សូមអរគុណ។

**ស៖** តើការប៉ះទង្គិច<ជាមួយ>កងកម្លាំង<បះបោរ មានទ្រង់ទ្រាយធំដូចការប៉ះទង្គិចជាមួយកងកម្លាំងវៀតណាមទេ? តើវាខុសគ្នាយ៉ាងម៉េច?>

**លោក វីល្លៀម ស្មីត៖**

ខ្ញុំគិតថាមេធាវីគាត់កំពុងតែធ្វើឲ្យសាក្សីយល់ច្រឡំហើយ គឺថាគាត់និយាយអំពីការប៉ះទង្គិច ប៉ុន្តែសាក្សី<មិនបាន>និយាយពីការប៉ះទង្គិច<ប្រដាប់អាវុធទេ។> គាត់និយាយអំពីការដាក់ឈើរាំងផ្លូវជាដើម <ដូច្នេះប្រហែលជាសំណួរនេះកំណត់ភស្តុតាងច្បាស់លាស់ហើយ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរឡើងវិញ មិនបញ្ហានោះទេ។ លោកសាក្សី ថាតើមានការប៉ះទង្គិចប្រដាប់អាវុធជាមួយនឹងអ្នកបះបោរនៅក្នុងខេត្តក្រចេះដែរឬទេ? គឺចង់និយាយអំពីការប៉ះទង្គិចអាវុធ ប្រដាប់អាវុធរវាងកងពលលោក ជាមួយនឹងអ្នកបះបោរនៅក្នុងខេត្តក្រចេះទេ?

[១៥:៥៤:៣៧]

**2-TCW-1005៖**

**ឆ៖** សូមជម្រាបលោកតាមត្រង់ថាអ៊ីចេះ ខាងខ្ញុំអត់មានដែលប៉ះទេ។ បើខាងមូលដ្ឋានអាចប៉ះដឹង មូលដ្ឋានចង់និយាយថា មូលដ្ឋានវានៅខាងឈ្លបភូមិស្រុកអីគេ ឃុំអ៊ីចឹង គេនៅយាមកន្លែងតាមផ្លូវជាតិនេះ។ ហើយដល់ខ្ញុំ កាលហ្នឹងដល់អ៊ីចឹងដូចឡានឈប់អ៊ីចឹងទៅ គេប្រាប់រាយការណ៍ថាអំមិញខ្ញុំឱ្យមើលសម្រាប់ខ្លាចប៉ះគេយកដុំដុលអីមកដាក់ អាឡានជញ្ជូនគ្រាប់ទៅមុខ។ ចង់និយាយអាហ្នឹង វាប៉ះមិនមានប៉ះប្រដាប់អាវុធទេ គឺប៉ះយកដុំឈើ ដុំអីទៅដាក់វាំងផ្លូវពីស្វាយជ្រះហ្នឹង គឺភ្នំប្រាំពណ៌ហ្នឹងមានៗពួកបះបោរនៅត្រង់នុំងមួយកង។ ហ្នឹងខ្ញុំនិយាយ។ នៅម្តុំដំរីផុង ម្តុំអីនុំងមានទៀត។ ដល់អ៊ីចឹងពួកបះបោរហ្នឹងឯងដែលៗត្រូវមកៗចាំស្ទាក់ឡានពួកខ្ញុំចេញពីស្ពានទេរ។ ដល់អ៊ីចឹងខាងស្រុកក្រចេះហ្នឹង គឺត្រូវការពារស្ពានព្រែកទេរហ្នឹងឱ្យបាន ដើម្បីឆ្លងដឹកគ្រាប់យកទៅៗទុកឆ្លូង។ ហ្នឹងខ្ញុំនិយាយឱ្យជម្រាបត្រង់ប៉ុណ្ណឹងហើយបាទ ដែលខ្ញុំដឹង គឺមានប៉ុណ្ណឹងឯង បាទ។ សូមអរគុណ។

**ស៖** ខ្ញុំថាប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំ។ គឺថាលោកបាននិយាយថា លោករៀបការជាមួយ ប្រាក់ យុត។ ខ្ញុំចាំថា លោកនិយាយថាឆ្នាំ៨៣ ប៉ុន្តែលោកធ្លាប់និយាយជាមួយគាត់អំពីតួនាទីរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ ឬមួយក៏ថាលោកមិនដែលជជែកជាមួយ ប្រាក់ យុត អំពីតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ?

[១៥:៥៦:២៣]

**ឆ៖** អាឡូ! សូមជម្រាបលោកពីបញ្ហាផ្ទាល់ខ្លួនម្តងអ៊ីចឹង លោកអ៊ីចឹង។ បញ្ហាខ្ញុំដឹងប្រវត្តិគាត់ដែរតើ ព្រោះស្រុកភូមិវានៅជិតគ្នាដែរទេ។ នៅគ្រាន់តែគាត់ទៅ និយាយរួម គាត់ចូលតស៊ូយូរហើយ តែដោយឡែក ដល់តែមកជួបខ្ញុំ ព្រោះខ្ញុំមកពីជើងនោះ ខ្ញុំមកពី១០០៣, ១០០១នោះ ខ្ញុំមកសុំអង្គភាព មករកម្តាយខ្ញុំនៅនុំង នៅជិតគាត់ហ្នឹង តែម្តាយខ្ញុំស្លាប់នៅខាងក្រោយផ្ទះ គេហៅថា បាវាំងធ្លាក់រាល់ថ្ងៃនេះម្តាយខ្ញុំស្លាប់នៅត្រង់នុំង៧៩។ ក៏មកហ្នឹង គាត់ឱ្យខ្ញុំនៅជាមួយគាត់ទៅថា អូ្ន! គ្រូ វ៉េត ឯងមិនបាត់ទៅវិញទេណា នៅនេះហើយ។ ដល់នៅទៅ ប៉ែត ខ្ញុំការ៨២ មិនមែនការ៨៣ទេ ខ្ញុំការ៨២។ គាត់ក៏ដឹងប្រវត្តិខ្ញុំ ខ្ញុំក៏ដឹងប្រវត្តិខ្ញុំ ខ្ញុំក៏ដឹងប្រវត្តិគាត់ដែរ ព្រោះវាស្រុកភូមិជិតគ្នាដែរ ជំនាន់នោះ។ បាទ មានប៉ុណ្ណឹងហើយ។ បាទ សូមអរគុណ។

**ស៖** តើគាត់ធ្លាប់ប្រាប់លោកអំពីអ្វីដែលគាត់បានធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** បញ្ហានេះ គាត់មិនមានបាននិយាយអីឱ្យក្បោះក្បាយទេ ព្រោះគាត់ ព្រោះការឃើញ ការដឹងនោះ ខ្ញុំវាដឹងស្រាប់ទៅហើយ។ ដល់លោកសួរមកខ្ញុំអ៊ីចឹង ខ្ញុំមិនដឹងឆ្លើយថាម៉េច ព្រោះគាត់បានមក

01329856

បកស្រាយនៅទីនេះហើយដែរ។ តែដោយឡែក ចង់និយាយថា ដល់តែដឹង គ្រាន់តែខ្ញុំដឹងថា គាត់ផ្លាស់ទៅកំពង់ចាម មានបញ្ហាអីជាមួយគាត់ ប្តីគាត់មុនហ្នឹងទៅ។ អ្ហ៊ុអាហ្នឹងខ្ញុំដឹងអ៊ីចឹងមក។ ដល់មកនៅទីនេះវិញ គាត់នៅអ៊ីចឹងទៅ ឬក៏គាត់មកពីកំពតអីហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង កន្លែងដែលគាត់ធ្វើហើយហ្នឹងដឹងដូចគ្នាហ្នឹងហើយ។ តែគ្រាន់តែឲ្យនិយាយរឿងអីផ្សេង គឺមិនមានទេ។ វាពាក់ព័ន្ធ បើតាមខ្ញុំដឹងគឺគាត់ពាក់ព័ន្ធទំនប់៦មករាដែរ មិនមែន១មករាទេ ៦មករា នៅកំពង់ថ្កុំង។ ហ្នឹងខ្ញុំឃើញដែលដឹងហ្នឹង ខ្ញុំដឹងប៉ុណ្ណឹង។ បាទ សូមអរគុណ។

[១៥:៥៨:៣៥]

**ស៖** ហើយខ្ញុំមានសំណួរមួយទៀត សូមទោសផងលោកប្រធាន ដែលខ្ញុំត្រូវសួរសំណួរបន្តមួយទៀត។ លោកសាក្សី ព្រឹកនេះ ព្រឹកមិញនេះលោក -- ព្រឹកមិញនេះ គឺថាខ្ញុំអានសារព័ត៌មានពីរ អំពីសក្ខីកម្មរបស់លោកកាលពីម្សិលមិញនេះ។ គឺអត្ថបទសារព័ត៌មាននេះនិយាយអំពី តាម៉ុក ដែលលោកបានប្រាប់កាលពីម្សិលមិញ ទាក់ទង តាម៉ុក។ ហើយនៅក្នុងសារព័ត៌មានទាំងពីរហ្នឹង គឺថា តាម៉ុក ត្រូវបានគេហៅថាជា "ពេជ្ឈឃាដ"។ ដូច្នេះឥឡូវហ្នឹង គឺហាក់ដូចជាបង្ហាញថា លោកស្គាល់ តាម៉ុក ច្បាស់។ តើលោកដឹងទេថា គេហៅ តាម៉ុក ថា "ពេជ្ឈឃាដ" ពីឆ្នាំ១៩៧៥ រហូតដល់ខែមករា ៧៩ ឬក៏មុននេះបន្តិច? តើលោកធ្លាប់ដឹងទេ ថាគេហៅគាត់អ៊ីចឹង?

**ឆ៖** បញ្ហានេះ ខ្ញុំសូមបដិសេធពាក្យថា "ពេជ្ឈឃាដ" នេះមួយ។ អានេះខ្ញុំមិនមែនថាជិតដិតអីគាត់ ហើយក៏មិនមែនអីដែរ ព្រោះគាត់បានទៅពេជ្ឈឃាដឯណា បើគាត់រវល់កងទ័ពផង រវល់គាត់ទៅនេះទៅនោះ។ ហើយដល់ឲ្យគាត់ថាទៅសម្លាប់អ្នកណាបានម្នាក់។ អានេះខ្ញុំនិយាយរឿងតាមួយចុះ។ បើគេអ្នកថា សារព័ត៌មានថា "ពេជ្ឈឃាដ" ហ្នឹង បើគាត់នៅរស់ មិនតវ៉ាជាមួយគាត់។ នេះខ្ញុំនិយាយត្រង់ណា។ មិនកាន់ជើង តែដោយឡែក គាត់គិតកងទ័ពអត់បាយ គិតប្រជាជនជីកទំនប់ប្រឡាយអីឯណាឯណី ដល់អ៊ីចឹងគាត់មានពេលឯណាទៅសម្លាប់មនុស្សបាន។ តែដោយឡែកមិនដឹងខាងក្រោមគេធ្វើយ៉ាងណា សម្រាប់ស្រុកនុំងយ៉ាងម៉េចអីយ៉ាងម៉េច បញ្ហាហ្នឹងខ្ញុំមិនៗជំទាស់ទេ។ តែដោយឡែកព័ត៌មានគេពិតមិនពិត អាហ្នឹងខ្ញុំ ដោយឡែកខ្ញុំមិនដឹង អាហ្នឹងខ្ញុំឆ្លើយអត់បាន ព្រោះខ្ញុំអត់ដែលបានដឹង បានឃើញបានឮ។ ខ្ញុំឆ្លើយជម្រាបលោកប៉ុណ្ណឹងចុះ។ បាទសូមអរគុណ។

[១៦:០០:៣៩]

**ស៖** អ៊ីចឹងបានន័យថា ឈ្មោះគេហៅថា "ពេជ្ឈឃាដ" ហ្នឹងគឺលោក គឺថាវាអត់មានន័យទាល់

តែសោះ អ៊ីចឹងមែនទេ?

**ឆ៖** ព្រោះលោកសួរខ្ញុំនេះ ព្រោះខ្ញុំអត់បានដឹងទេ។ ព្រោះគាត់ បើនិយាយពីថាគាត់ពេជ្ឈឃាដហ្នឹង ឲ្យចំបុគ្គល“ក” បុគ្គល“ខ”អ៊ីចឹង ឧទាហរណ៍អាហ្នឹងសួរឲ្យចំទិស។ តែបើសិនណាជាថាក្នុងក្រោមការដឹកនាំនេះ ឧទាហរណ៍ថាពាក្យហ្នឹង ដូចថាចង់និយាយថាពាក្យ ដូចថានៅក្នុងតំបន់គាត់ កាន់កាប់ហ្នឹងវាបាត់អីអ៊ីចេះអ៊ីចុះ អាហ្នឹងៗមិនដឹងអារឿងហ្នឹង របស់រឿងខាងលើចុះ អាហ្នឹងខ្ញុំអត់បានដឹងទេ ប៉ុន្តែឲ្យតែខ្ញុំដឹងថា គេដាក់ភាសាយ៉ាងណាៗ ខ្ញុំអត់ៗបានដឹងទេបាទ។ មិនមែនថាខ្ញុំបដិសេធ តែខ្ញុំគ្រាន់តែខ្ញុំអត់បានដឹង ព្រោះខ្ញុំអត់ដែលបានឃើញឮពាក្យហ្នឹង ព្រោះខ្ញុំអត់ដឹងបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះម៉េចទៅខាងក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន?

[១៦:០១:៥៣]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ យើងត្រូវការពេលវេលាប្រហែលជា៤៥នាទីទៅមួយម៉ោងតែប៉ុណ្ណោះ លោកប្រធានដើម្បីសួរសំណួរទៅសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៨ ខែកក្កដា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី 2-TCW-1005 បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មអ្នកជំនាញ 2-TCE-90 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី។ ការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សីនេះវិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់មកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែក

ទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន និង លោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*